60TH ANNIVERSARY OF DIPLOMATIC RELATIONS • ខួបលើកទី ៦០ នៃទំនាក់ទំនងការទូត
60th
UNITED STATES-CAMBODIA • 1950-2010
USAID

President Obama's Letter to His Majesty King Norodom Sihamoni on the Occasion of the 60th Anniversary of Diplomatic Relations between the United States and Cambodia

Your Majesty:

On behalf of the American people, I wish to congratulate the Kingdom of Cambodia on the Occasion of the 60th anniversary of the establishment of diplomatic relations between our two countries. This important milestone presents us with the opportunity to reflect on our shared past and to plot a course for the future based on the strong foundation we have built together.

Both Cambodia and the United States have changed immensely since July 11, 1950, when our first Ambassador to your country presented his credentials to King Sihanouk. As with any bilateral relationship, there have been times when we have not agreed, but the overall growth in the depth and breadth of our engagement reflects a maturing partnership. Over the last several years, for example, we have seen many positive developments, including the establishment of the Peace Corps program in Cambodia, the creation of the Extraordinary Cambers of the Courts in Cambodia and completion of its first trial, and the inauguration of Cambodia's peacekeeping force, a truly momentous achievement for a coutry that was the beneficiary of peacekeepers less than two decades before. The United States is now the top market for Cambodia's garment exporters, forming a pillar for the country's economic growth. Military-to-military and counterterrism cooperation between our two countries has grown as well, creating a safer environment for both Americans and Cambodians.

In the coming years, we look forward to taking advantage of the positive momentum that has been created and to see the patnership between our two nations grow stronger and deeper in areas such as food security, climate change, health, education, human rights, and strengthening democratic institutions.

I congratulate the Royal Government and the people of Cambodia on their achievements and offer my best wishes on the occasion of this important anniversary.

Sincerely,
Barack Obama

សាររបស់លោកប្រធានាធិបតី Obama ថ្វាយព្រះករុណាព្រះមហាក្សត្រ នរោត្តម សីហមុនី ក្នុងឱកាសខួបលើកទី ៦0 នៃទំនាក់ទំនងការទូតរវាងសហរដ្ឋអាមេរិក និងព្រះរាជាណាចក្រកម្ពុជា

ព្រះករុណា :

តាងនាមអោយប្រជាជនអាមេរិក ទូលបង្គំសូមថ្លែងអំណរសរសើរដល់ព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបលើកទី ៦0 នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសយើងទាំងពីរ។ ព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ជាប្រវត្តិសាស្ត្រនេះផ្តល់អោយយើងនូវឱកាសធ្វើការឆ្លុះបញ្ចាំងលើអតីតកាលរួមគ្នារបស់យើង ហើយដាក់ចេញនូវមាគ៌ាសំរាប់អនាគត ដោយឈរលើគ្រឹះរឹងមាំ ដែលយើងបានកសាងជាមួយគ្នាកន្លងមក។

ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិកមានការប្រែប្រួលច្រើន ចាប់តាំងពីថ្ងៃទី ១១ ខែកក្កដា ឆ្នាំ១៩៥0 មក នៅពេលដែលឯកអគ្គរដ្ឋទូតលើកដំបូងរបស់យើងប្រចាំប្រទេសរបស់ព្រះអង្គ បានថ្វាយសារតាំងដល់ព្រះករុណា ព្រះបាទនរោត្តមសីហនុ។ ដូចនឹងទំនាក់ទំនងទ្វេភាគីដទៃទៀតដែរ មានពេលខ្លះ យើងមិនយល់ស្របគ្នា តែជារួមជិវៅនិងទំហំនៃការទាក់ទងគ្នារបស់យើង បានឆ្លុះបញ្ចាំងអោយឃើញនូវភាពជាដៃគូប្រកបដោយភាពចាស់ទុំ។ ឧទាហរណ៍ ក្នុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ មានការវិវត្តន៍ជាវិជ្ជមានជាច្រើន ដូចជា ការធ្វើអោយមានកម្មវិធីរបស់ទីភ្នាក់ងារ Peace Corps នៅប្រទេសកម្ពុជា ការបង្កើតតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនៅប្រទេសកម្ពុជា និងការបញ្ចប់សវនាការកាត់ក្តីករណីដំបូងរបស់តុលាការនេះ ហើយនិងការបង្កើតកំលាំងថែរក្សាសន្តិភាពកម្ពុជា ដែលជាជោគជ័យអស្ចារ្យមួយសំរាប់ប្រទេសមួយដែលធ្លាប់តែជាប្រទេសទទួលផលពីការថែរក្សាសន្តិភាព កាលពីជិត ២ ទសវត្ស មុន។ នៅពេលនេះ សហរដ្ឋអាមេរិកគឺជាទីផ្សារធំជាងគេសំរាប់ការនាំចេញសំលៀកបំពាក់របស់ប្រទេសកម្ពុជា ដែលជាសសរទ្រូងនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ កិច្ចសហប្រតិបត្តិការរវាងយោធានិងយោធា ហើយក្នុងការប្រឆាំងភេរវកម្មរវាងប្រទេសយើងទាំងពីរ ក៏មានការរីកចំរើនផងដែរ ដែលជាការបង្កើតអោយមានបរិយាកាសប្រកបដោយសុវត្ថិភាពសំរាប់ប្រជាជនអាមេរិក និងប្រជាជនកម្ពុជា។

ក្នុងឆ្នាំខាងមុខៗនេះ យើងរំពឹងថា នឹងទទួលបានអត្ថប្រយោជន៍ពីដំណើរទៅមុខជាវិជ្ជមានដែលត្រូវបានបង្កើតឡើង ហើយមើលឃើញភាពជាដៃគូនៃប្រទេសទាំងពីররបស់យើង កាន់តែមានភាពរឹងមាំ និងស៊ីជំរៅក្នុងវិស័យនានា ដូចជាសន្តិសុខ ស្បៀង ការប្រែប្រួលអាកាសធាតុ សុខាភិបាល អប់រំ សិទ្ធិមនុស្សនិងស្ថាប័នប្រជាធិបតេយ្យដែលកាន់តែមានភាពរឹងមាំ។

ទូលបង្គំសូមសរសើរដល់រាជរដ្ឋាភិបាលកម្ពុជានិងប្រជាជនកម្ពុជាចំពោះជោគជ័យដែលសំរេចបានរបស់គេ និងសូមថ្វាយសព្វសាធុការពរក្នុងឱកាសខួបដ៏មានសារៈសំខាន់នេះ។

ដោយសេចក្តីស្មោះពីទូលបង្គំ

Barack Obama

Thank You Letter from His Majesty King Norodom Sihamoni to President Obama

Mr. President,

I wish to convey to Your Excellency and the People of the United States of America my sincere appreciation for your congratulatory letter of 13th July 2010 conveying Your Excellency's good wishes, on the occasion of the 60th Anniversary of the establishment of diplomatic relations between our two Countries.

Both the United States of America and the Kingdom of Cambodia have enjoyed a friendly relationship for 60 years. I am convinced that the bilateral cooperation existing between our two Countries will be further expanded in all fields for the mutual benefit of our two People, and in the interest of peace, stability and development in the world.

I extend my warmest congratulations to your Excellency, Your Administration and the People of the United States of America on their achievements.

With my best wishes, please accept, Mr. President, the renewed assurance of my highest consideration and personal esteem.

//signed//
Norodom Sihamoni
King of Cambodia

ព្រះរាជសារអំណរគុណរបស់ព្រះករុណាព្រះបាទនរោត្តម សីហមុនី ដល់លោកប្រធានាធិបតី Obama ក្នុងឱកាសខួបលើកទី ៦0 នៃទំនាក់ទំនងការទូតរវាងសហរដ្ឋអាមេរិក និង ព្រះរាជាណាចក្រកម្ពុជា

លោកប្រធានាធិបតី :

ខ្ញុំសូមសំដែងអំណរគុណដោយស្មោះជូនឯកឧត្តម និងប្រជាជនអាមេរិកចំពោះសារលិខិតអបអរសរបស់ឯកឧត្តម ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១0 ដែលក្នុងនោះឯកឧត្តមបានសំដែងពរសព្ទសាធុការរបស់ឯកឧត្តម នៅក្នុងឱកាសខួបលើកទី ៦0 នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសយើងទាំងពីរ។

សហរដ្ឋអាមេរិក និងព្រះរាជាណាចក្រកម្ពុជាមានទំនាក់ទំនងមិត្តល្អជាមួយគ្នា អស់រយៈពេល ៦0 ឆ្នាំមកហើយ។ ខ្ញុំជឿជាក់ថាកិច្ចសហប្រតិបត្តិការទ្វេភាគី ដែលកំពុងកើតមានរវាងប្រទេសយើងទាំងពីរ នឹងត្រូវបានពង្រីកថែមទៀត ក្នុងគ្រប់វិស័យទាំងអស់ ដើម្បីជាប្រយោជន៍ទៅវិញទៅមករបស់ប្រជាជនយើងទាំងពីរនិងដើម្បីជាផលប្រយោជន៍ដល់សន្តិភាព ស្ថេរភាព និងការអភិវឌ្ឍន៍ក្នុងពិភពលោក។

ខ្ញុំសូមសំដែងការអបអរយ៉ាងកក់ក្តៅបំផុតជូនចំពោះឯកឧត្តម រដ្ឋការរបស់ឯកឧត្តម និងប្រជាជនអាមេរិក ចំពោះជោគជ័យដែលគេសំរេចបាន។ ជាមួយនឹងពរសព្ទសាធុការរបស់ខ្ញុំ សូមលោកប្រធានាធិបតីទទួលយកនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

//ព្រះហស្តលេខា//
នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

A Message from Ambassador Carol Rodley

I'm honored that my term as Ambassador coincides with the 60th anniversary of the establishment of diplomatic relations between the United States of America and the Kingdom of Cambodia. On this momentous occasion, we take time to reflect on our relationship over the past 60 years. While the following pages highlight the past milestones of the cooperation between our two countries, I am most optimistic about our future relationship.

The connection between the Royal Government of Cambodian and the United States has never been stronger than it is today. From economic growth projects, to cultural exchange programs, to military cooperation, the level of substantive collaboration is unprecedented. In no time over the last 60 years have our two countries coordinated on a daily basis as much as we do now. This collaboration can only serve to increase the strength of our bonds.

Our Embassy is home to over one hundred American staff and a dozen U.S. Government agencies, including USAID, which manages an assistance budget of over $60 million. As one might imagine our bilateral engagement with Cambodia has expanded accordingly and now includes cooperation in areas such as counterterrorism, anti-trafficking, and the environment.

Some of our priorities have not changed, though, and we continue to invest in areas the United States has identified as critical since relations were restored in 1994 following the Paris Peace Accords. Health and education remain a top priority and we see our investment in the people of Cambodia as a down payment on the country's future. A good part of our annual assistance goes to improving access to quality primary education and health care in the provinces. We are also working on agriculture and food security concerns, both of which are extremely important in a country where 80% of the population supports itself through raising livestock, rice, and other crops.

The commemoration of the 60th Anniversary began in May when the US Embassy hosted the Los Angeles based band Dengue Fever. Their 1960's Khmer rock revival music demonstrates the perfect potential of artistic collaboration. The USNS Mercy naval medical ship anchored in Sihanoukville from June 18-28 is another wonderful symbol of our friendship. The doctors from the ship traveled around the country and saw patients on board, treating nearly 30,000 Cambodians in the course of only 10 days. The 60th Anniversary celebrations continue over seven days from July 18-24. During this time we have programs that highlight cultural, educational, and political exchanges. I hope you are able to join us for these memorable events.

During this time of reflection, I have two thoughts about what the next 60 years will bring. First, no matter what happens, both sides will exert extensive energy. Building relationships is always hard work, and to continue making substantial breakthroughs will take a committed effort on both sides. Secondly, I have an enormous sense of hope. Looking at where we have come from just over the last decade, we have made enormous strides in building and sustaining a lasting partnership. If we continue on the same trajectory, I have no doubt that our countries will become even closer in the next 60 years and beyond.

សារ របស់លោកស្រីឯកអគ្គរដ្ឋទូត Carol Rodley

ខ្ញុំមានកិត្តិយសដោយអាណត្តិ របស់ខ្ញុំជាឯកអគ្គរដ្ឋទូតត្រូវចំខួបលើកទី ៦0 នៃការបង្កើតទំនាក់ទំនងការទូតរវាងសហរដ្ឋអាមេរិក និងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងឱកាសដ៏ខុឡារ៉ឹកនេះ យើងធ្វើការឆ្លុះបញ្ចាំងលើទំនាក់ទំនងរបស់យើងក្នុងពេល ៦0 ឆ្នាំកន្លងមកនេះ។ ថ្ងៃត្បិតតែទំព័រតទៅនេះបញ្ជាក់ពីព្រឹត្តិការណ៍សំខាន់ៗ កន្លងមកក្នុងកិច្ចសហប្រតិបត្តិការ រវាងប្រទេសយើងទាំងពីរក្តី តែខ្ញុំមានសុទិដ្ឋិនិយមបំផុតចំពោះទំនាក់ទំនងរបស់យើងនៅពេលអនាគត។

ការទាក់ទងគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងសហរដ្ឋអាមេរិក នៅពេលនេះមានភាពរឹងមាំជាងពេលណាៗទាំងអស់។ រាប់ពីគំរោងកំណើនសេដ្ឋកិច្ច ដល់កម្មវិធីផ្លាស់ប្តូរវប្បធម៌ ដល់កិច្ចសហប្រតិបត្តិការយោធា កំរិតនៃការសហការគ្នានៅពេលនេះគឺមិនធ្លាប់មានពីមុនមកទេ។ ក្នុងរយៈពេល ៦0 ឆ្នាំកន្លងមកនេះ មិនដែលមានប្រទេស ២ ណាធ្វើការសំរបសំរួលគ្នាជាប្រចាំរាល់ថ្ងៃដូចយើងធ្វើនៅពេលនេះទេ។ កិច្ចសហការនេះជួយបង្កើនភាពខ្លាំងនៃចំណងទាក់ទងគ្នារបស់យើង។

ស្ថានទូតរបស់យើងមានបុគ្គលិកជនជាតិអាមេរិកធ្វើការចំនួនជាង ១00 នាក់ ហើយមានទីភ្នាក់ងាររដ្ឋាភិបាលអាមេរិកជាច្រើន រួមទាំងទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលគ្រប់គ្រងថវិកាជិនួយជាង ៦0 លានដុល្លាអាមេរិក។ ដូចដែលគេអាចគិតដល់បានថា ទំនាក់ទំនងទ្វេភាគីរបស់យើងជាមួយប្រទេសកម្ពុជាមានច្រើនទៅតាមហ្នឹង ហើយនៅពេលនេះ មានកិច្ចសហប្រតិបត្តិការក្នុងវិស័យនានា ដូចជាការប្រឆាំងភេរវកម្ម ការប្រឆាំងការជួញដូរមនុស្ស និងបរិស្ថាន។

យ៉ាងណាក្តី អាទិភាពខ្លះរបស់យើងមិនមានការប្រែប្រួលទេ ហើយយើងបន្តធ្វើការវិនិយោគលើវិស័យដែលសហរដ្ឋអាមេរិកកំណត់ថា មានសារៈសំខាន់ចាំបាច់ តាំងពីទំនាក់ទំនងត្រូវបានស្តារអោយមានឡើងវិញ នៅឆ្នាំ ១៩៩៤ បន្ទាប់ពីមានកិច្ចព្រមព្រៀងក្រុងប៉ារីសមក។ សុខភាពនិងការសិក្សាអប់រំ នៅតែជាអាទិភាពកំពូល ហើយយើងមើលឃើញការវិនិយោគរបស់យើងលើប្រជាជនកម្ពុជាថាជាការចំណាយសំរាប់អនាគតនៃប្រទេសកម្ពុជា។ មួយចំណែកធំនៃជិនួយប្រចាំឆ្នាំរបស់យើងគឺសំរាប់បង្កើនលទ្ធភាពទទួលបានការសិក្សាអប់រំថ្នាក់បឋមសិក្សា និងការថែទាំសុខភាពប្រកបដោយគុណភាព នៅតាមខេត្តនានា។ យើងក៏កំពុងតែធ្វើការផងដែរលើបញ្ហាកសិកម្ម និងសន្តិសុខស្បៀង ដែលជាបញ្ហាមានសារៈសំខាន់ណាស់ នៅប្រទេសមួយដែលមានប្រជាជន ៨0% ចិញ្ចឹមជីវិតដោយការចិញ្ចឹមសត្ត ធ្វើស្រែ និងដាំដំណាំផ្សេងទៀត។

ការរំលឹកខួបទី ៦0 បានចាប់ផ្តើមនៅខែឧសភា នៅពេលស្ថានទូតបានរៀបចំការប្រគុំតន្ត្រីរបស់ក្រុម ដែលមានឈ្មោះថា Dengue Fever មកពីទីក្រុង Los Angeles។ ការប្រគុំឡើងវិញនៃតន្ត្រីរ៉ុករបស់ខ្មែរនៅទសវត្សឆ្នាំ ១៩៦0 បង្ហាញអោយឃើញនូវសក្តានុពលយ៉ាងល្អឥតខ្ចោះនៃការសហការគ្នាផ្នែកសិល្ប:។ នាវាពេទ្យរបស់កងទ័ពជើងទឹកសហរដ្ឋអាមេរិក ដែលមានឈ្មោះថា USNS Mercy និងបានចូលចតនៅក្រុងព្រះសីហនុ ពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២៨ ខែមិថុនា ក៏ជានិមិត្តរូបដ៏អស្ចារ្យមួយទៀតនៃមិត្តភាពរបស់យើង។ វេជ្ជបណ្ឌិតរបស់នាវាបានធ្វើដំណើរទូទាំងប្រទេសកម្ពុជា ហើយបានព្យាបាលអ្នកជំងឺនៅលើនាវា ដោយបានព្យាបាលអ្នកជំងឺសរុបចំនួនជិត ៣0 000 នាក់ ក្នុងរយៈពេលតែ ១0 ថ្ងៃប៉ុណ្ណោះ។ ការអបអរខួបលើកទី ៦0 បានបន្តអស់រយៈពេល ៧ ថ្ងៃ ពីថ្ងៃទី១៨ ដល់ថ្ងៃទី ២៤ ខែកក្កដា។ ក្នុងអំឡុងពេលនេះ យើងមានកម្មវិធីដែលបង្ហាញពីការផ្លាស់ប្តូរផ្នែកនយោបាយ អប់រំ និងវប្បធម៌។ យើងសង្ឃឹមថា លោកអ្នកនឹងអាចចូលរួមជាមួយយើងក្នុងពិធីដ៏គួរអោយចងចាំនេះ។

ក្នុងពេលនៃការធ្វើការឆ្លុះបញ្ចាំងនេះ ខ្ញុំមានគំនិតពីរស្តីពីអ្វីដែលរយៈពេល ៦0 ឆ្នាំទៅមុខទៀតនឹងនាំយកមក។ ទី១ ទោះបីមានអ្វីកើតឡើងក៏ដោយ ភាគីទាំងពីរនឹងបញ្ជេញថាមពលយ៉ាងច្រើន។ ការកសាងទំនាក់ទំនងគឺជាការលំបាក ហើយការបន្តនាំមកនូវលទ្ធផលល្អជាដុំកំភួនត្រូវការការខិតខំប្រកបដោយការប្តេជ្ញាចិត្តរបស់ភាគីទាំងសងខាង។ ទី២ ខ្ញុំមានក្តីសង្ឃឹមយ៉ាងច្រើន។ បើក្រឡេកទៅលើអ្វីដែលយើងបានផ្តើមចេញមកក្នុងទសវត្សកន្លងទៅនេះ យើងសំរេចបានជោគជ័យយ៉ាងច្រើន ក្នុងការកសាង និងរក្សាភាពជាដៃគូអោយបានស្ថិតស្ថេរ។ បើយើងបន្តនៅលើគន្លងនេះទៀត ខ្ញុំមានការប្រាកដក្នុងចិត្តថា ប្រទេសរបស់យើងទាំងពីរនឹងមានភាពកាន់តែជិតស្និទ្ធថែមទៀត ក្នុងពេល៦0 ឆ្នាំទៅមុខទៀត និងតទៅអនាគត។

Secretary of State John Foster Dulles visited the Royal Palace in February 1955.

រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក លោក John Foster Dulles ធ្វើទស្សនកិច្ច នៅ ព្រះបរមរាជវាំង ក្នុងខែកុម្ភៈ ឆ្នាំ១៩៥៥ ។

Prince Norodom Sihanouk addresses American students in San Francisco.

សម្តេចព្រះ នរោត្តម ស៊ីហនុ ថ្លែងទៅកាន់និស្សិតអាមេរិក នៅទីក្រុង San Francisco ។

1950s

- 1950: State Department recognizes Cambodia
- 1950: First U.S. diplomat presents credentials to King Sihanouk on July 11
- 1953: Cambodia declares its independence
- 1955: U.S. assistance program begins focusing on infrastructure and education
- 1958: Eisenhower and Sihanouk visit to the United States
- 1959: Inauguration of National Road 4

- ឆ្នាំ ១៩៥០: ក្រសួងការបរទេសសហរដ្ឋអាមេរិកទទួលស្គាល់ប្រទេសកម្ពុជា
- ឆ្នាំ ១៩៥០: អ្នកការទូតសហរដ្ឋអាមេរិកដំបូងគេ បានថ្វាយសារតាំងដល់ ព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ នៅថ្ងៃទី ១១ ខែកក្កដា
- ឆ្នាំ ១៩៥៣: ប្រទេសកម្ពុជាបានប្រកាសឯករាជ្យរបស់ខ្លួន
- ឆ្នាំ ១៩៥៥: កម្មវិធីជំនួយរបស់សហរដ្ឋអាមេរិកចាប់ផ្តើមផ្តោតលើ ហេដ្ឋារចនាសម្ព័ន្ធ និងការអប់រំ
- ឆ្នាំ ១៩៥៨: លោកប្រធានាធិបតី Eisenhower និងសម្តេចព្រះនរោត្តម សីហនុ ទស្សនកិច្ចទៅកាន់សហរដ្ឋអាមេរិក
- ឆ្នាំ ១៩៥៩: ការសម្ពោធផ្លូវជាតិលេខ ៤



Ambassador Donald Heath

លោកឯកអគ្គរដ្ឋទូត Donald Heath

Though the United States had established consular offices in neighboring Vietnam in the late 1800s, there was no official U.S. presence in Phnom Penh until 1950. Contact between the United States and Cambodia in the19th and early 20th centuries was limited to that of missionaries, adventurers, big-game hunters and scientists, with some accounts —like Frank Vincent Jr.'s book, The Land of the White Elephant, which chronicles his journey from Bangkok to the temples of Angkor Wat by boat in the 1870s—capturing the American imagination. With the export of goods including kerosene, timber, rice, and flour into French Indochina (of which Cambodia had been a part since 1887), the United States had also formed some early regional economic ties.

The post-World War II era saw a distinct shift in relations between the two countries, with Mao Zedong's armies nearing victory in China and the nationalist, anti-colonialist Viet Minh forces gaining against the French in northern Vietnam. As U.S. foreign policy increasingly focused on preventing the spread of Communism in Southeast Asia, friendly ties between the United States and Cambodia took on a new importance.

Cambodia, along with Vietnam and Laos, had comprised French Indochina since the late 19th century; during World War II, much of the territory was occupied by Vichy-backed Japanese troops. The French resumed control after 1945, but by then the Khmers had become

ថ្មីបើសហរដ្ឋអាមេរិកបានបង្កើតការិយាល័យកុងស៊ុលនៅប្រទេសវៀតណាម ដែលជាប្រទេសជិតខាងរបស់កម្ពុជានៅចុងទសវត្ស ១៨00 ក្តី តែសហរដ្ឋអាមេរិក មិនទាន់មានវត្តមានរបស់ខ្លួនជាផ្លូវការនៅភ្នំពេញរហូតដល់ឆ្នាំ ១៩៥0ទើបមាន។ ការទាក់ទងគ្នារវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជានៅសតវត្សទី ១៩ និងដើមសតវត្ស ទី ២0 មានត្រឹមតែកំរិតអ្នកដើរផ្សព្វផ្សាយសាសនា អ្នកផ្សងព្រេង អ្នកបរបាញ់សត្ត និងអ្នកវិទ្យាសាស្ត្រ ដោយមានរឿងខ្លះដូចជាសៀវភៅរបស់លោក Frank Vincent Jr. ដែលមានចំណងជើងថា ទឹកដីនៃដំរីស (The Land of the White Elephant) ដែលរៀបរាប់ពីដំណើររបស់លោកពីទីក្រុងបាងកក ទៅកាន់ប្រសាទអង្គរវត្ត តាមទូកនៅទសវត្ស ឆ្នាំ១៨៧0 ដោយបានធ្វើអោយមានការចាប់អារម្មណ៍ដល់ជនជាតិអាមេរិក។ ជាមួយ នឹងការនាំចេញនូវទំនិញដូចជាប្រេងកាត ឈើហ៊ីប ស្រូវ និងម្សៅ មី ចូលមកឥណ្ឌូចិន ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំង (កម្ពុជាបានចូលរួមក្នុងឆ្នាំ ១៨៨៧) សហរដ្ឋអាមេរិកក៏បានបង្កើតផងដែរនូវទំនាក់ទំនងសេដ្ឋកិច្ចខ្លះៗនៅក្នុងតំបន់ ក្នុងពេល ដំបូងៗទៀត។

នៅសម័យក្រោយសង្គ្រាមលោកលើកទី ២ ទំនាក់ទំនងរវាងប្រទេសទាំងពីរ មានការប្រែប្រួលយ៉ាងច្បាស់ ជាមួយនឹងការដែលកងទ័ពរបស់ម៉ៅសេទុងជិតទទួលបានជោគជ័យនៅប្រទេសចិន ហើយកងទ័ពវៀតមិញប្រឆាំងនឹងអាណានិគម កាន់តែមានប្រៀបលើបារាំង នៅវៀតណាមភាគខាងជើង។ ក្នុងពេលដែលគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិកកាន់តែផ្តោតច្រើនឡើងលើការទប់ការរាលដាលនៃរបបកុំម្មុយនិស្ត នៅអាស៊ីអាគ្នেយទំនាក់ទំនងមិត្តភាពរវាងសហរដ្ឋអាមេរិក និងកម្ពុជាក៏ចាប់មានសារៈសំខាន់មួយថ្មី ។

ប្រទេសកម្ពុជា រួមជាមួយនឹងប្រទេសវៀតណាម និងប្រទេសឡាវបង្កើតបាននូវអ្វីដែលបារាំងហៅថាឥណ្ឌូចិន តាំងពីចុងសតវត្សទី ១៩ មក។ ក្នុងអំឡុងសង្គ្រាមលោកលើកទី ២ ទឹកដីភាគច្រើនត្រូវបានកាន់កាប់ដោយកងទ័ពជប៉ុន ដែលគាំទ្រដោយ Vichy ។ បារាំងបានបន្តការកាន់កាប់ឡើងវិញនៅក្រោយ ឆ្នាំ ១៩៤៥ តែមកដល់ពេលនោះ ខ្មែរចាប់មានគំនិតចង់បានឯករាជ្យជាខ្លាំង។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ ១៩៥0 សភាបារាំងបានផ្តល់ដល់ប្រទេសទាំងបី នៅឥណ្ឌូចិននូវស្វ័យភាពនៅ ក្រោមសហភាពបារាំង។ បន្ទាប់ពីនោះបន្តិច សហរដ្ឋអាមេរិកបានទទួលស្គាល់រដ្ឋាភិបាលកម្ពុជាថ្មី ដោយមានព្រះមហាក្សត្រ នរោត្តម សីហនុ ជាអ្នកដឹកនាំ ។ មកដល់ខែឧសភាលោកប្រធានាធិបតី Harry Truman បានយល់ព្រមលើជំនួយសេដ្ឋកិច្ច និងយោធាចំនួន ២0

anxious for their independence. On February 7, 1950, the French Assembly granted the three Indochinese countries autonomy within the French Union; shortly thereafter, the United States recognized the new Cambodian government, with the young King Norodom Sihanouk as its head. By May, President Harry Truman approved $20 million in economic and military aid to Cambodia, an amount that would increase significantly over the decade.

The United States established its first direct diplomatic relationship with Cambodia on June 29, 1950, with the appointment of Donald R. Heath as Envoy Extraordinary and Minister Plenipotentiary. Heath presented his credentials to King Sihanouk on July 11, 1950. The US Legation opened in Phnom Penh on November 14. Operations were initially conducted from the renowned Hotel Le Royal until a Legation office and U.S. Information Service library were established in a new location. The Legation was raised to Embassy status on June 25, 1952, at which point Heath became the first U.S. Ambassador to Cambodia.

Simultaneously, the United States entered into a mutual defense assistance agreement with Cambodia, Laos, and Vietnam, which included $7.8 million in economic and military assistance to be distributed over four years. Nong Kimny, Cambodia's first minister to the United States, on his first visit to America, expressed Cambodia's "deep gratitude" for U.S. assistance during his meeting with President Truman. (As a further gesture of appreciation, King Sihanouk sent the President a rare white elephant. The first U.S. Chargé d'Affaires to Cambodia, Don V. Catlett, is most remembered for managing the daunting task of shipping the animal to Washington.) After intense negotiations between King Sihanouk and the French government—with the United States often acting as mediator—Cambodia declared its full independence on November 9, 1953. But it would not be until the Geneva Conference the next year that the French would fully cede authority. Throughout the talks, the United States actively supported Cambodia's bid for autonomy.

Shortly after the Geneva Accords, Robert McClintock became

លានដុល្លាសំរាប់ប្រទេសកម្ពុជា ហើយចំនួននេះមានការកើនឡើងយ៉ាងច្រើននៅពេលបន្តបន្ទាប់មកទៀតក្នុងទសវត្សនោះ។

សហរដ្ឋអាមេរិកបានបង្កើតទំនាក់ទំនងការទូតដោយផ្ទាល់របស់ខ្លួនជាលើកដំបូង ជាមួយប្រទេសកម្ពុជា នៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ១៩៥0 ដោយបានតែងតាំងលោក Donald R. Heath អោយធ្វើជាតំណាងវិសាមញ្ញ និងពេញសមត្ថភាព។ លោក Heath បានថ្វាយសារតាំងទៅព្រះករុណាសម្តេចព្រះបាទ នរោត្តម សីហនុ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ ១៩៥0។ ការិយាល័យតំណាងសហរដ្ឋអាមេរិកបានបើកនៅភ្នំពេញ នៅថ្ងៃទី ១៤ ខែវិច្ឆិកា។ សណ្ឋាគារឡ្យ៉ូយ៉ាល់ដែលមានឈ្មោះល្បី គឺជាកន្លែងធ្វើការដំបូងរបស់ស្ថានទូតអាមេរិករហូតដល់ការិយាល័យអគ្គរដ្ឋទូតមួយ និងបណ្ណាល័យផ្តល់សេវាពត៌មានសហរដ្ឋអាមេរិកមួយត្រូវបានបង្កើត ឡើងនៅកន្លែងថ្មីមួយ។ ការិយាល័យតំណាងទូតត្រូវបានដំឡើងអោយទៅជាស្ថានឯកអគ្គរដ្ឋទូត នៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៥២ ដោយនៅពេលនោះ លោក Heath បានក្លាយទៅជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ដំបូងគេប្រចាំនៅប្រទេសកម្ពុជា។ នៅទន្ទឹមនឹងនោះ សហរដ្ឋអាមេរិកបានចុះកិច្ចព្រមព្រៀងផ្តល់ជំនួយការពារប្រទេសទៅវិញទៅមក

The US Legation opened in Phnom Penh on November 14. Operations were initially conducted from the renowned Hotel Le Royal.

ការិយាល័យតំណាងសហរដ្ឋ អាមេរិកបានបើក នៅភ្នំពេញ នៅថ្ងៃទី ១៤ ខែវិច្ឆិកា។ សណ្ឋាការ ឡ្យ៉ូយ៉ាល់ ដែលមានឈ្មោះល្បី គឺជាកន្លែងធ្វើការដំបូងរបស់ស្ថានទូតអាមេរិក។

Ambassador to Cambodia, presenting his credentials to the King on October 2, 1954. The Embassy continued to grow, relocating to a larger space to accommodate its expanding staff.

With the King taking the lead, the now fully independent country of Cambodia was staunchly committed to maintaining its neutrality, and Sihanouk cultivated friendships with both western and communist powers. In light of Ho Chi Minh's communist government in North Vietnam and fear that Cambodia's armed forces were ill equipped to handle a possible communist insurgency, the United States began working with the Cambodian government to expand U.S. military assistance in the country. Details of a military training program, which included the establishment of a Military Assistance Advisory Group (MAAG), were worked out by Ambassador McClintock and Assistant Secretary of State Walter S. Robinson, with Secretary of State John Foster Dulles visiting Phnom Penh (the highest level official visit at the time) in February 1955 to meet with King Sihanouk and discuss the plan. The military defense agreement was signed in May.



Secretary of State John Foster Dulles visited the Royal Palace in February 1955.

រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក លោក John Foster Dulles ធ្វើទស្សនកិច្ច នៅព្រះបរមរាជវាំង ក្នុងខែកុម្ភៈ ឆ្នាំ១៩៥៥ ។

ជាមួយប្រទេសកម្ពុជា ឡាវ និងវៀតណាម ដោយមានបញ្ជូលជំនួយយោធា និងសេដ្ឋកិច្ចចំនួន ៣.៨ លានដុល្លាអាមេរិក ដែលត្រូវផ្តល់ក្នុងរយៈពេល៤ ឆ្នាំ។ លោកនង គិមនី (Nong Kimny) ដែលជាទូតតំណាងដំបូងគេរបស់ប្រទេសកម្ពុជាប្រចាំនៅសហរដ្ឋអាមេរិក នៅពេលធ្វើទស្សនកិច្ចលើកដំបូងទៅកាន់សហរដ្ឋអាមេរិកបានសំដែង "ការដឹងគុណយ៉ាងជ្រាលជ្រៅ" របស់ប្រទេសកម្ពុជា ចំពោះជំនួយរបស់សហរដ្ឋអាមេរិកក្នុងពេលលោកជួបជាមួយលោកប្រធានាធិបតី Truman ។ (ជាកាយវិការសំដែងអំណរគុណបន្ថែមទៀត ព្រះករុណាព្រះមហាក្សត្រ នរោត្តមសីហនុ បានផ្ញើរជូនលោកប្រធានាធិបតីនូវដំរីសដ៏កំរមួយ ។ លោក Don V. Catlett ដែលជាភារធារីលើកដំបូងរបស់សហរដ្ឋអាមេរិក ប្រចាំនៅប្រទេសកម្ពុជា ត្រូវបានគេនៅចាំច្បាស់ជាងគេក្នុងការចាត់ចែងការងារដ៏ពិបាកក្នុងការដឹកយកដំរីសនោះទៅទីក្រុងវ៉ាស៊ីនតោន) ។

បន្ទាប់ពីមានការចរចាដ៏តឹងតែងរវាងព្រះករុណាព្រះមហាក្សត្រ នរោត្តមសីហនុ និងរដ្ឋាភិបាលបារាំង ដែលជាញឹកញាប់មានសហរដ្ឋអាមេរិកធ្វើជាអាជ្ញាកណ្តាលនោះ ប្រទេសកម្ពុជាបានប្រកាសឯករាជ្យពេញលេញរបស់ខ្លួននៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣។ តែទោះជាយ៉ាងណាក៏ដោយដល់នឹងសន្និសីទក្រុងហ្ស៊ីណែវ ក្នុងឆ្នាំបន្ទាប់ ទើបបារាំងសុខចិត្តបោះបង់អំណាចពេញលេញ។ ក្នុងដំណើរការចរចាទាំងមូល សហរដ្ឋអាមេរិកគាំទ្រយ៉ាងសកម្មដល់ការទាមទារស្វ័យភាពរបស់ប្រទេសកម្ពុជា។

បន្ទាប់ពីមានកិច្ចព្រមព្រៀងក្រុងហ្ស៊ីណែវភ្លាម លោក Robert McClintock បានក្លាយជាឯកអគ្គរដ្ឋទូតប្រចាំនៅប្រទេសកម្ពុជា ដោយបានថ្វាយសារតាំងដល់ព្រះករុណា នៅថ្ងៃទី ២ ខែតុលា ឆ្នាំ ១៩៥៤។ ស្ថានទូតបានបន្តរីកធំ ដោយបានប្តូរទីកន្លែងទៅកាន់កន្លែងធំទូលាយជាងមុន ដោយសារមានបុគ្គលិកកាន់តែច្រើនឡើង។ ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះអង្គ ប្រទេសកម្ពុជា ដែលមានសេរីភាព ពេញលេញនោះ បានប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការការារក្សាអព្យាក្រិតភាពរបស់ខ្លួន ហើយព្រះករុណាព្រះបាទ នរោត្តមសីហនុបានបណ្តុះអោយមានមិត្តភាព ទាំងជាមួយប្រទេសលោកខាងលិច ទាំងជាមួយមហាអំណាចកុំម្មុយនិស្ត។ ដោយសារមានរបបកុំម្មុយនិស្តរបស់ហូជីមុិញនៅវៀតណាមភាគខាងជើង និងការភ័យខ្លាចថា កងកំលាំងទ័ពកម្ពុជាមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទប់ទល់ការបះបោររបស់ពួកកុំម្មុយនិស្ត ដែលអាចកើតមានឡើងនោះ សហរដ្ឋអាមេរិកបានចាប់ផ្តើមធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា



Ambassador McClintock

ឯកអគ្គរដ្ឋទូត McClintock

Simultaneously, Ambassador McClintock focused efforts on securing the gradual withdrawal of French troops from Cambodia.

Bilateral relations between the two countries received another significant boost with the establishment in 1955 of a $50-million-per-year assistance program, which sought to promote economic and social progress; strengthen indepedence; improve and expand free public education; increase the quantity and quality of agricultural yields; improve public health, security, and infrastructure; and modernize the armed forces. The aid program was larger in size and scope than the combined support from all other countries and international organiztions, with the United States providing $493 million in assistance by 1963.

U.S. assistance trained teachers and helped build and equip elementary, secondary, and specialist schools across many fields. U.S. funding established the country's first Primary Teachers Training Center in Kampong Kantuot, as well as 14 elementary schools and five secondary school buildings. Several Cambodian students were also sent to the United States on scholarships to study agriculture, public health, industrial arts, and engineering.

Other projects included the construction of health centers, pediatric facilities, and a police academy, along with extensive expansion and improvement of Cambodia's infrastructure, which included the repair of

ដើម្បីបង្កើនជំនួយយោធារបស់សហរដ្ឋអាមេរិកនៅកម្ពុជា។ ចំណុចលំអិតស្តីពីកម្មវិធីហ្វឹកហ្វឺនយោធាដែលរួមមានផងដែរនូវការបង្កើតក្រុមផ្តល់ប្រឹក្សាសំរាប់ជំនួយយោធា (MAAG) ត្រូវបានរៀបចំដោយឯកអគ្គរដ្ឋទូត McClintock និងឧបការីរដ្ឋមន្ត្រីក្រសួងការបរទេស Walter S. Robinson ដោយមានរដ្ឋមន្ត្រីការបរទេស John Foster Dulles បានមកធ្វើទស្សនកិច្ច នៅទីក្រុងភ្នំពេញ (ដែលជាទស្សនកិច្ចផ្លូវការថ្នាក់ ខ្ពស់បំផុត នៅពេលនោះ) នៅខែកុម្ភៈ ឆ្នាំ ១៩៥៥ ដើម្បីជួបពិភាក្សាស្តីពីផែនការជាមួយព្រះករុណា ព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហនុ។ កិច្ចព្រមព្រៀងយោធាការពារប្រទេសត្រូវបានចុះហត្ថលេខានៅខែឧសភា។ ទន្ទឹមនឹងនោះ លោកឯកអគ្គរដ្ឋទូត McClintock បានផ្តោតការយកចិត្តទុកដាក់លើការធានាអោយមានការដកកងទ័ពបារាំងបន្តិចម្តងៗចេញពីប្រទេសកម្ពុជា។ ទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរបានទទួលការជំរុញមួយថ្មីទៀត ដោយមានការបង្កើតនៅឆ្នាំ ១៩៥៥ នូវកម្មវិធីជំនួយមានទឹកប្រាក់ចំនួន ៥0 លានដុល្លាអាមេរិកក្នុងមួយឆ្នាំៗដែលមានបំណងជំរុញដំណើរជឿនលឿនផ្នែកសេដ្ឋកិច្ច និងសង្គមពង្រឹងឯករាជ្យ កែលំអ និងពង្រីកការសិក្សាអប់រំសាធារណៈដោយមិនយកថ្លៃ បង្កើនគុណភាព និងបរិមាណផលិតផលកសិកម្ម លើកកំពស់សុខភាពសាធារណៈ សន្តិសុខ និងហេដ្ឋារចនាសម្ព័ន្ធ និងធ្វើទំនើបកម្មកងកំលាំងប្រដាប់អាវុធ។ កម្មវិធីជំនួយនេះមានទំហំនិងកំរិតធំជាងជំនួយបូករួមចូលគ្នាទាំងអស់ពីបណ្តាប្រទេសនិងអង្គការអន្តរជាតិដទៃទៀត ដោយសហរដ្ឋអាមេរិកបានផ្តល់ជំនួយ ៤៩៣ លានដុល្លា គិតត្រឹមឆ្នាំ ១៩៦៣។ ជំនួយរបស់សហរដ្ឋអាមេរិកបានជួយបណ្តុះបណ្តាលគ្រូ និងជួយកសាង និងបំពាក់គ្រឿងបរិក្ខាដល់សាលាឯកទេស តាមវិស័យជាច្រើន សាលាមធ្យមសិក្សា និងសាលាបឋមសិក្សា។ ថវិកាពីសហរដ្ឋអាមេរិកបានបង្កើតមជ្ឈមណ្ឌលគរុកោសល្យបឋមលើកដំបូងរបស់ប្រទេសកម្ពុជា នៅកំពង់កន្ទុត រួមជាមួយនឹងសាលា បឋមសិក្សាចំនួន១៤ និងអាគារសាលា មធ្យមសិក្សាចំនួន ៥ ផ្សេងទៀត ។ និស្សិតកម្ពុជាមួយចំនួនបានទទួលអាហារូបករណ៍ទៅសិក្សានៅសហរដ្ឋអាមេរិកក្នុងផ្នែកកសិកម្ម សុខភាពសាធារណៈ បច្ចេកទេសក្នុងការប្រើប្រាស់ឧបករណ៍ និងគ្រឿងម៉ាស៊ីន និងវិស្វកម្ម។

គំរោងដទៃទៀតរួមមានការកសាងមណ្ឌលសុខភាពមន្ទីរពេទ្យកុមារ និងបណ្ឌិសភានរគបាល រួមជាមួយនឹងការពង្រីក និងការកែលំអហេដ្ឋារចនាសម្ព័ន្ធនៅប្រទេសកម្ពុជា ដូចជាការជួសជុលផ្លូវប្រវែង ៨00 ម៉ែល៍ និងស្ពានចំនួន ៤៣ ជាដើម។ ចំណុចលេចធ្លោមួយទៀតក្នុងការខិតខំទាំងនេះគឺផ្លូវ មិត្តភាពកម្ពុជា អាមេរិក ដែល

Mr. Iv CHay Iv Yan, Director of the National School of Arts and Crafts, and his assistant confer with the director of the American aid mission Charles A. Mann and the mission's chief advisor in education, Dr. Loper, over model school to be constructed and equipped by American aid program.

800 miles of roads and 43 bridges. A highlight of these efforts was the Khmer-American Friendship Highway, a 140-mile-long road that would link Phnom Penh with the newly built port at Sihanoukville, along Cambodia's coast. The $25-million construction was the largest single cooperative aid project, with American and Cambodian laborers working side-by-side.

Meanwhile, changes were taking place on the Cambodian political scene. In March 1955, King Sihanouk abdicated the throne to form the Sangkum political party and stand for election later that year. The Prince, as he was now known, handily won the September election and took the post of Prime Minister.

In October 1956, Ambassador McClintock completed his tour and Carl W. Strom was appointed as the next U.S. Ambassador. He presented his credentials to the Prince on December 7, 1956 and remained in the

មានប្រវែង ១៤0 ម៉ែល ភ្ជាប់ទីក្រុងភ្នំពេញ ទៅនឹងកំពង់ផែដែលទើបតែកសាងថ្មី នៅទីក្រុងព្រះសីហនុ ដែលនៅតាមឆ្នេរសមុទ្រនៃប្រទេសកម្ពុជា។ ការធ្វើផ្លូវនេះបានចំណាយថវិកាអស់ ២៥ លានដុល្លាអាមេរិក គឺជាគំរោងជំនួយសហប្រតិបត្តិការទោលធំជាងគេ ដោយមានកម្មករអាមេរិក និងកម្មករខ្មែរធ្វើការជាមួយគ្នាទៀតផង។

តែទន្ទឹមនឹងនោះ ក៏មានការប្រែប្រួលផងដែរក្នុងផ្នែកនយោបាយរបស់ប្រទេសកម្ពុជា។ នៅខែមិនា ឆ្នាំ ១៩៥៥ព្រះករុណាព្រះបាទនរោត្តម សីហនុបានដាក់រាជ្យ ដើម្បីបង្កើតគណបក្សសង្គមរាស្ត្រនិយម ហើយបានចូលរួមបោះឆ្នោតនៅចុងឆ្នាំនោះ។ សម្តេច ដែលត្រូវបានគេហៅនៅពេលនោះ បានឈ្នះការបោះឆ្នោតខែកញ្ញាដោយស្រួល ហើយបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រី។ នៅខែតុលា ឆ្នាំ ១៩៥៦ លោកឯកអគ្គរដ្ឋទូត McClintock បានបញ្ចប់បេសកកម្មរបស់លោក ហើយលោក Carl W. Strom ត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតបន្ទាប់របស់សហរដ្ឋអាមេរិក។ លោកបានថ្វាយសារតាំងដល់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ១៩៥៦ ហើយបានកាន់តំណែងនេះរហូតដល់ខែមិនា ឆ្នាំ ១៩៥៩។ មុខងារមួយក្នុងចំណោមមុខងាររបស់លោកឯកអគ្គរដ្ឋទូតត្រូតរៀម គឺការពារអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា នៅចំពោះមុខការឈ្លានពានកាន់តែច្រើនឡើងពីកំលាំងរបស់ថៃ និងវៀតណាម ដែលប្រទេសកម្ពុជាមានប្រវត្តិដំលោះទឹកដីជាមួយ យូរមកហើយ។

ទោះបីជាទំនាក់ទំនងត្រូវបានពង្រឹងរវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជាក្តី តែគោលដំហររបស់សម្តេច ព្រះនរោត្តម សីហនុក្នុងការប្រកាន់យកអព្យាក្រឹតភាពបានចាប់ផ្តើមធ្វើអោយទំនាក់ទំនងមានភាពស្មុគស្មាញ។ សម្តេច ម្តងហើយម្តងទៀតបានទោរទន់ទៅរកសាធារណរដ្ឋប្រជាមានិតចិន ដោយបានទៅធ្វើទស្សនកិច្ចនៅប្រទេសចិននិងប្រទេសកុំមុយនិស្តដទៃទៀត នៅឆ្នាំ ១៩៥៧ ដោយនៅពេលនោះសម្តេចទទួលបានជំនួយសេដ្ឋកិច្ច។ ដោយកាន់តែធ្វើអោយអ្វីៗកាន់តែអាក្រក់ទៅទៀតនៅក្នុងកាលៈទេសៈដែលមានភាពតានតឹងកាន់តែខ្លាំងឡើងជាមួយរដ្ឋាភិបាលប្រទេសថៃ និងវៀតណាមខាងត្បូង ដែលមានទំនោរទៅរកលោកខាងលិច សម្តេចសីហនុបានទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិន នៅខែកក្កដា ឆ្នាំ ១៩៥៨ ទោះបីមានការប្រឆាំងរបស់សហរដ្ឋអាមេរិកយ៉ាងណាក្តី ។ លោកឯកអគ្គរដ្ឋទូត Strom ត្រូវបានហៅត្រឡប់ទៅស្រុកវិញជាបណ្តោះអាសន្ន តែសម្តេចសីហនុ ដោយប្រឈមនឹងបរិយាកាសកាន់តែបាត់ស្ថេរភាពឡើងនៅក្នុងស្រុក បានខិតខំស្តារទំនាក់ទំនងឡើងវិញ ហើយបានទទួល យកសេចក្តីអញ្ជើញអោយធ្វើទស្សនកិច្ចនៅសហរដ្ឋអាមេរិក។

post until March 1959. One of Ambassador Strom's key positions was to protect Cambodia's sovereignty in the face of increasing aggression from Thai and Vietnamese forces, with which Cambodia had a long history of border skirmishes.

Though ties were strengthening between the United States and Cambodia, Sihanouk's position of neutrality began to complicate the relationship. The Prince had repeatedly extended a friendly hand to the People's Republic of China, visiting it and other Communist countries in 1957, during which he secured economic aid. To exacerbate matters —and amid rising tensions with the pro-western governments of Thailand and South Vietnam—Prince Sihanouk recognized the People's Republic of China in July 1958, despite American rejections. Ambassador Strom was temporarily recalled, but Prince Sihanouk,

Mr. Richard Daley, Mayor of Chicago, welcomes Prince Norodom Sihanouk. (1958)

លោក Richard Daley អភិបាលក្រុង Chicago ទទួលស្វាគមន៍ក្នុងការយាងមកដល់របស់
សម្តេចព្រះនរោត្តម ស៊ីហនុ (ឆ្នាំ ១៩៥៨)។

ដំណើរទស្សនកិច្ចរបស់ព្រះអង្គរួមមានការឈប់សំចតនៅទីក្រុង វ៉ាស៊ីនតោន ទីក្រុងញូយ៉ក Detroit Chicago និង Los Angeles ផងដែរ។ នៅពេលទៅដល់អាកាសយានដ្ឋានអន្តរជាតិក្នុងទីក្រុង Los Angeles នៅខែកញ្ញា សម្តេចបានប្រាប់អ្នកសារព័ត៌មានថា "យើងមិនបានបំភ្លេចទេថា សហរដ្ឋអាមេរិកស្ថិតក្នុងចំណោមប្រទេសដំបូងគេ ដែលបានទទួលស្គាល់ប្រទេសរបស់យើង ហើយបានផ្តល់ការគាំទ្រនិងជំនួយដល់ប្រទេសកម្ពុជា។ ចាប់តាំងពីដំហានដំបូងរបស់យើងក្នុងការទទួលបានឯករាជ្យ យើងបានបោះដំហានសំខាន់ៗខ្លះទៅមុខ... ដំណើរជឿនលឿនទៅមុខនេះត្រូវបានសំរួលដោយមិត្តភាពនិងជំនួយសប្បុរសជាប្រចាំរបស់អ្នក។ បើកម្ពុជាអាចជំនះបានលើការពិបាកដ៏ធំធេង ដែលបានជះស្រមោលទៅលើការចាប់កំណើតឡើងនៃឯករាជ្យរបស់កម្ពុជាមួយចំណែកធំគឺដោយសារសហរដ្ឋអាមេរិក។ ប្រជាជនខ្មែរដឹងពីរឿងនេះ ហើយនឹងមិនអាចភ្លេចទេ"។

ទស្សនកិច្ចរបស់សម្តេចព្រះនរោត្តមសីហនុបាននាំអោយមជ្ឈដ្ឋានអ្នកការទូត

Prince Norodom Sihanouk visits the historic Thomas Jefferson Monticello estate.

សម្តេចព្រះនរោត្តមស៊ីហនុទស្សនាវិមានប្រវត្តិសាស្ត្រ Thomas Jefferson Monticello.

facing an increasingly unstable environment at home, sought to repair relations and accepted an invitation to visit the United States. His itinerary would include stops in Washington, D.C., New York City, Detroit, Chicago, and Los Angeles. Upon arriving at Los Angeles International Airport in September, the Prince told the press: “We haven’t forgotten that the United States of America was one of the first nations to recognize our country and provide it with sympathy and aid. Since our first steps of independence, we have taken some rather significant steps forward…this progress was facilitated by your constant friendship and generous aid. If Cambodia can surmount the immense difficulties that shadow the dawn of its independence, it is due, in large part, to the United States. The Khmer people know this and will not forget it.”

The Prince’s visit caused quite a stir in diplomatic circles, particularly following the Cambodian-themed parties he organized in New York and Washington that included a traditional Khmer dance recital given by Princess Bopha Devi, Prince Chakrapong and dancers from the Royal Cambodian Ballet. The Washington Post and Times-Herald called him “the most fabulous party-giver to date”, adding that guests “raved over the décor (a Cambodian garden), the dancers and the glittery costumes.”

In Washington, as an “appreciation for all the aid your country has given mine,” Prince Sihanouk presented President Eisenhower with a 12th-century solid granite Angkorean Buddha, which still stands in the National Gallery today.

Sihanouk was also received by Secretary Dulles, to whom the Prince reiterated his commitment to maintaining Cambodia’s neutrality. Dulles reaffirmed U.S. commitment to Cambodia’s total independence.

The visit was a highpoint in bilateral relations during the 1950s, with Ambassador Strom commenting, “I was very happy when I learned that the Prince would travel to better know the U.S. and the American people. I know that the visits with President Eisenhower and Secretary Dulles were very productive. I hope that they will allow more

Prince Norodom Sihanouk hosts a dinner to honor U.S. Secretary of State John Foster Dulles and his wife at the Cambodian Embassy. (1958)

សម្តេចព្រះ នរោត្តម ស៊ីហនុរៀបចំពិធីអាហារពេលល្ងាចជាកិត្តិយសចំពោះលោករដ្ឋមន្ត្រីការបរទេសអាមេរិក John Foster Dulles និង ភរិយារបស់លោក នៅស្ថានទូតកម្ពុជា។ (ឆ្នាំ ១៩៥៨)

មានការចាប់អារម្មណ៍យ៉ាងខ្លាំង ជាពិសេស បន្ទាប់ពីពិធីជប់លៀងតាមបែបប្រទេសកម្ពុជា ដែលព្រះអង្គបានរៀបចំឡើងនៅទីក្រុងញូយ៉ក និងទីក្រុងវ៉ាស៊ីនតោន ដោយមាន របាំខ្មែរបូរាណសំដែងដោយម្ចាស់ក្សត្រីបុប្ផាទេវី ព្រះអង្គម្ចាស់ចក្រពង្ស និងអ្នករាំរបាំក្នុងក្រុមរបាំព្រះរាជ្យទ្រព្យផ្សេងៗទៀត។ កាសែត Washington Post និង Times-Herald បានហៅព្រះអង្គថា "អ្នករៀបចំពិធីជប់លៀងដ៏ល្អបំផុត នៅពេលនោះ ដោយបានបន្ថែមថាភ្ញៀវ" បានសរសើរយ៉ាងខ្លាំងចំពោះការតុបតែង អ្នករបាំ និងសំលៀកបំពាក់ដ៏ចែងចាំង"។នៅទីក្រុងវ៉ាស៊ីនតោន សម្តេចសីហនុបានប្រគល់ជូនលោកប្រធានាធិបតី Eisenhower នូវបដិមាការសម័យអង្គរ ក្នុងសតវត្សទី ១២ ធ្វើពីថ្មក្រានីត តាន់ ដោយមានព្រះបន្ទូលថា "ដើម្បីជាការដឹងគុណចំពោះជំនួយដែលប្រទេសរបស់លោកបានផ្តល់អោយប្រទេសរបស់ខ្ញុំ"។ បដិមាការនេះ ឥឡូវត្រូវបានដាក់តាំងនៅ វិចិត្រសាលជាតិ (National Gallery) ។ សម្តេចព្រះនរោត្តម សីហនុ ក៏ត្រូវបានទទួលផងដែរ ដោយលោករដ្ឋមន្ត្រីការបរទេស ឌុលលេស ដោយព្រះអង្គ

American Ambassador William Trimble, with Cambodian Head of State Prince Norodom Sihanouk, cuts the ribbon at the inauguration ceremonies of the model elementary school at Stung Treng, one of fourteen built in various provinces by American Aid.

លោកឯកអគ្គរដ្ឋទូតអាមេរិក William Trimble ជាមួយសម្តេច នរោត្តម សីហនុ ប្រមុខរដ្ឋកម្ពុជាកាត់ ខ្សែបូរក្នុងពិធីសម្ពោធសាលាបឋមសិក្សាគំរូ នៅខេត្តស្ទឹងត្រែង ដែលជាសាលាមួយក្នុងចំណោមសាលា ចំនួន ១៤ ដែលត្រូវបានសង់នៅតាមខេត្តនានា ក្រោមជំនួយ របស់អាមេរិក។

Cambodians to acquire a better understanding of the United States. I am certain that a better mutual knowledge cannot but reassure our friendly relations.”

The decade would close on a high note: On April 23, 1959, William C. Trimble presented his credentials to the Prince; he would become one of the most successful early Ambassadors to Cambodia. Plans were also initiated to build the first official Embassy building. In July, Secretary of the Interior Fred A. Seaton traveled to Cambodia to inaugurate the recently completed Khmer-American Friendship Highway. The road, now known as National Road 4, is to this day viewed as a symbol of the friendship between the United States and Cambodian governments. Markers at either end of the road bear the following words from Prince Sihanouk and President Eisenhower:

“This is a highway of friendship, built through the cooperative efforts of Americans and Khmers who have worked in a spirit of liberty and fraternity toward the goal of economic independence of this country.” – Prince Sihanouk

បានបញ្ជាក់សារជាថ្មីដល់លោករដ្ឋមន្ត្រី នូវការប្តេជ្ញាចិត្តរបស់ព្រះអង្គ ក្នុងការការពារ អព្យាក្រឹតភាពនៃប្រទេសកម្ពុជា ។ លោករដ្ឋមន្ត្រី Dulles បានបញ្ជាក់សារជាថ្មីនូវការ ប្តេជ្ញាចំពោះឯករាជ្យភាពទាំងស្រុងនៃប្រទេសកម្ពុជា។ ទស្សនកិច្ចនោះគឺជាចំណុចខ្ពស់បំផុត ក្នុងទំនាក់ទំនងទ្វេភាគីក្នុងទសវត្សទី ១៩៥0 ដោយលោកឯកអគ្គរដ្ឋទូត Strom បានមានប្រសាសន៍ថា "ខ្ញុំសប្បាយចិត្តណាស់នៅពេលខ្ញុំបានដឹងថា សម្តេចបានធ្វើដំណើរ ដើម្បីបានដឹងពីសហរដ្ឋអាមេរិក និងប្រជាជនអាមេរិកអោយបានកាន់តែច្បាស់។ ខ្ញុំដឹងថា ការជួប ជាមួយលោកប្រធានាធិបតី Eisenhower និងលោករដ្ឋមន្ត្រី Dulles មានផ្លែផ្កាច្រើន។ ខ្ញុំសង្ឃឹមថាវានឹងធ្វើអោយជនជាតិខ្មែរមានការយល់ដឹងកាន់តែច្បាស់ពីសហរដ្ឋអាមេរិក។ ខ្ញុំមានការប្រាកដក្នុងចិត្តថាការយល់គ្នាទៅវិញទៅមកបានល្អពិតជាធានាដល់ទំនាក់ទំនងមិត្តភាពរបស់យើង"។

ទសវត្សនោះចប់ទៅប្រកបដោយភាពប្រសើរ។ នៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ ១៩៥៩ លោក William C. Trimble បានថ្វាយសារតាំងជូនសម្តេច ព្រះនរោត្តម សីហនុ ហើយលោកគឺជាឯកអគ្គរដ្ឋទូតម្នាក់ក្នុងចំណោមឯកអគ្គរដ្ឋទូតដែលមានជោគជ័យជាងគេនៅប្រទេសកម្ពុជា ក្នុងពេលដំបូងៗ។ ផែនការសំរាប់អោយមានអាគារស្ថានទូតជាផ្លូវការត្រូវបានផ្តួចផ្តើមឡើង។ នៅខែកក្កដា លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃសហរដ្ឋអាមេរិក Fred A. Seaton បានធ្វើដំណើរមកប្រទេសកម្ពុជាដើម្បីសម្ពោធផ្លូវមិត្ត ភាពកម្ពុជា អាមេរិក ដែលទើបតែសង់ហើយថ្មីៗនៅពេលនោះ។ ផ្លូវនោះ ដែលគេច្រើនស្គាល់ថា ជាផ្លូវជាតិលេខ ៤ រហូតមកដល់ពេលនេះត្រូវបានគេចាត់ទុកថា ជានិមិត្តរូបនៃចំណងមិត្តភាព រវាងរដ្ឋាភិបាលអាមេរិក និងរដ្ឋាភិបាលកម្ពុជា។ ស្លាកសំគាល់នៅចុងទាំងសងខាងនៃផ្លូវនោះ មានចារឹក ព្រះបន្ទូលរបស់សម្តេច ព្រះនរោត្តមសីហនុនិងប្រសាសន៍របស់ លោក ប្រធានាធិបតី Eisenhower ដែលមានន័យ ដូចខាងក្រោមនេះ:

សម្តេចសីហនុ: "នេះគឺជាផ្លូវ មិត្តភាព ដែលត្រូវបានកសាង ឡើងតាមរយៈការខិតខំ សហប្រតិបត្តិការគ្នា រវាងអាមេរិកនិងកម្ពុជា ដែលបានធ្វើការក្នុងស្មារតីសេរីភាព និងភាតរៈភាពដើម្បីសំរេចបំណងឯករាជ្យសេដ្ឋកិច្ចនៃប្រទេសនេះ"។

លោកប្រធានាធិបតី Eisenhower: "ផ្លូវនេះ ដែលកសាងឡើងដោយការខិតខំរួមគ្នារបស់ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក គឺជានិមិត្តរូបនៃមិត្តភាពរបស់ប្រជាជននៃ

"This highway, built by joint efforts of Cambodian and the United States of America, is the symbol of the friendship of the peoples of our two countries, and of our mutual desire for a free, independent prosperous Cambodia." – President Eisenhower

Speaking in 1961 and looking back on a decade of cooperation, Ambassador Trimble said, "It was a decade of remarkable achievement. … In these 10 years, this ancient yet modern nation has been laying the foundations essential for continued progress and prosperity. The Cambodian people are vigorously engaged in strengthening and extending these foundations, in an atmosphere of liberty and security."

ប្រទេសយើងទាំងពីរ និងបំណងប្រាថ្នារួមគ្នារបស់យើង ដែលចង់អោយប្រទេសកម្ពុជាក្លាយជាប្រទេសមានសេរីភាព ឯករាជ្យ និងវិបុលភាព"។

នៅពេលថ្លែងក្នុងឆ្នាំ ១៩៦១ និងក្រលេកមើលទៅទសវត្សនៃសហប្រតិបត្តិការគ្នាកន្លងទៅនោះ លោកឯកអគ្គរដ្ឋទូត Trimble បានមានប្រសាសន៍ថា "វាជាទសវត្សនៃជោគជ័យដ៏គួរអោយកត់សំគាល់... ក្នុងរយៈពេល ១០ ឆ្នាំនេះ ប្រជាជាតិដ៏ចំណាស់តែមានភាពទំនើបនេះបានចាក់មូលដ្ឋានគ្រឹះចាំបាច់សំរាប់អោយមានភាពជឿនលឿន និងវិបុលភាពជាបន្តទៀត។ ប្រជាជនកម្ពុជាចូលរួមយ៉ាងខ្លាំងក្លា ក្នុងការពង្រឹង និងពង្រីកមូលដ្ឋានគ្រឹះទាំងនេះ ក្នុងបរិយាកាសនៃសេរីភាព និងសន្តិសុខ"។

Prince Norodom Sihanouk, U.S. Secretary of Interior Fred Seaton, and Ambassador Trimble inaugurated the U.S. – Cambodian Friendship road linking Phnom Penh with Sihanoukville on July 22, 1959.

សម្តេចព្រះនរោត្តមសីហនុ លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាមេរិក Fred Seaton ហើយនិងឯកអគ្គរដ្ឋទូត Trimble សម្ពោធផ្លូវមិត្តភាពកម្ពុជា-អាមេរិក ដែលភ្ជាប់ទីក្រុងភ្នំពេញ ទៅក្រុងព្រះសីហនុ នៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ១៩៥៩។

President Eisenhower and Prince Norodom Sihanouk

លោកប្រធានាធិបតី Eisenhower និង សម្តេចព្រះនរោត្តមសីហនុ

Jacqueline Kennedy visits Cambodia in 1967.

លោកជំទាវ Jacqueline Kennedy បានធ្វើទស្សនកិច្ច
នៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៦៧

1960s

- The Golden olden Era of Khmer film, music, and architecture
- 1962: Cambodia wins Preah Vihear case, represented by Dean Acheson
- 1962, 1965 and 1969: Senator Mike Mansfield visits Cambodia
- 1965: Bilateral relations severed between the United States and Cambodia
- 1967: Jacqueline Kennedy visits Cambodia
- 1969: The United States begins secret bombings in eastern Cambodia
- 1969: Relations restored

- សម័យរុងរឿងនៃភាពយន្ត តន្ត្រី និងស្ថាបត្យកម្ម
- ឆ្នាំ ១៩៦២: ប្រទេសកម្ពុជាបានឈ្នះក្តីប្រាសាទព្រះវិហារ ដោយមានលោក Dean Acheson ធ្វើជាតំណាង
- ឆ្នាំ ១៩៦២ ១៩៦៥ និង ១៩៦៩: លោក Mike Mansfield ព្រឹទ្ធសមាជិកសភាអាមេរិក ធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា
- ឆ្នាំ ១៩៦៥: ទំនាក់ទំនងទ្វេភាគីរវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជាបានត្រូវកាត់ផ្តាច់
- ឆ្នាំ ១៩៦៧: លោកជំទាវ Jacqueline Kennedy បានធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា
- ឆ្នាំ ១៩៦៩: សហរដ្ឋអាមេរិកបានចាប់ផ្តើមការទំលាក់គ្រាប់បែកដោយសំងាត់ នៅភាគខាងកើតនៃប្រទេសកម្ពុជា
- ឆ្នាំ ១៩៦៩: ទំនាក់ទំនងត្រូវបានស្តារឡើងវិញ

The 1960s would be a tumultuous decade in Indochina, with the United States deepening its involvement in Vietnam and the civil war in Laos intensifying. U.S. policies and positions were defined largely by the Cold War, which meant, in regional terms, that containing Chinese influence and securing victory against the North Vietnamese were key priorities.

The United States had allied itself with the anti-Communist governments of Thailand and South Vietnam, and hoped to play a role in improving relations between Cambodia and its neighbors to the east and west. Prince and Head of State Norodom Sihanouk, though, remained firmly committed to maintaining Cambodia's neutrality, with a primary objective of avoiding entanglement in the war in Vietnam. The Prince also feared the consequences of a unified Vietnam for his country.

Determined to uphold Cambodia's territorial integrity and suspicious of Thai and South Vietnamese intentions, Sihanouk continued to cultivate ties with superpowers on both ends of the ideological spectrum, despite

Ambassador Dodson Sprouse presented his credentials to H.R.H Prince Norodom Sihanouk, head of state on August, 20, 1962.

លោកឯកអគ្គរដ្ឋទូត Dodson Sprouse បានថ្វាយសារតាំងដល់ព្រះករុណា ព្រះបាទនរោត្តមសីហនុ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៦២

សម័យទសវត្សទី ១៩៦0 គឺជារយៈពេលប្រកបដោយការរំជើបរំជួល នៅឥណ្ឌូចិន ដោយសហរដ្ឋអាមេរិកមានការពាក់ព័ន្ធកាន់តែជ្រៅនៅប្រទេសវៀតណាម ហើយសង្គ្រាមស៊ីវិលនៅប្រទេសឡាវមានការរីករាលដាលកាន់តែខ្លាំងឡើង។ គោលនយោបាយ និងគោលជំហររបស់សហរដ្ឋអាមេរិក ជាទូទៅត្រូវបានកំណត់ដោយសង្គ្រាមត្រជាក់ ដែលសំរាប់តំបន់នេះ មានន័យថា ការទប់ទល់បានចំពោះឥទ្ធិពលរបស់ចិន និងការធានាអោយបាននូវជ័យជំនះលើវៀតណាមខាងជើង គឺជាអាទិភាពសំខាន់។

សហរដ្ឋអាមេរិកបានចងសម្ព័ន្ធមិត្តជាមួយនឹងរដ្ឋាភិបាលប្រឆាំងនឹងកុំម្មុនិស្ត នៅប្រទេសថៃ និងវៀតណាមខាងត្បូង ហើយសង្ឃឹមថានឹងដើរតួនាទីមួយក្នុងការកែលំអទំនាក់ទំនងរវាងប្រទេសកម្ពុជា និង ប្រទេសជិតខាងកម្ពុជា នៅភាគខាងកើត និងខាងលិច។ សម្តេចព្រះរោត្តម សីហនុ ដែលជាប្រមុខរដ្ឋនៅពេលនោះ នៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការការពារអព្យាក្រិត្យភាពនៃប្រទេសកម្ពុជាដោយមានគោលបំណងសំខាន់គឺជៀសវាងការពាក់ព័ន្ធក្នុងសង្គ្រាមវៀតណាម។ ព្រះអង្គថែមទាំងមានការភ័យខ្លាចចំពោះផលវិបាកសំរាប់ប្រទេសរបស់ព្រះអង្គ ដែលបណ្តាលមកពីការរួបរួមគ្នានៃប្រទេសវៀតណាម។

ដោយមានការតាំងចិត្តក្នុងការការពារអធិបតេយ្យភាពទឹកដីនៃប្រទេសកម្ពុជា និងដោយមានការសង្ស័យចំពោះចេតនារបស់ប្រទេសថៃ និងប្រទេសវៀតណាមខាងត្បូង សម្តេចព្រះនរោត្តមសីហនុ បានបន្តការទាក់ទងជាមួយប្រទេសមហាអំណាចនៃមនោគមវិជ្ជាទាំងពីរ ទោះបីជាជា សហរដ្ឋអាមេរិកកំពុងតែជួយដល់ទៅ ១ ភាគ៣ នៃថវិការយោធារបស់កម្ពុជាយ៉ាងណាក្តី។ សម្តេចបានបញ្ជាក់យ៉ាងច្បាស់ថាព្រះអង្គចាត់ទុកផលប្រយោជន៍ និងអត្តសញ្ញាណនៃប្រទេសកម្ពុជាធំជាងអ្វីៗទាំងអស់។

តាមទស្សនៈរបស់សហរដ្ឋអាមេរិក ជំហរនេះអាចទទួលយកបាន ដរាបណារដ្ឋាភិបាលកម្ពុជាពិតជានៅអព្យាក្រិត្យ ហើយជាផ្លូវការមិនលំអៀងទៅខាងប្រទេសចិន ការបង្ក្រាបរបស់ព្រះអង្គទៅលើពួកឆ្វេងនិយម នៅប្រទេសកម្ពុជាឬពួកខ្មែរក្រហមតាមដែលសម្តេចបានហៅ ធ្វើអោយសហរដ្ឋអាមេរិកមានការជឿជាក់។ ទោះបីមានការប្រឆាំងខ្លះចំពោះរដ្ឋាភិបាលរបស់ទ្រង់ក្តី ក៏ជាទូទៅ សម្តេចព្រះនរោត្តមសីហនុគឺជាអ្នកដឹកនាំម្នាក់ដែលមានប្រជាប្រិយភាពនៅទសវត្សនោះ ដោយមានការគាំទ្រយ៉ាងពេញទំហឹងដោយយោធា។

ប៉ុន្តានទសវត្សក្រោយមក នៅពេលនិយាយពីការប្រែប្រួលឥរិយាបទរបស់

the fact that by now the United States supported a third of the country's military budget. The Prince made it clear that he would prioritize Cambodian interests and national identity over all other agendas.

From the U.S. point of view, this was acceptable as long as the Cambodian government did indeed remain neutral and did not officially side with the Chinese; Sihanouk's crackdown on leftists in Cambodia—or, as he called them, the Khmer Rouge—was reassuring to the United States. Though there was some opposition to his government, during much of the decade Sihanouk was a popular leader who was fully backed by the military.

(From left to right) U.S. Ambassador to the U.N., Adlai Stevenson; Prince Norodom Sihanouk; President John F. Kennedy; Nhiek Tioulong,Cambodian Foriegn Minister; and John M. Steeve, U.S. Assistant Secretary of State for Far Eastern Affairs.

(ពីឆ្វេងទៅស្តាំ) លោក Adlai Stevenson ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅអង្គការសហប្រជាជាតិ សម្តេចព្រះនរោត្តមសីហនុ លោកប្រធានាធិបតី John F. Kennedy លោកញ៉ីត ជ្លូង រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា និង លោក John M. Steeve ជំនួយការរដ្ឋមន្ត្រីក្រសួងការបរទេស សំរាប់តំបន់ចុងបូព៌ា។

ព្រះអង្គចំពោះសហរដ្ឋអាមេរិកលោក C. Robert Moore អនុប្រធានបេសកកម្មទូតសហរដ្ឋអាមេរិកនៅកម្ពុជា ពីឆ្នាំ ១៩៥៩ដល់ឆ្នាំ ១៩៦២ បានមានប្រសាសន៍ថា "វ៉ាគីជារបបដែលមានពណ៌ច្រើន។ គេត្រូវដឹងថា ឥរិយាបទរបស់សម្តេចចំពោះយើងមានការប្រែប្រួលរាល់ថ្ងៃ ពីព្រោះព្រះអង្គជឿជាក់ថា អាមេរិកមាននយោបាយពីរ។ មួយគឺជានយោបាយរបស់ស្ថានទូត និងមួយទៀតគឺជានយោបាយរបស់សេអ៊ីអា។

ទំនាក់ទំនងទ្វេភាគីនៅពាក់កណ្តាលដំបូងនៃទសវត្ស ជាទូទៅ គឺមានលក្ខណៈវិជ្ជមាន ដោយសហរដ្ឋអាមេរិកបានផ្តល់ជំនួយប្រហែល ២០ លានដុល្លា ក្នុងមួយឆ្នាំ។ ទំនាក់ទំនងរឹតតែមានភាពប្រសើរថែមទៀត ជាមួយលោកប្រធានាធិបតី John F. Kennedy ដែលបានយល់ព្រមបញ្ជូនយន្តហោះ បណ្តុះណ្តាលធុន ទ-37 ចំនួនបួនគ្រឿងមកប្រទេសកម្ពុជា នៅពេលលោកចូលកាន់តំណែងបានបន្តិច ដែលនោះជាសំណើមួយ ដែលសម្តេចព្រះនរោត្តម សីហនុ បានស្នើសុំដល់រដ្ឋបាលលោកប្រធានាធិបតី Eisenhower នៅរដូវស្លឹកឈើជ្រុះនៃឆ្នាំ ១៩៦១ ក្នុងពេលដែលកំពុងតែចូលរួមប្រជុំនៅក្នុងមហាសន្និបាតនៃអង្គការសហប្រជាជាតិក្នុងទីក្រុងញូយ៉ក លោកប្រធានាធិបតី Kennedy បានអញ្ជើញសម្តេចមកកាន់សេតវិមាន។ក្នុងការប្រជុំរយៈពេល ៩0 នាទីនោះ មេដឹកនាំទាំងពីរបានពិភាក្សាគ្នាពីកិច្ចការបច្ចុប្បន្ន នៅអាស៊ីអាគ្នេយ៍ ដោយផ្តោតសំខាន់លើប្រទេសឡាវ និងប្រទេសវៀតណាម។ បើយោងតាមអត្ថបទមួយរបស់កាសែត The New York Times សម្តេចមានអារម្មណ៍ថា "មានការផ្លាស់ប្តូរទស្សនៈគ្នាពេញលេញ" និងថាការពិភាក្សានោះ "គួរជាទីពេញចិត្តយ៉ាងខ្លាំង"។

ដោយមានការភ័យខ្លាចចំពោះស្ថានការនៅប្រទេសឡាវដែលនៅទីនោះ ពួកកុំម្យុយនិស្ត Pathet Lao កំពុងតែមានប្រៀប ហើយវៀតណាមខាងជើងកំពុងតែបញ្ជូនទាហាននិងគ្រឿងផ្គត់ផ្គង់មកភាគខាងត្បូង តាមអ្វីដែលគេហៅថាផ្លូវលំ ហូជីមុិញ នោះ សម្តេចព្រះនរោត្តមសីហនុ បានអំពាវនាវអោយធ្វើការកោះប្រជុំសន្និសីទក្រុងហ្ស៊ីណេវ ដោយព្រះអង្គសង្ឃឹមថា សន្និសីទនោះនឹងដោះស្រាយស្ថានភាពនោះ។ សម្តេចមានការភ័យខ្លាចចំពោះផលអាក្រក់មកលើឯករាជ្យភាព ស្មេរភាព និងបូរណភាពទឹកដីនៃប្រទេសកម្ពុជា បើសិនជាប្រទេសឡាវធ្លាក់ទៅក្នុងដៃរបស់ពួកកុំម្យុយនិស្ត។ សហរដ្ឋអាមេរិក រួមជាមួយនឹងប្រទេសចំនួន ១៤ផ្សេងទៀត ដែលរួមទាំងប្រទេសចិន សហភាពសូវៀត បារាំងនិងអង់គ្លេស ផងនោះ បានចូលរួមក្នុងការពិភាក្សានៅឆ្នាំ ១៩៦១ ។ មួយឆ្នាំក្រោយមក ការចរចាបានឈានដល់ការ

Decades later, commenting on Sihanouk's shifting attitudes toward the United States, C. Robert Moore, the Deputy Chief of Mission in Cambodia from 1959 to 1962, said: "It was a colorful regime. One had to get used to daily changes in the attitude of the Prince towards us, because he was convinced that there were two American policies. One was that of the Embassy and the other was that of the CIA.

Bilateral relations during the first part of the decade were largely positive, with U.S. assistance peaking at roughly $20 million per year. Ties improved further with President John F. Kennedy, who agreed to send four T-37 jet-trainer planes to Cambodia early in his presidency, a request that Prince Sihanouk had registered under the Eisenhower Administration. In the fall of 1961, while Sihanouk attended a meeting of the United Nations General Assembly in New York, President Kennedy invited him to the White House. During the 90-minute meeting, the leaders discussed current affairs in Southeast Asia, focusing on problems in Laos and Vietnam. Sihanouk felt there had been a "complete exchange of views" and that the talk had been "very satisfactory," according to an article about the meeting in The New York Times.

Unnerved by the state of affairs in Laos, where the Pathet Lao Communists were gaining the upper hand and the North Vietnamese were sending soldiers and supplies southward along what would become known as the Ho Chi Minh Trail, Prince Sihanouk called for a Geneva conference that he hoped would resolve the situation. The Prince feared for Cambodia's independence, stability, and territorial integrity, should Laos succumb to the communists. The United States, along with 14 other nations including China, the Soviet Union, France, and Britain, attended the talks in 1961. A year later, the negotiations led to accords that called for a peaceful, neutral, independent, and democratic Laos. By that point, however, little could be done to turn the nation back towards democracy.

Temperatures rose even higher with the escalation in early 1962 of the conflict in Vietnam. Concerned about hostilities spilling over into its

ព្រៀមព្រៀងគ្នា ដែលអំពាវនាវអោយប្រទេសឡាវជាប្រទេសមានសន្តិភាព អព្យាក្រិត្យភាព ឯករាជ្យ និងប្រជាធិបតេយ្យ។ តែនៅត្រឹមនោះគេមិនអាចធ្វើអ្វីកើត ដើម្បីប្រែក្លាយប្រទេសនេះអោយទៅជាប្រទេសដែលប្រកាន់ តាមលទ្ធិប្រជាធិបតេយ្យ បានឡើយ។

កំដៅមានកំណើនកាន់តែខ្លាំង នៅដើមឆ្នាំ១៩៦២ នៅពេលដែលសង្គ្រាមនៅ វៀតណាមកំពុងតែមាន សន្ទុះខ្លាំង។ ដោយមានកង្វល់ថា សង្គ្រាមនេះនឹងរាលដាលដល់ ខ្លួន ប្រទេសកម្ពុជាបានខិតខំពង្រីក កងទ័ពបាន ១០%។ សម្តេចសីហនុបានងាកទៅរក សហរដ្ឋអាមេរិកដើម្បីរកជំនួយបន្ថែម ដោយសង្ឃឹមថាកងទ័ពកម្ពុជាអាចបញ្ឈប់ការ ជ្រៀតចូលរបស់ពួកវៀតកុងមកក្នុងទឹកដីកម្ពុជា ។ សហរដ្ឋអាមេរិក បានគាំទ្រការ ពង្រីកកងទ័ពរបស់កម្ពុជា។

នៅពេលដែលការប្រយុទ្ធគ្នានៅវៀតណាមខាងត្បូងកាន់តែមានសភាពខ្លាំង ឡើង ការវាយប្រហារមកលើភូមិដ្ឋាននានានៅក្នុងប្រទេសកម្ពុជា ក៏មានកាន់តែច្រើន ឡើងផងដែរ។ វៀតណាមភាគខាងត្បូង លើកហេតុផលថា ពួកគេចូលមកនោះដើម្បី តាមរកកងទ័ពវៀតកុងដែលត្រូវបានគេជឿថាកំពុងតែលាក់ខ្លួន តាមព្រំដែន។

ជំលោះរវាងប្រទេសថៃនិងប្រទេសកម្ពុជាស្តីពីប្រាសាទព្រះវិហារគឺជាការ

H.E.M. Son San greets Mr. Dean Acheson, the eminent American attorney who represented Cambodia in the Preah Vihear dispute before the International Court at The Hague.

ឯកឧត្តម សឺនសាន ទទួលស្វាគមន៍លោក Dean Acheson ដែលជាមេធាវីអាមេរិក ហើយជាតំណាង អោយប្រទេសកម្ពុជា ក្នុងជំលោះប្រាសាទព្រះវិហារ នៅតុលាការអន្តរជាតិ នៅទីក្រុង The Hague។

borders, Cambodia sought to increase its armed forces by 10 %. Sihanouk turned to the United States for additional assistance, hoping that Cambodian forces would be able to stop the Viet Cong from infiltrating Cambodian land. The United States supported this expansion of the Cambodian military.

As the fighting in South Vietnam worsened, attacks on Cambodian villages became increasingly common. The South Vietnamese justified these incursions as missions to target Viet Cong troops, which were believed to be hiding out across the border.

The dispute between Thailand and Cambodia over the temple of Preah Vihear served as another source of regional tension. The 11th-century architectural masterpiece was located on disputed territory along the Thai-Cambodian border, which the Thais had controlled since 1954. The case was heard in 1962 at the International Court of Justice in The Hague, with Dean Acheson, former Secretary of State during the Truman Administration, representing the Cambodian side.

Though it was widely believed that Thailand would win the case, the court decided in favor of Cambodia. Prince Sihanouk proclaimed a seven-day national holiday and the country erupted into mass celebration. The Thais refused to accept the ruling and boycotted international meetings. The United States did its part to defuse the situation. The crisis became one of the first issues that the newly appointed U.S. Ambassador to Cambodia, Philip D. Sprouse, would manage. Ambassador Sprouse presented his credentials in August 1962.

The Preah Vihear victory was one of many sources of national pride to emerge in 1960s Cambodia; others included prolific creativity in the areas of film, music, and architecture. Artists like Sinn Sisamouth and Ros Serey Sothea,singers who forged an unforgettable blend of Khmer sounds with rock ‘n’ roll, and Van Molyvann, the father of the modernist New Khmer Architecture style, helped make Phnom Penh one of Southeast Asia’s most attractive, culturally rich capitals.



Mr. Dean Acheson, American ex-Secretary of State, and Mrs. Dean Acheson arrived in Cambodia on 14th January for a short visit. In the course of his stay, Mr. Dean Acheson was invited to several receptions, including, a dinner given in his honour by Prince Norodom Sihanouk, Head of State.

បង្ហាញមួយទៀតនៃភាពតានតឹងនៅក្នុងតំបន់។ ប្រាសាទដែលស្នាដៃឯកផ្នែកស្ថាបត្យកម្មពីសតវត្សទី១១ មកនេះ ស្ថិតនៅលើទឹកដី មានជំលោះតាមបណ្តាយព្រំដែនកម្ពុជា ថៃដែលប្រទេសថៃបានកាន់កាប់តាំងពីឆ្នាំ ១៩៥៤ មក។ ក្តីក្តាំនេះបានឡើងដល់តុលាការក្រុងឡាអេ ដោយមានលោក Dean Acheson អតីតរដ្ឋមន្ត្រីការបរទេសអាមេរិកក្នុង សម័យរដ្ឋបាលលោកប្រធានាធិបតីអាមេរិក Truman ធ្វើជាតំណាងអោយភាគីកម្ពុជា។

ទ្ចីបើជាទូទៅ គេជឿជាមុនថា ប្រទេសថៃនឹងឈ្នះក្តីនោះ តែតុលាការបានសំរេចអោយកម្ពុជាឈ្នះទៅវិញ។ សម្តេចព្រះនរោត្តម សីហនុបានប្រកាសការឈប់សំរាកការងារ រយៈពេល ៧ ថ្ងៃ ហើយនៅទូទាំងប្រទេស មានការអបអរយ៉ាងខ្លាំង។ ថៃមិនព្រមទទួលយកសាលក្រមនោះទេ ហើយបានធ្វើពហិការ មិនចូលរួមក្នុងកិច្ចប្រជុំអន្តរជាតិនានា។ សហរដ្ឋអាមេរិកបានរួមចំណែកក្នុងការកាត់ បន្ថយស្ថានភាពតានតឹង។ វិបត្តិនេះបាន ក្លាយជាបញ្ហាមួយក្នុងចំណោមបញ្ហាដំបូង។ ដែលឯកអគ្គរដ្ឋទូតថ្មីរបស់សហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា លោក Philip D. Sprouse ត្រូវដោះស្រាយ។ លោកឯកអគ្គរដ្ឋទូត Sprouse បានថ្វាយសារតាំង នៅខែសីហា ឆ្នាំ ១៩៦២។

Montana Senator Mike Mansfield offers a bouquet of flowers to Princess Bopha Devi and Prince Sihamoni. The senator and his wife visited Cambodia in 1969.

ព្រឹទ្ធសមាជិក Mike Mansfield មកពីរដ្ឋ Montana ថ្វាយបាច់ផ្កាជូនម្ចាស់ក្សត្រីបុប្ផាទេវី និងព្រះអង្គម្ចាស់ សីហមុនី។ លោកព្រឹទ្ធសមាជិក និងភរិយារបស់លោក បានធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា នៅឆ្នាំ ១៩៦៩។

By this time, the U.S. stance towards Cambodia had become divided into two camps: those who believed Sihanouk was aligning himself with the Communists and those who felt it was in the U.S. interest not to isolate Cambodia. A vocal proponent of the latter perspective was Senator Mike Mansfield, who visited Cambodia in late 1962 along with three other senators. An Asia expert who would later become the longest serving U.S. Ambassador to Japan, Senator Mansfield personally advised Presidents Kennedy, Johnson, and Nixon during the 1960s and 1970s on U.S. military involvement in the Vietnam War, which he opposed.

The trip to Cambodia made a favorable impression on the Senator, who left the country believing that the United States and Cambodia could find common ground. Throughout the decade, Mansfield would continue to cultivate a fruitful relationship with Prince Sihanouk that

ដោគជ័យក្នុងរឿងប្រាសាទព្រះវិហារគឺជាប្រភពមួយក្នុងចំណោមប្រភពជាច្រើននៃមោទនភាពជាតិ នៅប្រទេសកម្ពុជា នៅក្នុងទសវត្សទី ១៩៦0 ។ មោទនភាពដទៃទៀតមានដូចជាស្នាដៃជាច្រើនផ្នែកភាពយន្ត តន្ត្រី និងស្ថាបត្យកម្ម។ សិល្បករដូចជាលោក ស៊ីន ស៊ីសាមុត និងលោកស្រី រស់ សេរីសុទ្ធា ដែលជាអ្នកចំរៀងដែលធ្វើអោយគេមិនអាចបំភ្លេចបាន នូវសំលេងខ្មែរជាមួយភ្លេងរ៉ុក លោក វណ្ណ ម៉ូលីវណ្ណ ដែលជាបិតានៃស្ថាបត្យកម្មខ្មែរថ្មី សម័យទំនើប បានជួយធ្វើអោយទីក្រុងភ្នំពេញ ក្លាយជារាជធានីមួយក្នុងចំណោម រាជធានីដ៏ស្រស់ស្អាត និងមានលក្ខណៈសំបូរបែបបំផុតជាងគេផ្នែកវប្ធធម៌ នៅអាស៊ីអាគ្នេយ៍។

មកដល់ពេលនោះ ជំហររបស់សហរដ្ឋអាមេរិកចំពោះ ប្រទេសកម្ពុជាត្រូវបានបែងចែកទៅជាពីរក្រុម ដោយមួយក្រុមជឿថា សម្តេចភ្ជាប់ព្រះកាយជាមួយពួកកុំម្មុយនិស្ត ហើយមួយក្រុមទៀតគិតថាដើម្បីផលប្រយោជនរបស់សហរដ្ឋអាមេរិក គេមិនត្រូវធ្វើអោយប្រទេសកម្ពុជាស្ថិតនៅឯកកោទេ។ អ្នកដែលគាំទ្រខ្លាំង ចំពោះគោលជំហរ ២ នេះគឺលោក ព្រឹទ្ធសមាជិកសភាអាមេរិក Mike Mansfield ដែលបានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា នៅចុងឆ្នាំ ១៩៦២ ជាមួយនឹងព្រឹទ្ធសមាជិកសភា ៣ នាក់ទៀត។ លោក Mansfield អ្នកជំនាញការស្តីពីអាស៊ី ដែលក្រោយមកបានក្លាយជាឯកអគ្គរដ្ឋទូតយូរជាងគេរបស់សហរដ្ឋអាមេរិកប្រចាំនៅប្រទេសជប៉ុន លោក បានធ្វើការផ្តល់យោបល់ដោយផ្ទាល់ ទៅលោកប្រធានាធិបតី Kennedy Johnson និងប្រធានាធិបតី Nixon ក្នុងអំឡុងទសវត្សទី ១៩៦0 និង ១៩៧0 ស្តីពីការពាក់ព័ន្ធផ្នែកយោធារបស់សហរដ្ឋអាមេរិកក្នុងសង្គ្រាមវៀតណាម ដែលលោកបានប្រឆាំង។

លោកព្រឹទ្ធសមាជិក Mansfield មានការចាប់អារម្មណ៍ល្អ នៅពេលលោកមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយលោកបានចាកចេញទៅវិញដោយជឿថាសហរដ្ឋអាមេរិក និងកម្ពុជាអាចមានការព្រមព្រៀងគ្នា។ ក្នុងអំឡុងទសវត្សនោះទាំងមូល លោក Mansfield បានបន្តធ្វើអោយមានទំនាក់ទំនងល្អជាមួយសម្តេចព្រះនរោត្តម សីហនុ ដែលអាចពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរបាន។

ដោយមិនបានចូលរួមក្នុងសន្ធិសីទអន្តរជាតិដែលស្នើឡើងដោយសម្តេចសហរដ្ឋអាមេរិកចង់បានលិខិតពីប្រទេសនិមួយៗ ដែលសន្យាគោរពបូរណភាពទឹកដីនិងអព្យាក្រិត្យភាពនៃប្រទេសកម្ពុជា។ ដើម្បីបង្ហាញបន្ថែមនូវការគាំទ្ររបស់សហរដ្ឋអាមេរិក លោកប្រធានា ធិបតី Kennedy បានថ្វាយ សម្តេចសីហនុ នូវលិខិតមួយច្បាប់ ដោយបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តរបស់លោកចំពោះសន្តិសុខនៃប្រទេស

would strengthen ties between the two countries.

Rather than participate in an international conference the Prince proposed earlier in the decade, the United States preferred draft notes from individual countries that pledged to respect Cambodia's territorial integrity and neutrality. To further illustrate U.S. support, President Kennedy sent Sihanouk a letter reiterating his commitment to Cambodia's security.

Sihanouk persisted with his desire for an international guarantee; the United States countered that bilateral agreements with Cambodia's neighbors and allies was a better solution. Meanwhile, as relations with the United States became tense, Prince Sihanouk headed to Beijing, where he hoped to procure additional economic and military aid.

As events in Vietnam took a turn for the worse—June 1963 would see the first Vietnamese monk burn himself to death to protest the authoritarian regime of South Vietnam's President Ngo Dinh Diem—Sihanouk continued to voice concern over attacks on Cambodian territory. In August, after an assault on a Cambodian guard post, he broke diplomatic relations with Diem. A few days later, the Soviet Union sent four aircraft and 24 anti-aircraft guns to Cambodia, marking the first non-Western military aid to the country. Relations between the United States and Cambodia continued to fray.

Despite direct assurances from President Kennedy that the United States supported Cambodia's neutrality and did not back the dissidents, Prince Sihanouk called for the immediate termination of U.S. aid, which was now the equivalent to roughly 15% of Cambodian budget. He hoped the move would save his country from becoming embroiled in the Vietnam War and strengthen relations with the communist bloc.

To salvage the situation, President Kennedy planned to send former Secretary of State Dean Acheson to Cambodia. But Acheson would never make the visit; on November 22, the President was assassinated.

កម្ពុជា។ សម្តេចព្រះនរោត្តមសីហនុនៅតែទទួចចង់បានការធានាជាអន្តរជាតិមួយ។ សហរដ្ឋអាមេរិកបានឆ្លើយតបវិញថាកិច្ចព្រមព្រៀងទ្វេភាគីជាមួយសម្ព័ន្ធមិត្តនិងប្រទេសជិតខាងរបស់ប្រទេសកម្ពុជា គឺជាដំណោះស្រាយប្រសើរជាង។ ទន្ទឹមនឹងនោះ នៅពេលទំនាក់ទំនងជាមួយសហរដ្ឋអាមេរិកមានភាពតានតឹងសម្តេចសីហនុបានធ្វើដំណើរទៅប្រទេសចិនដើម្បីសុំជំនួយបន្ថែម ផ្នែកយោធា និងសេដ្ឋកិច្ច។

នៅពេលដែលស្ថានការណ៍នៅក្នុងប្រទេសវៀតណាមកាន់តែដុនដាប ដោយនៅខែមិថុនា ឆ្នាំ ១៩៦៣ មានព្រះសង្ឆវៀតណាមទី ១ បានដុតព្រះកាយអោយស្លាប់ ដើម្បីតវ៉ាប្រឆាំងនឹងរបបផ្តាច់ការរបស់ប្រធានាធិបតីវៀតណាមខាងត្បូង Ngo Dinh Diem សម្តេចសីហនុបានបន្តសំដែងការព្រួយបារម្ភចំពោះការវាយប្រហារមកលើទឹកដីនៃប្រទេសកម្ពុជា។ នៅខែសីហា បន្ទាប់ពីមានការវាយប្រហារមកលើប៉ុស្ត៍យាមមួយរបស់កម្ពុជា សម្តេចបានផ្តាច់ទំនាក់ទំនងការទូតជាមួយប្រធានាធិបតី Diem ។ ប៉ុន្មានថ្ងៃក្រោយមក សហភាពសូវៀតបានបញ្ជូនយន្តហោះចំនួន ៤ គ្រឿង និងកាំភ្លើងប្រឆាំងយន្តហោះចំនួន ២៤ ដើម មកអោយកម្ពុជា ដែលនោះគឺជាជំនួយលើកដំបូងមកពីប្រទេសដែលមិនមែនជាប្រទេសលោកខាងលិច មកកាន់ ប្រទេសកម្ពុជា។ ទំនាក់ទំនងរវាងសហរដ្ឋអាមេរិកនិងកម្ពុជាបានបន្តរសាត់។

ទោះបីមានការធានាអះអាងដោយផ្ទាល់ពីលោកប្រធានាធិបតី Kennedy ថាសហរដ្ឋអាមេរិកគាំទ្រអព្យាក្រឹត្យភាពនៃប្រទេសកម្ពុជា ហើយមិនគាំទ្រពួកប្រឆាំងក្តី តែព្រះអង្គនៅតែអំពាវនាវអោយមានការបញ្ចប់ជាបន្ទាន់នូវជំនួយរបស់អាមេរិក ដែលមានតំលៃប្រហែលនឹង ១៥% នៃថវិកាជាតិកម្ពុជា។ ព្រះអង្គសង្ឃឹមថា ការធ្វើដូច្នេះនឹងជួយអោយប្រទេសរបស់ព្រះអង្គមិនមានការពាក់ព័ន្ធក្នុងសង្គ្រាមវៀតណាម ហើយពង្រឹងទំនាក់ទំនងជាមួយប្លុកកុំមុយនិស្ត។

ដើម្បីស្រោចស្រង់ស្ថានភាព លោកប្រធានាធិបតី Kennedy ក្រោងបញ្ជូនអតីតរដ្ឋមន្ត្រីការបរទេស Dean Acheson មកប្រទេសកម្ពុជា។ តែលោក Acheson មិនទាន់ទាំងបានមកធ្វើទស្សនកិច្ចផង លោកប្រធានាធិបតី ត្រូវបានគេធ្វើឃាត នៅថ្ងៃទី ២២ ខែវិច្ឆិកា។

សម្តេចបានកត់សំគាល់ព្រឹត្តិការណ៍សោកនាដកម្មនេះ ដោយធ្វើការកាន់ទុក្ខជាសាធារណៈចំនួន ៣ ថ្ងៃ។ យ៉ាងណាក្តី ព្រះបន្ទូលរបស់ព្រះអង្គក្នុងពេលមួយខែក្រោយមកបន្ទាប់ពីមរណភាពនៃនាយករដ្ឋមន្ត្រី Sarit Thanarat ធ្វើអោយទំនាក់ទំនងទ្វេភាគីរវាងសហរដ្ឋអាមេរិក និងកម្ពុជាមានការធ្លាក់ចុះយ៉ាងរហ័ស។

The Prince marked the tragic event with three days of public mourning. However, comments he made a month later following the death of Thai Prime Minister Sarit Thanarat sent bilateral relations between the United States and Cambodia into a tailspin.

Not only did Sihanouk call for a national celebration after Thanarat's death, but in a speech, he also suggested that divine intervention had brought about the recent deaths of Diem, Thanarat, and Kennedy; he called the late President the "great boss of aggressors." Ambassador Sprouse requested a retraction and called Sihanouk's behavior "barbaric." The Prince attempted to downplay his comments, but did not retract them.

In January, the United States began to reduce its staff in Phnom Penh and the Cambodian Ambassador to the United States, Nong Kimny, was recalled. Ambassador Sprouse returned to Washington. Despite several attempts to reverse the situation, none proved successful.

The issues surrounding Cambodia's neutrality and territorial integrity, coupled with the Khmer Serei broadcasts and continued border raids into Cambodia (during which U.S. military representatives were often present) continued to erode ties between the two countries. Anti-American sentiment grew, with demonstrations taking place around the country and two attacks on the U.S. Embassy. The United States claimed that the Cambodian military was cooperating with the Viet Cong, which merited continual incursions into Cambodian that resulted in civilian deaths.

On July 9, 1964, Randolph A. Kidder was appointed as U.S. Ambassador to Cambodia, but the Prince refused to accept his credentials. By the end of 1964, there were only 12 official representatives of the United States in Cambodia; a year earlier, there had been 300.

Meanwhile, the Gulf of Tonkin incident had led to open warfare in Northern Vietnam, with American combat units arriving in 1965. U.S.

Jacqueline Kennedy with Prince Norodom Sihanouk at her arrival in Phnom Penh.

ជិទាវ Jacqueline Kennedy ជាមួយ សម្តេចនរោត្តម សីហនុ ពេលលោកជិទាវ មកដល់ក្រុងភ្នំពេញ។

policy in Southeast Asia would now be wholly dictated by events in Vietnam, and seen through the lens of Cold War politics.

In May 1965, relations between the United States and Cambodia were officially broken. A few months later, during an unofficial visit to

First Lady Jacqueline Kennedy, Queen Sisowath Kossamak, and Prince Norodom Sihanouk at the Royal Palace in November 1967.

លោកជំទាវទី ១ Jacqueline Kennedy ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសម: និង សម្តេចនរោត្តម សីហនុ នៅព្រះបរមរាជវាំង កាលពីខែវិច្ឆិកា ឆ្នាំ ១៩៦៧ ។

សម្តេចព្រះនរោត្តម សីហនុមិនត្រឹមតែបានអំពាវនាវអោយមានការអបអរនៅទូទាំងប្រទេស បន្ទាប់ពីមរណភាពរបស់លោក Thanarat តែប៉ុណ្ណោះទេ តែនៅក្នុងសុន្ទរកថាមួយ ព្រះអង្គថែមទាំងបានមានព្រះបន្ទូលថា អន្តរាគមរបស់ព្រះ បាននាំមកនូវមរណភាពដល់លោក Diem លោក Thanarat និង Kennedy ។ ព្រះអង្គបានហៅសពលោកប្រធានាធិបតី Kennedy ថាជា "ចៅហ្វាយធំនៃពួកអ្នកឈ្លានពាន"។ លោកឯកអគ្គរដ្ឋទូត Sprouse បានសុំអោយមានការដកពាក្យវិញ ហើយបានហៅអាកប្បកិរិយារបស់ព្រះអង្គថា "ព្រៃផ្សៃ"។ សម្តេចបាននិយាយសំរាលចំពោះបន្ទូលរបស់ទ្រង់ តែមិនបានដកពាក្យវិញទេ។

នៅខែមករា សហរដ្ឋអាមេរិកបានចាប់ផ្តើមកាត់បន្ថយបុគ្គលិករបស់ខ្លួន នៅភ្នំពេញ ហើយលោក នង គីមនី ដែលជាឯកអគ្គរដ្ឋទូតខ្មែរប្រចាំនៅសហរដ្ឋអាមេរិកត្រូវបានហៅត្រឡប់មកស្រុកវិញ។ ឯកអគ្គរដ្ឋទូត Sprouse បានវិលត្រឡប់មកទីក្រុងវ៉ាស៊ីនតោនវិញ។ ទោះបីជាមានការខិតខំជាច្រើនដើម្បីបង្វែរស្ថានភាពនេះក្តី ក៏វ៉ាមិនទទួលបានជោគជ័យដែរ ។

បញ្ហានៅជុំវិញអព្យាក្រឹត្យភាព និងបូរណភាពទឹកដីនៃប្រទេសកម្ពុជា រួមផ្សំជាមួយនឹងការផ្សាយតាមវិទ្យុរបស់ខ្មែរសេរី និងការបន្តឆ្មក់ចូលព្រំដែនប្រទេសកម្ពុជា (ដោយនៅពេលនោះ តំណាងយោធារបស់សហរដ្ឋ អាមេរិកច្រើនមានវត្តមាន) បានបន្តធ្វើអោយទំនាក់ទំនងរវាងប្រទេសទាំងពីរមានការថយចុះ។ គំនិតប្រឆាំងនឹងអាមេរិកមានកាន់តែច្រើន ដោយមានបាតុកម្មនៅទូទាំងប្រទេស និងការវាយប្រហារដងទៅលើស្ថានទូតអាមេរិក។ សហរដ្ឋអាមេរិកបានអះអាង ថាកងយោធាកម្ពុជាបានធ្វើសហប្រតិបត្តិការជាមួយវៀតកុង ដែលនាំអោយមានការវាយឆ្លងចូលប្រទេសកម្ពុជាបណ្តាលអោយមានការស្លាប់ជនស៊ីវិល។

នៅថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ១៩៦៤ លោក Randolph A. Kidder ត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅប្រទេសកម្ពុជា តែសម្តេចព្រះនរោត្តម សីហនុបដិសេធមិនទទួលយកសារតាំងរបស់លោកទេ។ នៅដំណាច់ឆ្នាំ ១៩៦៤ មានតំណាងតែចំនួន ១២ នាក់ប៉ុណ្ណោះរបស់សហរដ្ឋអាមេរិក នៅកម្ពុជា ចំណែក ក្នុងពេលមួយឆ្នាំមុននោះ មានចំនួន ៣00 នាក់។

ទន្ទឹមនឹងនោះ ឧប្បត្តិហេតុនៅឈូងសមុទ្រ Tonkin បាននាំអោយមានសង្គ្រាមដោយចំហនៅវៀតណាមភាគខាងជើង ដោយអង្គភាពប្រយុទ្ធរបស់អាមេរិកបានមកដល់នៅឆ្នាំ ១៩៦៥។ ចាប់ពីពេលនោះមក គោលនយោបាយរបស់សហរដ្ឋអាមេរិកនៅ

Cambodia by Senator Mansfield, the Prince reaffirmed his conditions for re-establishing bilateral ties: recognition of Cambodia's boundaries, compensation for lives lost, and an end to bombings and incursions in the country.

During the break, Australia represented the United States in Phnom Penh, while the French shared Cambodian views with Washington. Tensions continued, with the United States alleging that the Vietnamese communists were sending supplies into South Vietnam



Mrs. Kennedy feeding the royal elephants at the Royal Palace in Phnom Penh.

លោកស្រី Kennedy អោយចំណីសត្វដំរីនៅឯព្រះបរមរាជវាំង។

អាស៊ីអាគ្នេយ៍ដើរតាមព្រឹត្តិការណ៍នៅវៀតណាមទាំងស្រុង ហើយត្រូវបានប្រមើលមើលតាមកែវភ្នែកនៃនយោបាយសង្គ្រាមត្រជាក់។

នៅខែឧសភា ឆ្នាំ ១៩៦៥ ទំនាក់ទំនងរវាងសហរដ្ឋអាមេរិកនិងកម្ពុជាត្រូវបានកាត់ផ្តាច់ជាផ្លូវការ។ ប៉ុន្មានខែក្រោយមក នៅក្នុងអំឡុងពេលនៃទស្សនកិច្ចមកកម្ពុជារបស់ព្រឹទ្ធសមាជិក Mansfield ព្រះអង្គបានបញ្ជាក់សារជាថ្មីនូវលក្ខខ័ណ្ឌសំរាប់កសាងទំនាក់ទំនងទ្វេភាគីឡើងវិញ នោះគឺការទទួលស្គាល់ព្រំដែនរបស់កម្ពុជា សំណងចំពោះជីវិតដែលបានបាត់បង់ ហើយនិងការបញ្ឈប់ការទំលាក់គ្រាប់បែក និងការលុកចូលក្នុងប្រទេសកម្ពុជា។

ក្នុងអំឡុងរយៈពេលកាត់ផ្តាច់នោះ ប្រទេសអូស្ត្រាលីធ្វើជាតំណាងអោយសហរដ្ឋអាមេរិក នៅភ្នំពេញ ចំណែកប្រទេសបារាំងតំណាងអោយប្រទេសកម្ពុជាក្នុងការទាក់ទងជាមួយក្រុងវ៉ាស៊ីនតោន។ ភាពតានតឹងនៅមានជាបន្ត ដោយសហរដ្ឋអាមេរិកបានធ្វើការចោទប្រកាន់ថា ពួកកុំមុយនិស្តវៀតណាមកំពុងដឹកជញ្ជូនគ្រឿងផ្គត់ផ្គង់តាមកំពង់ផែក្រុងព្រះសីហនុ ភស្តុតាងខ្លះបង្ហាញថា កម្ពុជាមានកិច្ចព្រមព្រៀងជាមួយចិន និងវៀតណាមខាងជើង ក្នុងការរក្សាទុកអាវុធចំនួន ១0% នៃអាវុធទាំងអស់ ដែលត្រូវបានដឹកឆ្លងកាត់។ ថ្នាំពេទ្យ និងជាង ១ ភាគ៤ នៃផលិតផលស្រូវ

Jacqueline Kennedy and Prince Norodom Sihanouk during a dinner at Chamcar Mon Palace.

អ្នកស្រី Jacqueline Kennedy និងសម្តេចព្រះនរោត្តមសីហនុ ក្នុងពិធីភោជនីអាហារពេលល្ងាចនៅដំណាក់ចំការមន។

Prince Sihanouk and Jacqueline Kennedy inaugurate J.F. Kennedy Avenue in Sihanoukville.

សម្តេចព្រះ នរោត្តម សីហនុ និងអ្នកស្រី Jacqueline Kennedy ក្នុងពិធីសម្ពោធវិថី J.F. Kennedy នៅទីក្រុងព្រះសីហនុ។

របស់កម្ពុជាត្រូវបានលក់ទៅអោយវៀតណាមខាងជើង។ នៅមានកង្វល់ផងដែរថា សម្តេចព្រះនរោត្តមសីហនុបានចងសម្ព័ន្ធមិត្តជាមួយប្រទេសចិន។ នៅ ត្រឹមចុងឆ្នាំ ១៩៦៥ លោកប្រធានាធិបតី Lyndon Johnson បានអនុញ្ញាតិអោយមានប្រតិបត្តិការ សំងាត់ចូលក្នុងប្រទេសកម្ពុជាដើម្បីកំទេចមូលដ្ឋានរបស់ពួកវៀតកុង។

ទស្សនកិច្ចរបស់ជំទាវ Jacqueline Kennedy មកប្រទេសកម្ពុជា នៅខែ វិច្ឆិកា ឆ្នាំ ១៩៦៧ ហាក់ដូចជាសញ្ញានៃការប្រែប្រួលល្អនៃទំនាក់ទំនង។ ព្រះអង្គបាន រៀបចំសំរាប់ដំណើរទាំងមូលរបស់លោកជំទាវ ហើយបានស្វាគមន៍លោកស្រីជាភ្ញៀវ

Mrs. Kennedy visited Angkor Wat.

លោកជំទាវ Kennedy ទស្សនាប្រាសាទអង្គរវត្ត

through the Cambodian port of Sihanoukville (some evidence suggests that the Cambodians had entered a deal with the Chinese and North Vietnamese to keep 10% of all weapons that passed through). Medical supplies and over a quarter of Cambodia's rice output were being sold to the North Vietnamese. There was also concern that the Prince had allied himself with the Chinese. By late 1965, President Lyndon Johnson signed off on the expansion of covert operations into Cambodia to destroy Viet Cong bases.

The visit of Jacqueline Kennedy to Cambodia in November 1967 seemed to signal a promising shift in relations. The Prince planned her entire trip and welcomed her as a personal guest, making Mrs. Kennedy the first American to be received with high state honors since relations were severed. The New York Times reported that a crowd of 10,000 greeted her at the airport; the former First Lady was welcomed by "girls in red and white Cambodian dress… carrying silver bowls filled with jasmine petals, which they strewed in front of Mrs. Kennedy in the traditional symbolic Buddhist welcome." During her trip, Mrs. Kennedy visited Angkor Wat, attended a ceremony where an avenue was named for President Kennedy, and met with Queen Sisowath Kossamak, Prince Sihanouk's mother.

Shortly thereafter, the Prince indicated he would receive a Presidential envoy. Chester A. Bowles landed in Phnom Penh on January 8, 1968, and the men had productive discussions about the extent of the Viet Cong presence in Cambodia and Sihanouk's concerns about the integrity of Cambodia's borders. The Prince emphasized that recognition of these borders was essential to the restoration of diplomatic relations. Sihanouk also agreed to small-scale U.S. military action in remote parts of Cambodia, so long as they remained minimal.

Bowles emerged optimistic from the meeting, confident that relations would be restored. But an intensification of border skirmishes, driven to a degree by the Tet Offensive in late January 1968, postponed the issue again.

ពិសេស ដោយលោកជំទាវគឺជាជនជាតិអាមេរិកដំបូងគេដែលទទួលបាននូវកិត្តិយសថ្នាក់រដ្ឋខ្ពស់ តាំងពីទំនាក់ទំនងត្រូវបានកាត់ផ្តាច់មក។ កាសែត The New York Times បានសរសេរថា មានមនុស្សប្រមាណ ១0 000 នាក់បានទទួលលោកជំទាវនៅព្រលានយន្តហោះ ។ អតីតជំទាវទី១ ត្រូវបានស្វាគមន៍ដោយ "នារីក្នុងសំលៀកបំពាក់ក្រហមនិងស... ដៃកាន់ផ្ទៀលប្រាក់មានដាក់ផ្ការ៉ាម្ប៊ិះ ដែលគេរាយនៅពីមុខលោកជំទាវជាលក្ខណៈស្វាគមន៍តាមប្រពៃណីព្រះពុទ្ធសាសនា"។ ក្នុងដំណើរទស្សនកិច្ចនេះ លោកជំទាវ Kennedy បានទៅទស្សនាប្រាសាទអង្គរវត្ត ចូលរួមក្នុងពិធីសម្ពោធផ្លូវមួយដែលបានដាក់ឈ្មោះរបស់លោកប្រធានាធិបតី Kennedy ហើយបានចូលគាល់ព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសម: ដែលជាមាតារបស់សម្តេចព្រះនរោត្តម សីហនុ។

បន្ទាប់ពីនោះបន្តិច ព្រះអង្គបានបង្ហាញអោយឃើញថាទ្រង់នឹងទទួលបេសកជនរបស់ប្រធានាធិបតី។ លោក Chester A. Bowles បានមកដល់ទីក្រុងភ្នំពេញ នៅថ្ងៃទី ៨ ខែមករា ឆ្នាំ១៩៦៨ ហើយបានពិភាក្សាប្រកបដោយផ្លែផ្កាស្តីពីកំរិតនៃវត្តមានរបស់ពួកវៀតកុង នៅប្រទេសកម្ពុជានិងពីកង្វល់របស់សម្តេចព្រះនរោត្តមសីហនុលើបូរណភាពព្រំដែនរបស់ប្រទេសកម្ពុជា។ ព្រះអង្គបានគូសបញ្ជាក់ថា ការទទួលស្គាល់ព្រំដែនទាំងនេះគឺជាការចាំបាច់សំរាប់ស្តារទំនាក់ទំនងការទូតឡើងវិញ។ សម្តេចថែមទាំងបានយល់ព្រមអោយមានការធ្វើសកម្មភាពយោធាទ្រង់ទ្រាយតូចរបស់អាមេរិក នៅតាមតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ដរាបណាសកម្មភាពទាំងនោះមានកំរិតតិចតួចមែនទែន។

បន្ទាប់ពីការប្រជុំនោះមក លោក Bowles មានសុទិដ្ឋិនិយម ហើយសង្ឃឹមថា ទំនាក់ទំនងនឹងត្រូវបានស្តារឡើងវិញ។ តែការបង្កើនការវាយប្រហារតាមបណ្តាយព្រំដែន ដែលជំរុញមួយផ្នែកដោយការវាយប្រហារ Tet Offensive នៅវៀតណាមខាងត្បូង នៅចុងខែមករា ឆ្នាំ ១៩៦៨ បានបង្អាក់បញ្ហានេះម្តងទៀត។

លោក Richard M. Nixon បានស្បថចូលកាន់តំណែងប្រធានាធិបតី នៅថ្ងៃទី ២0 ខែមករា ឆ្នាំ ១៩៦៩។ ដោយពួកកុំមុយនិស្តវៀតណាមជ្រៀតចូលក្នុងប្រទេសរបស់ព្រះអង្គកាន់តែជ្រៅ ពេលនោះ សម្តេចព្រះនរោត្តមសីហនុចង់ស្តារទំនាក់ទំនងឡើងវិញ។ លោកប្រធានាធិបតី Nixon បានចាត់វិធានការដោយត្រង់ក្នុងរឿងនេះ ហើយនៅថ្ងៃទី ២ ខែមេសា សហរដ្ឋអាមេរិកបានចេញសេចក្តីប្រកាសស្តីពីព្រំដែនដោយទទួលស្គាល់អធិបតេយ្យភាព ឯករាជ្យភាព អព្យាក្រឹត្យភាព និងបូរណភាពទឹកដីនៃប្រទេសកម្ពុជា។

Richard M. Nixon was sworn in to the Presidency on January 20, 1969. With the Vietnamese Communists penetrating deeper and deeper into his country, by now Sihanouk was anxious to restore relations. President Nixon took direct measures toward this end and on April 2, the United States issued a border declaration that recognized Cambodia's sovereignty, independence, neutrality and territorial integrity.

Cambodia's fate was now more important than ever in securing a U.S. victory in the war in Vietnam. Evidence shows that by 1970, anywhere from a fifth to a third of Cambodia was occupied by Viet Cong-North Vietnamese forces. In an attempt to eliminate or thwart the progress of the communists, President Nixon authorized a covert bombing campaign in eastern Cambodia known as Operation Menu. The 14-month campaign, which had commenced on March 18, 1969 resulted in over 230,516 sorties that collectively dropped some 2,756,941 tons of ordnance on eastern Cambodia. The bombings would not become known to the American public until 1973.

The U.S. Embassy reopened on August 16, 1969, with Lloyd M. Rives as Chargé d'Affaires ad interim, with a staff numbering eight. Later that month, in an effort to demonstrate Washington's new commitment to Cambodia, Senator Mansfield returned to Phnom Penh for the third time for a friendly meeting with Prince Sihanouk, who called the Senator, "one of the greatest and most loyal friends to Cambodia." Mansfield would further contribute to the restoration of relations.

Though relations had been restored, hundreds of border incidents and the B-52 bombings, coupled with continued Vietnamese advancement, would mean that tensions remained high. Meanwhile, facing serious casualties among American troops and an increasingly powerful anti-war movement at home, the withdrawal of U.S. soldiers in Vietnam would begin.

នៅពេលនោះ ជោគវាសនានៃប្រទេសកម្ពុជាមានសារៈសំខាន់ជាងពេលណា។ទាំងអស់ ក្នុងការទទួលបានជោគជ័យរបស់សហរដ្ឋអាមេរិក នៅក្នុងសង្គ្រាមវៀតណាម។ ភស្តុតាងបង្ហាញថា មកដល់ឆ្នាំ ១៩៧0 ប្រទេសកម្ពុជាចំនួនពី ១ ភាគ ៥ ទៅ ១ ភាគ ៣ ត្រូវបានកាន់កាប់ដោយកំលាំងវៀតកុង និងកំលាំងវៀតណាមខាងជើង។ ដើម្បីបំបាត់ ឬទប់ដំណើរទៅមុខនៃពួកកុំម្មុយនិស្ត លោកប្រធានាធិបតី Nixon បានអនុញ្ញាតិអោយមានយុទ្ធនាការទំលាក់គ្រាប់បែកដោយសំងាត់ នៅភាគខាងកើតប្រទេសកម្ពុជា ដែលត្រូវបានគេហៅថា Operation Menu ។ យុទ្ធនាការរយៈពេល ១៤ ខែ ដែលបានចាប់ផ្តើមនៅថ្ងៃទី ១៨ ខែមិនា ឆ្នាំ១៩៦៩ មានជើងយន្តហោះចំនួនជាង ២៣0 ៥១៦ ជើង ហើយគ្រាប់ដែលបានទំលាក់មានទំងន់សរុបចំនួន ២ ៧៥៦ ៩៤១ តោន។ រហូតមកដល់ឆ្នាំ ១៩៧៣ ទើបសាធារណជនអាមេរិកដឹងពីការទំលាក់គ្រាប់បែកនេះ។

ស្ថានទូតអាមេរិកបានចាប់ផ្តើមបើកឡើងវិញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ ១៩៦៩ ដោយមានលោក Lloyd M. Rives ជាភារធារី ហើយមានបុគ្គលិកចំនួន ៨ នាក់។ ក្រោយមកនៅក្នុងខែដដែលនោះ ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តថ្មីរបស់ក្រុងវ៉ាស៊ីនតោនចំពោះប្រទេសកម្ពុជា លោកព្រឹទ្ធសមាជិកសភា Mansfield បានត្រឡប់មកភ្នំពេញវិញជាលើកទី ៣ ដើម្បីការប្រជុំមិត្តភាពជាមួយសម្តេចព្រះនរោត្តម សីហនុ ដែលបានហៅលោកព្រឹទ្ធសមាជិកថាជា "មិត្តម្នាក់របស់កម្ពុជា ដែលអស្ចារ្យ និងស្មោះត្រង់បំផុត"។ លោក Mansfield បានរួមចំណែកជួយស្តារទំនាក់ទំនងឡើងវិញ។

ទោះបីទំនាក់ទំនងត្រូវបានស្តារឡើងវិញក្តី តែឧប្បត្តិហេតុរាប់រយនៅតាមបណ្តាយព្រំដែន និងការទំលាក់គ្រាបបែកដោយយន្តហោះ B–៥២ រួមជាមួយនឹងការបន្តរុលចូលមករបស់វៀតណាម ធ្វើអោយភាពតានតឹងនៅតែខ្លាំង។ ទន្ទឹមនឹងនោះ ដោយប្រឈមនឹងការស្លាប់និងរបួសក្នុងចំណោមទាហានអាមេរិកកាន់តែច្រើន គួបផ្សំនឹងចលនាប្រឆាំងសង្គ្រាមមានកាន់តែច្រើននៅសហរដ្ឋអាមេរិក ការដកកងទ័ពអាមេរិកពីប្រទេសវៀតណាមក៏បានចាប់ផ្តើម។

Admiral John S. McCain is welcomed by General Sisowath Sirik Matak upon arrival at the airport in 1971.

លោកឧត្តមនាវីឯក John S. McCain ត្រូវបាន
ស្វាគមន៍ ដោយឧត្តមសេនីយ សិរីមតៈ នៅ
លោកមកដល់ ព្រលានយន្តហោះ នៅ

ទាហានអាមេរិកម្នាក់ឡើងបង្ហូតទង់ជាតិអាមេរិកចុះ នៅស្ថានទូតអាមេរិកក្នុងឆ្នាំ ១៩៧៥។

1970s

- 1970: Prince Sihanouk ousted and Lon Nol takes over; Cambodia begins fighting the communists with U.S. support
- 1973: U.S. Congress ends military assistance to Cambodia
- 1975: The Khmer Rouge takes Phnom Penh; U.S. Embassy staff evacuated
- 1975-1979: Up to two million Cambodians die under the Khmer Rouge
- 1979: Vietnam invades Cambodia and topples Pol Pot

- ឆ្នាំ ១៩៧០: សម្តេច សីហនុត្រូវបានបណ្តេញចេញពីអំណាច ហើយលោក លន់ នល់ ឡើងកាន់អំណាច ប្រទេសកម្ពុជាបានចាប់ផ្តើមច្បាំងជាមួយពួកកុំម្មុយនិស្ត ដោយមានជំនួយពីសហរដ្ឋអាមេរិក
- ឆ្នាំ ១៩៧៣: សភាសហរដ្ឋអាមេរិកបញ្ឈប់ជំនួយយោធាអោយកម្ពុជា
- ឆ្នាំ ១៩៧៥: ខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ បុគ្គលិកទូតអាមេរិកត្រូវបានជម្លៀសចេញ
- ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩: ប្រជាជនកម្ពុជាចំនួន ២ លាននាក់បានស្លាប់ ក្រោមរបបខ្មែរក្រហម
- ឆ្នាំ ១៩៧៩: វៀតណាមចូលលុកលុយប្រទេសកម្ពុជា ហើយផ្តួលរំលំរបបប៉ុល ពត

Prince Sihanouk's efforts throughout the previous decade to keep Cambodia out of the war in Vietnam and walk a tightrope between superpowers had failed. In March 1970, while he vacationed in France, the National Assembly voted unanimously to withdraw its confidence from Prince Sihanouk.

Lon Nol would become the new head of state and oversee the drafting of a new constitution. In October 1970, he proclaimed the Khmer Republic, with the removal of Vietnamese Communists from Cambodian lands at the center of its agenda.

The Prince and the communist powers—the governments of North Vietnam, the Soviet Union and China—claimed that the CIA was behind the coup, while President Nixon and Henry Kissinger, then National Security Advisor, expressed surprise at the take-over, stating the United States was in no way involved. Many scholars now believe that the United States knew that Sihanouk might be overthrown, but whether or not it had a hand in the coup has never been certain. The exiled Prince would go on to form a government in Paris called the Gouvernement Royal d'Union Nationale de Kampuchea, or GRUNK, while encouraging Cambodians to join the rising Khmer Rouge party.

The United States military had become increasingly suspicious of the Prince and viewed him as an obstacle to its objectives in Southeast Asia. The trafficking of weapons and supplies for Vietnamese communists through the Cambodian port of Sihanoukville had long been an issue of concern, as were Sihanouk's overtures to the North Vietnamese. Given these issues, the new regime in Cambodia was viewed as a positive change in the recently re-established diplomatic relations between the United States and Cambodia. The United States was quick to recognize and back Lon Nol's government.

Initially, the U.S. Embassy staff remained small, with the primary task of resuming dialogue with Cambodia; it was composed of Chargé d'Affaires Lloyd M. Rives, a military attaché, an administrative officer, a political officer, two secretaries, and a communicator. On September

ការប្រឹងប្រែងរបស់សម្តេច សីហនុ ក្នុងទសវត្សមុនទាំងមូល ដើម្បីធ្វើអោយប្រទេសកម្ពុជាស្ថិតនៅក្រៅសង្គ្រាមវៀតណាម ហើយប្រកាន់ជំហរដោយប្រយ័ត្ន នៅចន្លោះប្រទេសមហាអំណាច មិនបានធ្វើអោយព្រះអង្គទទួលបានជោគជ័យទេ។ នៅខែមិនា ឆ្នាំ ១៩៧0 នៅពេលសម្តេចសីហនុកំពុងតែសំរាកលំហែព្រះកាយនៅប្រទេសបារាំងសភាជាតិបានបោះឆ្នោតជាឯកច្ឆន្ទដកសេចក្តីទុកចិត្តពីព្រះអង្គ។

លន់ ណុលបានក្លាយជាប្រមុខរដ្ឋថ្មី ហើយដឹកនាំការធ្វើសេចក្តីព្រាងលើរដ្ឋធម្មនុញ្ញថ្មី។ នៅខែតុលា ឆ្នាំ ១៩៧0 លោកបានប្រកាសបង្កើតរបបសាធារណរដ្ឋខ្មែរ ដោយមានរបៀបវារៈសំខាន់គឺការបណ្តេញជនជាតិវៀតណាមចេញពីទឹកដីកម្ពុជា។

សម្តេច សីហនុ និងមហាអំណាចកុំម្មុយនិស្ត ដែលមានរដ្ឋាភិបាលវៀតណាមខាងជើង សហភាពសូវៀត និងចិន បានអះអាងថា សេអ៊ីអានៅពីក្រោយការធ្វើរដ្ឋប្រហារ ចំណែកលោកប្រធានាធិបតី Nixon និង លោកទីប្រឹក្សាសន្តិសុខជាតិ Henry Kissinger បានសំដែងការភ្ញាក់ផ្អើលចំពោះការចាប់យកអំណាចនេះ ដោយបាននិយាយថាសហរដ្ឋអាមេរិកមិនមានជាប់ពាក់ព័ន្ធអ្វីទាំងអស់។ អ្នកជំនាញជាច្រើនជឿថា សហរដ្ឋអាមេរិកបានដឹងថាគេនឹងទំលាក់សម្តេច សីហនុតែត្រង់ថា សហរដ្ឋអាមេរិកមានការពាក់ព័ន្ធក្នុងរដ្ឋប្រហារឬអត់នោះគឺគេមិនច្បាស់ទេ។ សម្តេចដែលកំពុងនៅនិរទេសនោះ បានបង្កើតរដ្ឋាភិបាលមួយនៅទីក្រុងប៉ារីស ដែលមានឈ្មោះថារាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា (Gouvernement Royal d'Union Nationale de Kampuchea ឬ GRUNK) ដោយបានអំពាវនាវអោយពលរដ្ឋខ្មែរចូលរួមជាមួយក្រុមខ្មែរក្រហម ដែលកំពុងតែមានចំនួនសមាជិកកើនឡើង។

យោធាអាមេរិកមានការសង្ស័យកាន់តែច្រើនឡើងទៅលើសម្តេច សីហនុ ហើយបានចាត់ទុកសម្តេចថា ជាឧបសគ្គមួយដល់ការសំរេចគោលបំណងរបស់ខ្លួននៅអាស៊ីអាគ្នេយ៍។ ការលួចជួញដូរអាវុធនិងគ្រឿងផ្គត់ផ្គង់ទៅអោយពួកកុំម្មុនិស្តវៀតណាម តាមរយៈកំពង់ផែក្រុងព្រះសីហនុ គឺជាកង្វល់មួយដែលមានជាយូរមកហើយ ចំណែកការទាក់ទងរបស់សម្តេចជាមួយវៀតណាមខាងជើងក៏ជាកង្វល់មួយដែរ។ ដោយសារមានបញ្ហាទាំងនេះ របបថ្មីនៅកម្ពុជាត្រូវបានចាត់ទុកថាជាការប្រែប្រួលវិជ្ជមានមួយក្នុងទំនាក់ទំនងដែលទើបតែត្រូវបានបង្កើតឡើងវិញ រវាងសហរដ្ឋអាមេរិកនិងកម្ពុជា។ សហរដ្ឋអាមេរិកទទួលស្គាល់និងគាំទ្ររដ្ឋាភិបាល លន់ ណុលភ្លាម។

15, 1970, Ambassador Emory C. Swank presented his credentials in Phnom Penh. He would remain in the post for three years.

The United States and Cambodia now shared the same goal: to get communist Vietnamese troops out of Cambodia. To this end, Lon Nol entered into an entente with the South Vietnamese, ending Cambodia's long-time position of neutrality. In doing so, Cambodia officially began to fight the communists.

But Lon Nol would not be the strong military leader Cambodia needed. Within the first few months of his rule, his Force Armée National Khmère, or FANK, would suffer major casualties and setbacks, desperately looking on as more than half of Cambodia fell to the North Vietnamese army.

On April 30, 1970, President Nixon informed a shocked American public that U.S. and South Vietnamese troops were entering Cambodia in order to defeat the over 40,000 Viet Cong and North Vietnamese soldiers that had amassed in the east of the country. Few people outside of the President's circle knew about the plan, including Secretary of State William P. Rogers, who only five days earlier had testified to the U.S. Senate Committee on Foreign Relations that the United States had no intention of intervening in Cambodia.

The strategy, known as the Cambodia Campaign or Cambodia Incursion, had several aims: to upset the supply system to the Vietnamese communists, relieve pressure on U.S. and South Vietnamese soldiers in South Vietnam, facilitate the imminent withdrawal of U.S. troops from Vietnam, and help rid Cambodia of the communist threat. Cambodia was no longer simply a sideshow in the Vietnam War; it was now part of it.

Nations around the world condemned the military action. At home, with the United States in the throes of the anti-war movement, Nixon's announcement ignited college campuses across the country. In one of the era's most infamous incidents, four student demonstrators were

ដំបូងឡើយ ស្ថានទូតអាមេរិកមានបុគ្គលិកតិច ដោយមានភារកិច្ចសំខាន់គឺ បន្តការពិភាក្សាឡើងវិញជាមួយប្រទេសកម្ពុជា។ បុគ្គលិកទាំងនេះរួមមានការធារី Lloyd M. Rives អនុព័ន្ធយោធាម្នាក់ មន្ត្រីរដ្ឋបាលម្នាក់ មន្ត្រីនយោបាយម្នាក់ លេខាធិការ ២ នាក់ និងអ្នកកាន់ផ្នែកទូរគមនាគមន៍ម្នាក់។ នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៧0 ឯកអគ្គរដ្ឋទូត Emory C. Swank បានជូនសារតាំងនៅក្រុងភ្នំពេញ។ លោកបានកាន់តំណែងនោះរយៈពេល៣ ឆ្នាំ។

នៅពេលនោះ សហរដ្ឋអាមេរិក និងប្រទេសកម្ពុជាមានគោលដៅដូចគ្នា គឺ អោយពួកកុំម្មុយនិស្តវៀតណាមចេញពីប្រទេសកម្ពុជា។ ដើម្បីសំរេចបំណងនេះ លន់ ណុល មានការព្រមព្រៀងជាមួយវៀតណាមខាងត្បូង ដែលជាការបញ្ចប់គោលជំហរ អព្យាក្រិត្យដែលប្រទេសកម្ពុជាបានប្រកាន់តាមជាយូរមកហើយ។ ក្នុងការធ្វើដូច្នេះ ប្រទេសកម្ពុជាបានចាប់ផ្តើមធ្វើសង្គ្រាមជាផ្លូវការជាមួយពួកកុំម្មុយនិស្ត។

តែលន់ ណុល មិនមែនជាមេដឹកនាំយោធាខ្លាំងម្នាក់ ដែលប្រទេសកម្ពុជា ត្រូវការនោះទេ។ ក្នុងអំឡុងពេលប៉ុន្មានខែក្រោមការដឹកនាំរបស់លោក កងទ័ពជាតិ ខ្មែររបស់លោកមានការស្លាប់ របួស និងបរាជ័យយ៉ាងធ្ងន់ ដោយតំបន់ជាងពាក់ កណ្តាលនៃប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងដៃរបស់កងទ័ពវៀតណាមខាងជើង។

នៅថ្ងៃទី ៣0 ខែមេសា ឆ្នាំ ១៩៧0 លោកប្រធានាធិបតី Nixon បានជំរាប សាធារណជនអាមេរិកដែលមានការភ្ញាក់ផ្អើលថា កងទ័ពរបស់សហរដ្ឋអាមេរិក និង កងទ័ពវៀតណាមខាងត្បូងបានចូលប្រទេសកម្ពុជា ដើម្បីវាយទាហានវៀតណាមខាង ជើង និងពួកវៀតកុង ដែលមានចំនួនជាង ៤0 000 នាក់ និងបានផ្តុំនៅក្នុងភាគខាង កើតប្រទេសកម្ពុជា។ មានមនុស្សតិចតួចប៉ុណ្ណោះនៅក្រៅរង្វង់របស់លោក ប្រធានាធិបតី ដែលបានដឹងពីផែនការនេះ រួមទាំងរដ្ឋមន្ត្រីក្រសួងការបរទេស William P. Rogers ដែលកាលពី ៥ ថ្ងៃមុននោះ បានថ្លែងទៅកាន់គណកម្មាធិការ កិច្ចការបរទេសរបស់ព្រឹទ្ធសភាថា សហរដ្ឋអាមេរិកគ្មានបំណងចូលអន្តរាគមក្នុង ប្រទេសកម្ពុជាទេ។

យុទ្ធសាស្ត្រនោះ ដែលមានឈ្មោះថា យុទ្ធនាការនៅប្រទេសកម្ពុជា (Cambodia Campaign) ឬការលុកចូលប្រទេសកម្ពុជា (Cambodia Incursion) មានគោលបំណងច្រើន គឺផ្តាច់ប្រព័ន្ធផ្គត់ផ្គង់ទៅអោយពួកកុំម្មុយនិស្ត វៀតណាម បន្ធូរសម្ពាធទៅលើកងទ័ពអាមេរិក និងកងទ័ពវៀតណាមខាងត្បូង សំរួល ដល់ការដកកងទ័ពសហរដ្ឋអាមេរិក ដែលនឹងមានដោយជៀសមិនផុត ចេញពី

Vice President Spiro Agnew on his visit to Cambodia in September in 1970.

លោកអនុប្រធានាធិបតី Spiro Agnew ធ្វើទស្សនកិច្ច
នៅប្រទេសកម្ពុជា ក្នុងខែកញ្ញា ឆ្នាំ១៩៧០។

killed by the National Guard at Kent State University on May 4.

The U.S. Congress had been kept in the dark on the Cambodia Incursion. Its Committee on Foreign Relations, with Senator William J. Fulbright taking the lead, demanded to know the legal basis for the troops being sent to Cambodia. Fifty U.S. Senators voiced their opposition to the campaign; 21 supported it. Shortly thereafter, the Cooper-Church Amendment was introduced to the U.S. Senate, which included a stipulation that the official number of U.S. personnel in Cambodia could never exceed 200 at any given time.

But the incursion did not have the intended results. Fleeing from the attacks, the Vietnamese communists retreated deeper into Cambodia, bringing them within a few miles of Phnom Penh. President Nixon did not lose resolve, taking the view that it was essential to U.S. policy that Cambodia not fall to the communists. He was committed to preserving Cambodia's independence. To show his support, the President sent Vice President Agnew to Phnom Penh. Nixon was also determined to increase U.S. military assistance to Cambodia, seeking to increase aid from $8.9 million in 1970 to $40 million in 1971. A few months later, the President requested an additional $255 million for Cambodia. Congress would grant $185 million; in total, the United States would provide $1.6 billion to the Lon Nol regime. Controversially, some of these funds were delivered without Congressional approval.

វៀតណាម និងជួយប្រទេសកម្ពុជាក្នុងការបំបាត់ការគំរាមកំហែងរបស់ពួកកុំម្យុនិស្ត។ នៅពេលនោះ ប្រទេសកម្ពុជាលែងមានឋានៈបន្ទាប់បន្សំទៀតហើយ ក្នុងសង្គ្រាមវៀតណាម។ កម្ពុជាគឺជាផ្នែកមួយក្នុងសង្គ្រាមវៀតណាម។

ប្រទេសនានានៅជុំវិញពិភពលោកថ្កោលទោសសកម្មភាពយោធានោះ។ ដោយមានចលនាប្រឆាំងសង្គ្រាមនៅសហរដ្ឋអាមេរិកស្រាប់ផងនោះ សេចក្ដីប្រកាសរបស់លោកប្រធានាធិបតី Nixon បានបញ្ជេះអោយមានបាតុកម្មនៅតាមមហាវិទ្យាល័យនៅទូទាំងសហរដ្ឋអាមេរិក។ ក្នុងព្រឹត្តិការណ៍ដ៏ជូរចត់បំផុតមួយ ក្នុងពេលនោះគឺ បាតុករជានិស្សិតចំនួន ៤ នាក់ត្រូវបានសំលាប់ ដោយឆ្មាំជាតិ (National Guard) នៅសាកលវិទ្យាល័យ Kent State នៅថ្ងៃទី ៤ ខែឧសភា។

សភាសហរដ្ឋអាមេរិកមិនបានដឹងពីការវាយលុកចូលប្រទេសកម្ពុជាទេ។ គណកម្មាធិការកិច្ចការបរទេសរបស់សភាសហរដ្ឋអាមេរិក ដែលមានព្រឹទ្ធសមាជិក William J. Fulbright ជាអ្នកដឹកនាំ បានទាមទារ អោយមានការពន្យល់ពីមូលដ្ឋានច្បាប់នៃការបញ្ជូនកងទ័ពចូលប្រទេសកម្ពុជា។ ព្រឹទ្ធសមាជិកចំនួន ៥0 នាក់បានសំដែងការប្រឆាំងរបស់គេចំពោះយុទ្ធនាការនេះ ហើយមាន ២១ នាក់បានគាំទ្រយុទ្ធនាការនេះ។ បន្ទាប់ពីនោះបន្ទិចវិសោធនកម្ម Cooper-Church ត្រូវបានអនុម័តក្នុងព្រឹទ្ធសភាអាមេរិក ដោយមានខ្ចែងថា ចំនួនផ្លូវការនៃបុគ្គលិកអាមេរិកនៅកម្ពុជាមិនអាចមានលើសពី ២00 នាក់ទេ ទោះក្នុងករណីណាក៏ដោយ។ តែការលុកចូលនោះមិនទទួលបានលទ្ធផលតាមការចង់បានទេ។ ដោយគេចចេញពីការវាយប្រហារ ពួកកុំម្យុនិស្ត វៀតណាមបានដកថយចូលជ្រៅទៅក្នុងប្រទេសកម្ពុជារហូតដល់តែប៉ុន្មានម៉ែល៏តែប៉ុណ្ណោះពីទីក្រុងភ្នំពេញ។ លោកប្រធានាធិបតី Nixon មិនបានបាត់បង់ការប្ដេជ្ញាចិត្ត ទេដោយមានទស្សនៈថាវាមានសារៈសំខាន់ចាំបាច់ដល់គោលនយោបាយរបស់សហរដ្ឋអាមេរិក ដែលប្រទេសកម្ពុជាមិនត្រូវធ្លាក់ទៅក្នុងដៃរបស់ពួកកុំម្យុនិស្ត។ លោកមានការប្ដេជ្ញាចិត្តក្នុងការថែរក្សាឯករាជ្យរបស់ប្រទេសកម្ពុជា។ ដើម្បីបង្ហាញការគាំទ្ររបស់លោក លោកប្រធានាធិបតីបានបញ្ជូនអនុប្រធាធិបតី Spiro Agnew មកទីក្រុងភ្នំពេញ។ លោក Nixon ថែមទាំងបានប្ដេជ្ញាចិត្តបង្កើនជំនួយយោធារបស់ សហរដ្ឋអាមេរិកដល់ប្រទេសកម្ពុជាថែមទៀត ដោយចង់បង្កើនជំនួយយោធាពី ៨,៩ លានដុល្លាអាមេរិក នៅឆ្នាំ១៩៧0 ដល់ ៤0 លានដុល្លាអាមេរិកនៅឆ្នាំ១៩៧១។ ប៉ុន្មានខែក្រោយមក លោកប្រធានាធិតីក៏បានស្នើប្រាក់ចំនួន ២៥៥ លានដុល្លាបន្ថែម ទៀតសំរាប់ប្រទេសកម្ពុជា។ សភាអាមេរិកយល់ព្រមផ្ដល់ប្រាក់ចំនួន ១៨៥ លាន ដុល្លា។ គិតសរុប

The U.S. Embassy grew as U.S. military personnel arrived in Phnom Penh and U.S. forces provided significant air power to assist the Cambodians. But both the Department of Defense and the Embassy feared for Cambodia's future. Lon Nol continued to be a weak leader, ineffectively managing the army and a government that seemed to be falling deeper and deeper into corruption and incompetence. The country needed a strong, central character that would win the war.

Meanwhile, the Khmer Rouge forces, or FUNK, were becoming an increasing threat as their ranks swelled with new recruits, who were both students and peasants. FUNK was bolstered by the return of some 5,000 young Cambodians who had been indoctrinated and trained by the Viet Minh in the 15 years following the wars for independence with France, after the Vietnamese forces had withdrawn from Cambodia. These now seasoned soldiers were ready to train Cambodians to join them.

The Embassy estimated that FUNK forces had grown to 15,000 by August 1971, while other accounts suggested the number might be as high as 50,000.

The August 1971 Chenla II campaign, whose main goal was to a regain control of a key transportation link, was the last offensive led by Lon Nol's FANK troops. The North Vietnamese and Viet Cong crushed the Cambodian army, killing 3,000 soldiers and sending some 15,000 demoralized troops in retreat.

The situation in Phnom Penh continued to deteriorate. To consolidate his power, Lon Nol would become increasingly anti-democratic and begin violent crackdowns on student protests and labor strikes. When an election was called in the spring of 1972, the United States hoped that Lon Nol, who had recently suffered a stroke, would graciously bow out and a reform-minded group would assume power. Not only did Lon Nol run, but he won in an election that was widely believed to be rigged. Hope was fading fast for a resolution in Cambodia.

ទៅ សហរដ្ឋអាមេរិកបានផ្តល់ប្រាក់ចំនួន ១,៦ ពាន់លានដុល្លាអាមេរិក ដល់របបលន់ណុល។ មានបញ្ហានៅត្រង់ថា ប្រាក់នេះខ្លះត្រូវបានគេបង្វែរទៅប្រើប្រាស់លើរឿងផ្សេង ដោយមិនមានការយល់ព្រមពីសភា។

ស្ថានទូតអាមេរិកបានរីកធំ ដោយបុគ្គលិកយោធាសហរដ្ឋអាមេរិកបានមកដល់ក្រុងភ្នំពេញ ហើយកំលាំងទ័ពរបស់អាមេរិកផ្តល់កំលាំងផ្នែកអាកាសសំខាន់មួយ ដើម្បីជួយកម្ពុជា។ តែទាំងក្រសួងការពារជាតិ និងស្ថានទូតអាមេរិកមានការបារម្ភចំពោះអនាគតនៃប្រទេសកម្ពុជា។ លន់ នល់ នៅតែជាមេដឹកនាំខ្សោយម្នាក់ ដោយគ្រប់គ្រងទាំងមិនមានប្រសិទ្ធិភាពលើកងទ័ពនិងរដ្ឋាភិបាល ដែលហាក់ដូចជាកំពុងតែធ្លាក់កាន់តែជ្រៅទៅ។ ទៅក្នុងអំពើពុករលួយ និងអសមត្ថភាព។ ប្រទេសកម្ពុជាពេលនោះត្រូវការតួអង្គរឹងមាំនៅថ្នាក់កំពូលដែលអាចយកឈ្នះសង្គ្រាមបាន។ ទន្ទឹមនឹងនោះ កងកំលាំងខ្មែរក្រហម ឬកងទ័ពបង្រួបបង្រួមជាតិកម្ពុជា បានចោទជាការគំរាមកំហែងកាន់តែធំឡើងដោយសារពួកគេមានចំនួនកាន់តែច្រើនឡើង ដោយមានអ្នកចូលរួមថ្មីៗ ដែលជាកសិករ និងនិស្សិត។ កំលាំងនេះត្រូវបានពង្រឹងបន្ថែមដោយការវិលត្រឡប់មកវិញនៃយុវជនខ្មែរ ចំនួន ៥000 នាក់ ដែលបានទទួលការបណ្តុះមនោគមវិជ្ជា និងហ្វឹកហ្វឺនដោយវៀតម៉ិញ ក្នុងរយៈពេល ១៥ឆ្នាំ បន្ទាប់ពីសង្គ្រាមដើម្បីឯករាជ្យជាមួយបារាំង បន្ទាប់ពីកងទ័ពវៀតណាមបានដកចេញ ពីប្រទេសកម្ពុជា។ ទាហានដែលមានបទពិសោធន៍ទាំងនេះត្រៀមជាស្រេច ដើម្បីហ្វឹកហ្វឺនខ្មែរអោយចូលរួមជាមួយគេ។

ស្ថានទូតអាមេរិកបាន៉ាន់ប្រមាណថា កងកំលាំងនេះមានកំណើនពី ១៥ 000 នាក់ នៅខែសីហា ឆ្នាំ១៩៧១ ចំណែកមជ្ឈដ្ឋានខ្លះទៀតបានលើកឡើងថា ចំនួននេះអាចមានរហូតដល់ ៥0 000 នាក់។

នៅខែសីហា ឆ្នាំ១៩៧១ យុទ្ធនាការ ចេនឡាទី ២ ដែលមានបំណងសំខាន់គឺ ដើម្បីគ្រប់គ្រងមកវិញនូវខ្សែដឹកជញ្ជូនសំខាន់មួយ គឺជាការវាយប្រហារចុងក្រោយ ដែលដឹកនាំដោយកងទ័ពជាតិកម្ពុជារបស់លោក លន់ ណុល។ កងទ័ពវៀតណាមខាងជើង និងវៀតកុងបានវាយអោយកងទ័ពកម្ពុជាបរាជ័យ ដោយបានសំលាប់ទាហានអស់ ៣ 000 នាក់ ហើយរុញអោយទាហានចំនួនប្រហែល ១៥ 000 នាក់ ដែលធ្លាក់ទឹកចិត្ត ធ្វើការដកថយ។

ស្ថានភាពនៅទីក្រុងភ្នំពេញកាន់តែមានភាពដុនដាបទៅ។ ដើម្បីពង្រឹងអំណាចរបស់គាត់ លោកលន់ណុល កាន់តែមានភាពផ្តាច់ការឡើង ហើយបានចាប់ផ្តើមដោយប្រើហឹង្សាទៅលើនិស្សិតដែលធ្វើការតវ៉ា និង កម្មករដែលធ្វើកូដកម្ម។ នៅពេល

The security situation in the country deteriorated rapidly and attacks increased, with members of Lon Nol's army defecting to the Khmer Rouge. American Foreign Service officers were forced to travel in heavily armoured vehicles. One incident saw a bomb detonated near Deputy Chief of Mission Thomas Enders's car; had he not been in a protected vehicle, the attack would have killed him.

The 1972 Easter Offensive in Vietnam, during which the North Vietnamese launched a massive campaign against South Vietnamese and U.S. troops, represented a major turning point in the war in Cambodia. Key Vietnamese units withdrew from Cambodia to support the offensive. From this point forward, the Khmer Rouge became the leading force battling the Lon Nol government, though officials in Washington would continue to believe that the insurgent troops were still backed by the Vietnamese. The conflict in Cambodia had now become a civil war.

A State Department report prepared in January of 1973 stated that the Cambodian government now controlled as little as a quarter of the country, and Lon Nol's government had virtually no support. It went on to say that without U.S. trade, Cambodia would be in complete economic ruin. Things had become so bad that even rice had to be imported into once-fertile Cambodia.

The same month saw the signing of the Paris Peace Accords, which ended direct U.S. military involvement in Vietnam. Fighting in Vietnam stopped temporarily, and there was momentary hope that the conflict would end in Cambodia. Though the accords reiterated Cambodia's independence and neutrality as defined by the 1954 Geneva Convention, no timetable was set for a ceasefire in Cambodia. On the advice of the United States, which hoped to see an end to the wars in Indochina, Lon Nol called for a ceasefire. Meanwhile, Prince Sihanouk repeatedly tried to meet with Kissinger and discuss solutions for the failing Cambodian state. Kissinger mistrusted Sihanouk's intentions and questioned his ties to the Khmer Rouge, and no talks were ever

ការបោះឆ្នោតត្រូវបានរៀបចំឡើងនៅឆ្នាំ ១៩៧២ សហរដ្ឋអាមេរិកសង្ឃឹមថា លន់ ណុល ដែលមានជំងឺដាច់សរសៃឈាមក្នុងខួរក្បាល នឹងលាឈប់ពីតំណែង ហើយក្រុមដែលមានគំនិតកែទំរង់នឹងឡើងកាន់អំណាច។ លន់ណុល មិនត្រឹមតែឈរឈ្មោះទេ តែគាត់ថែមទាំងបានឈ្នះឆ្នោតថែមទៀត ក្នុងការបោះឆ្នោត ដែលគេជឿជាទូទៅថា មានការបន្ទំសន្លឹកឆ្នោត។ ការសង្ឃឹមថានឹងមានដំណោះស្រាយឆាប់រហ័សនៅប្រទេសកម្ពុជាក៏បានរសាត់បាត់ទៅយ៉ាងឆាប់រហ័ស។

ស្ថានភាពសន្តិសុខនៅប្រទេសកម្ពុជាបានធ្លាក់ចុះយ៉ាងរហ័សហើយការវាយប្រហារមានការកើនឡើងដោយមានសមាជិកនៃកងទ័ពលន់ នល់ បានរត់ចូលពួកខ្មែរក្រហម។ មន្ត្រីសហរដ្ឋអាមេរិកដែលបំពេញការងារនៅក្រៅប្រទេស ត្រូវបង្ខំចិត្តធ្វើដំណើរតាមរថយន្តដែលមានពាសដែកក្រាស់ៗ។ មានម្តងនោះ គ្រាប់បែកបានផ្ទុះនៅជិតរថយន្តរបស់លោកអនុប្រធានទូត Thomas Enders បើលោកមិនស្ថិតក្នុងរថយន្តដែលមានការការពារទេ នោះលោកប្រហែលជាស្លាប់បាត់ទៅហើយ។

ការវាយប្រហារ Easter Offensive ក្នុងឆ្នាំ ១៩៧២ នៅប្រទេសវៀតណាមផ្តល់នូវរបត់ដ៏ធំមួយក្នុងសង្គ្រាមនៅ ប្រទេសកម្ពុជា។ នៅពេលនោះ វៀតណាមខាងជើងបានបើកយុទ្ធនាការធំមួយប្រឆាំងនឹងកងទ័ពវៀតណាមខាងត្បូង និងកងទ័ពសហរដ្ឋអាមេរិក។ កងឯកភាពសំខាន់ៗរបស់វៀតណាមបានដកចេញពីប្រទេសកម្ពុជាដើម្បីជួយក្នុងការវាយប្រហារនោះ។ ចាប់ពីពេលនោះមក ខ្មែរក្រហមបានក្លាយជាកំលាំងដឹកនាំក្នុងការប្រយុទ្ធប្រឆាំងកងទ័ពលន់ណុល ទ្វីបើមន្ត្រីក្នុងទីក្រុងវ៉ាស៊ីនតោននៅតែជឿថា កងកំលាំងរបស់ពួកខ្មែរបះបោរនៅតែទទួលបានការគាំទ្រពីវៀតណាម។ ជំលោះនៅប្រទេសកម្ពុជាបានក្លាយជាសង្គ្រាមស៊ីវិល។

របាយការណ៍របស់ក្រសួងការបរទេសអាមេរិក ដែលត្រូវបានរៀបចំនៅខែមករា ឆ្នាំ ១៩៧៣ បានបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជានៅពេលនោះ គ្រប់គ្រងប្រទេសបានតែ ១ ភាគ ៤ តែប៉ុណ្ណោះ ហើយថា រដ្ឋាភិបាលលោក លន់ ណុល ស្ទើរតែគ្មានការគាំទ្រសោះ។ របាយការណ៍នោះបាននិយាយផងដែរថា បើគ្មានពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិកទេ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាត្រូវស្ថិតក្នុងស្ថានភាពដួលរលំ។ អ្វីៗកាន់តែអាក្រក់ខ្លាំងរហូតដល់គេត្រូវនាំស្រូវចូលប្រទេសកម្ពុជា ដែលជាប្រទេសដែលមានដីមានជីជាតិ។

នៅក្នុងខែដដែលនោះ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីស ដែលនាំអោយមានការបញ្ឈប់ការពាក់ព័ន្ធផ្ទាល់ផ្ទាល់ របស់សហរដ្ឋ

arranged.

The peace was short-lived and fighting resumed in February. Lon Nol's ineptitude and the lack of a obvious successor left Cambodia with few options for a way out, though he continued to crack down on civil rights, prohibiting public gatherings, imprisoning members of the royal family, and arresting political opponents.

The conflict continued to escalate and it looked as though Phnom Penh might fall to the Khmer Rouge at any moment. But the troops were pushed back by U.S. bombings. At home, pressure was growing to end U.S. involvement in the civil war. Congress soon revoked all funds for military involvement in Cambodia, forcing President Nixon to end all air support in mid-August of 1973.

Ambassador Swank, who was by now critical of the ongoing war, was relieved of his post. On April 3, 1974, John Gunther Dean presented his credentials and took on the daunting task of trying to salvage the

U.S. Ambassador Emory Swank signs an assistance agreement with Cambodian Prime Minister Long Boret in 1973, which will provide Cambodia with 28,000 tons of rice.

លោកឯកអគ្គរដ្ឋទូត Emory Swank និង នាយករដ្ឋមន្ត្រីកម្ពុជា លោក ឡុង បូរ៉ែត ចុះហត្ថលេខា ក្នុងឆ្នាំ១៩៧៣ លើកិច្ចព្រមព្រៀងផ្តល់អោយកម្ពុជានូវជំនួយជាអង្ករចំនួន ២៨ 000តោន។

អាមេរិក នៅប្រទេសវៀតណាម។ ការប្រយុទ្ធគ្នានៅប្រទេសវៀតណាមបានឈប់ជាបណ្តោះអាសន្ន ហើយគេមានការសង្ឃឹមដ៏ខ្លីថា ជំលោះនៅកម្ពុជានឹងលែងមាន។ ទោះបីជាកិច្ចព្រមព្រៀងបានបញ្ជាក់ជាថ្មីនូវអព្យាក្រិត្យភាព និងឯករាជ្យរបស់កម្ពុជាដូចដែលមានចែងក្នុងអនុសញ្ញាក្នុងហ្ស៊ីណែវ ឆ្នាំ ១៩៥៤ ក្តី ក៏គេមិនបានកំណត់ថ្ងៃខែសំរាប់ការឈប់បាញ់គ្នានៅប្រទេសកម្ពុជាទេ។ តាមការណែនាំរបស់អាមេរិក ដែលចង់អោយមានការបញ្ចប់សង្គ្រាមនៅឥណ្ឌូចិន លន់ណល់បានអំពាវនាវអោយមានការបញ្ចប់សង្គ្រាម។ ទន្ទឹមនឹងនោះ សម្តេចព្រះនរោត្តមសីហនុបានព្យាយាមម្តងហើយម្តងទៀតក្នុងការជួបជាមួយលោក Kissinger ដើម្បីពិភាក្សាពីដំណោះស្រាយ ចំពោះប្រទេសកម្ពុជាដែលកំពុងតែយ៉ាប់យ៉ឺន។ លោក Kissinger មិនមានការទុកចិត្តលើចេតនារបស់សម្តេច ហើយមានការសង្ស័យលើទំនាក់ទំនងរបស់ព្រះអង្គជាមួយពួកខ្មែរក្រហម ហើយការជួបពិភាក្សាគ្នាក៏មិនដែលបានធ្វើឡើងឡើយ។

សន្តិភាពមានរយៈពេលខ្លី ហើយការប្រយុទ្ធគ្នាក៏ចាប់មានឡើងវិញ នៅខែកុម្ភៈ។ អសមត្ថភាពរបស់លោក លន់ ណុល និងការគ្មានអ្នកបន្តវេនពីគាត់ធ្វើអោយប្រទេសកម្ពុជាមានជំរើសតិចតួចក្នុងការរកច្រកចេញ ថ្វីបើគាត់នៅតែធ្វើការបង្ក្រាបលើសិទ្ធិពលរដ្ឋ ហាមប្រាមការជួបប្រជុំគ្នាជាសាធារណៈ ហើយចាប់សមាជិករាជ្យវង្ស ដាក់ពន្ធនាគារ និងចាប់ខ្លួនអ្នកនយោបាយប្រឆាំងក្តី។

ជំលោះបន្តមានកាន់តែខ្លាំងឡើង ហើយមើលទៅហាក់ឃើញថា ទីក្រុងភ្នំពេញអាចធ្លាក់ទៅក្នុងដៃរបស់ពួកខ្មែរក្រហមបានគ្រប់ពេលវេលា។ តែកំលាំងរបស់ពួកខ្មែរក្រហមត្រូវបានរុញច្រានទៅវិញដោយការទំលាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក។ នៅក្នុងសហរដ្ឋអាមេរិក មានការគាបសង្កត់កាន់តែ ច្រើនឡើងអោយអាមេរិកបញ្ឈប់ការពាក់ព័ន្ធក្នុងសង្គ្រាមស៊ីវិល។ មិនយូរប៉ុន្មានសភាសហរដ្ឋអាមេរិកឈប់ផ្តល់ថវិកា សំរាប់ការពាក់ព័ន្ធផ្នែកយោធា នៅប្រទេសកម្ពុជា ដែលជាការបង្ខំអោយលោកប្រធានាធិបតី Nixon បញ្ឈប់ការគាំទ្រផ្លូវអាកាសទាំងអស់នៅពាក់កណ្តាលខែសីហាឆ្នាំ ១៩៧៣។

លោកឯកអគ្គរដ្ឋទូត Swank ដែលបានធ្វើការរិះគន់ចំពោះសង្គ្រាមដែលកំពុងមានជាបន្ត ត្រូវបានដកចេញពីតំណែង។ នៅថ្ងៃទី ៣ ខែមេសា ឆ្នាំ ១៩៧៤ លោក John Gunther Dean បានជូនសារតាំង ហើយបានទទួលយកការងារដ៏ពិបាកក្នុងការស្រោចស្រង់ស្ថានភាពដែលកាន់តែមានភាពអស់សង្ឃឹមទៅ នៅក្នុងប្រទេស ដែលភាគច្រើនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម។ ដោយលែងមានការគាំទ្រ

increasingly hopeless situation in the country, which was now largely controlled by the Khmer Rouge. With U.S. support gone, the Lon Nol government focused its efforts on holding onto Phnom Penh for as long as it could.

Ambassador Dean urged for a controlled solution, which inevitably involved the United States negotiating with Khmer Rouge leaders. That way, he reasoned, the United States would at least have some influence over the fate of the country. Ambassador Dean also urged Washington to open direct talks with Prince Sihanouk. But Kissinger, who was now Secretary of State, dismissed the urgency of Dean's pleas, and did not pursue diplomatic channels. By the time he came around to the idea in 1975, the Khmer Rouge was within weeks of total victory.

After President Nixon's resignation in August 1974, the Cambodia issue fell to President Gerald Ford. The administration continued to ask Congress to support Cambodia. President Ford did manage to secure a congressional, bipartisan fact-finding mission to visit Cambodia in March 1975. Stunned by the devastation, virtually all the participants returned with the intention of restoring aid to Cambodia. But it was too late.



U.S. Marine Corps evacuating U.S. Embassy staff and American citizens from Phnom Penh. The photo was taken on April 12, 1975 by war photographer Al Rockoff.

ទាហានអាមេរិកកំពុងធ្វើការជំលាសបុគ្គលិកស្ថានទូត និងពលរដ្ឋអាមេរិកចេញពីភ្នំពេញ។ រូបថតនេះ ត្រូវបានថតដោយ លោក Al Rockoff នៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥។

របស់អាមេរិក រដ្ឋាភិបាលលោក លន់ នល់ បានផ្តោតការខិតខំលើការការពារការគ្រប់គ្រងទីក្រុងភ្នំពេញ អោយបានយូរតាមដែលអាចធ្វើទៅបាន។

លោកឯកអគ្គរដ្ឋទូត Dean សុំអោយមានដំណោះស្រាយ ដែលចាំបាច់ត្រូវអោយសហរដ្ឋអាមេរិកចរចាជាមួយមេដឹកនាំខ្មែរក្រហម។ លោកបានលើកហេតុផលថា ការធ្វើរបៀបនេះយ៉ាងហោចណាស់ក៏ធ្វើអោយអាមេរិកមានឥទ្ធិពលខ្លះលើវាសនានៃប្រទេសកម្ពុជាដែរ។ តែលោក Kissinger ដែលនៅពេលនោះជារដ្ឋមន្ត្រីក្រសួងការបរទេស មិនទទួលយកភាពបន្ទាន់នៃការអំពាវនាវសុំរបស់លោក Dean ទេ ហើយមិនបានងាកទៅរកផ្លូវការទូតទេ។ នៅពេលគាត់ងាកមករកគំនិតនេះវិញនៅឆ្នាំ ១៩៧៥ វានៅសល់ពេលតែប៉ុន្មានសប្តាហ៍តែប៉ុណ្ណោះមុនពេលពួកខ្មែរក្រហមទទួលបានជ័យជំនះទាំងស្រុង។

បន្ទាប់ពីលោកប្រធានាធិបតី Nixon បានលាលែងពីតំណែង នៅខែសីហា ឆ្នាំ ១៩៧៤ បញ្ហាប្រទេសកម្ពុជា បានធ្លាក់ទៅក្នុងដៃរបស់លោកប្រធានាធិបតី Gerald Ford។ រដ្ឋបាលលោកប្រធានាធិបតីបានបន្តសុំអោយសភាជួយដល់ប្រទេសកម្ពុជា។ លោកប្រធានាធិបតី Ford បានទទួលជោគជ័យក្នុងការធ្វើអោយមានទស្សនកិច្ចស្វែងរកការពិតរបស់សភា ដែលមានការគាំទ្រពីគណបក្សទាំងពីរមកកាន់ បទេសកម្ពុជានៅខែមិនា ឆ្នាំ ១៩៧៥។ ដោយមានការភ្ញាក់ផ្អើលចំពោះភាពអន្តរាយយ៉ាងខ្លាំងគ្រប់សមាជិកចូលរួមទាំងអស់បានវិលត្រឡប់ទៅវិញ ដោយមានបំណងផ្តល់ជំនួយដល់ប្រទេសកម្ពុជាឡើងវិញ។ តែវាហួសពេលទៅហើយ។

នៅខែមេសា លន់ ណុល បានចាកចេញពីទីក្រុងភ្នំពេញ។ ខ្មែរក្រហមស្ថិតនៅតែចំងាយ ៣ ម៉ែល៍តែប៉ុណ្ណោះពីទីក្រុងភ្នំពេញ។ នៅថ្ងៃទី ១២ ខែមេសា ស្ថានទូតអាមេរិកនៅទីក្រុងភ្នំពេញបានបិទ ហើយពលរដ្ឋអាមេរិកចំនួន ៨២ នាក់ រួមជាមួយនឹងពលរដ្ឋខ្មែរចំនួន ១៥៩ នាក់ ហើយនិងពលរដ្ឋបរទេសផ្សេងទៀតចំនួន ៣៥ នាក់ ត្រូវបានជន្លៀសចេញពីទីក្រុងដោយសុវត្ថិភាព។

នៅថ្ងៃទី ១៧ ខែមេសា កងកំលាំងខ្មែរក្រហមបានចូលក្រុងភ្នំពេញ។ ១៣ថ្ងៃបន្ទាប់មក ទីក្រុងព្រៃនគរក៏ត្រូវបានដណ្តើមបានដែរ។ សង្គ្រាមស៊ីវិលរយៈពេល ៥ ឆ្នាំ ដែលបានសំលាប់មនុស្សអស់ប្រមាណ ៥00 000 នាក់នៅប្រទេសកម្ពុជា នៅទីបំផុតបានចប់ ។ តែនោះគ្រាន់តែជាការចាប់ផ្តើមនៃការបង្ហូរឈាមថ្មី តែប៉ុណ្ណោះ នៅប្រទេសកម្ពុជា។

នៅក្រោមការដឹកនាំរបស់ សាឡុត ស ដែលមានឈ្មោះបដិវត្តន៍ថា ប៉ុល ពត

By April, Lon Nol had left Phnom Penh. The Khmer Rouge was now within three miles of the city. On April 12, the U.S. Embassy in Phnom Penh closed and 82 American citizens, along with 159 Cambodians and 35 other foreign nationals, were peacefully evacuated.

The Khmer Rouge entered Phnom Penh on April 17. Thirteen days later, Saigon fell. In the five years of civil war that had consumed Cambodia, 500,000 people died. But this would only be the beginning of the bloodshed in Cambodia.

Under the leadership of Saloth Sar, a long-time political rival of Lon Nol who had taken the revolutionary name Pol Pot, cities were emptied and residents were driven into the countryside.

The new Democratic Kampuchea would become one of the most savage, secretive regimes in the world, maintaining ties only with North Korea and China. Little would be known about the atrocities that would ensue in the next four years, which would see nearly two million people, or a fifth of the population, perish.

A report generated in 1974 by Foreign Service Officer Kenneth Quinn, who would serve as Ambassador to Cambodia from 1996 to 1999, provided a stark portrayal of the Khmer Rouge's true nature. While stationed along the South Vietnamese border for nine months between 1973 and 1974, Quinn had interviewed countless Cambodian refugees who had escaped the brutal clutches of the Khmer Rouge. He learned that the regime abolished private property and collectivized all goods, imposed forced relocations, separated families, and classified all people as peasants, workers, or soldiers. Education was highly suspect; wearing glasses was a crime worthy of execution. Minorities were persecuted. Work would be the only acceptable pastime. Quinn's assessment foreshadowed the country's fate.

After over 15 years of involvement in Indochina, and at great cost in American lives, the United States was ready to move on. Crises in the

និងជាគូបដិបក្ស នយោបាយជាយូរមកហើយរបស់លន់នល់នោះ ប្រជាជនទាំងអស់ក្នុងទីក្រុងត្រូវបានបណ្តេញចេញ អោយទៅនៅជនបទ។ របបថ្មីដែលមានឈ្មោះថា កម្ពុជាប្រជាធិបតេយ្យ គឺជារបបមួយដែលសាហាវ និងលាក់ការសំងាត់បំផុតនៅក្នុងពិភពលោក ដោយរក្សាការទាក់ទងតែជាមួយប្រទេសចិន និងកូរ៉េខាងជើងតែប៉ុណ្ណោះ។ គេដឹងតិចតួចតែប៉ុណ្ណោះពីអំពើយង់ឃ្នង ដែលមានក្នុងរយៈពេល ៤ ឆ្នាំបន្ទាប់មក ដែលនាំអោយមនុស្សប្រមាណជិត ២ លាននាក់ ឬ ប្រហែល ១ ភាគ ៤ បានស្លាប់។

របាយការណ៍មួយដែលសរសេរដោយលោក Kenneth Quinn មន្ត្រីសហរដ្ឋអាមេរិកផ្នែកកិច្ចការបរទេស ដែលក្រោយមកបានធ្វើជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅប្រទេសកម្ពុជា ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ១៩៩៩ បានរៀបរាប់យ៉ាងច្បាស់ពីសារជាតិពិតប្រាកដរបស់ពួកខ្មែរក្រហម។ ក្នុងពេលលោកប្រចាំការនៅតាមព្រំដែនវៀតណាមភាគខាងត្បូងអស់រយៈពេល ៩ ខែ រវាងចន្លោះពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៧៤ លោក Quinn បានសំភាសន៍ជនភៀសខ្លួនជាច្រើន ដែលបានគេចចេញពីកណ្តាប់ដៃដ៏ឃោរឃៅរបស់ពួកខ្មែរក្រហម។ លោកបានដឹងថារបបនេះលុបបំបាត់ចោលកម្មសិទ្ធិឯកជន ប្រមូលសម្បត្តិទ្រព្យទាំងអស់ដាក់រួមបង្គុំ អោយមនុស្សផ្លាស់ទីលំនៅ បំបែកគ្រួសារ ហើយចាត់ចំណាត់ថ្នាក់ប្រជាជនជាកសិករ កម្មករ ឬ ទាហាន។ អ្នកមានចំណេះដឹងជាមនុស្សដែលគេមានការសង្ស័យជាខ្លាំង។ ការពាក់វ៉ែនតា គឺជាបទឧក្រិដ្ឋដែលអាចទទួលទោសប្រហារជីវិត។ ក្រុមជនជាតិភាគតិចត្រូវបានគេធ្វើទុក្ខបុកម្នេញ។ គេបង្ខំអោយមនុស្សធ្វើការគ្មានពេលទំនេរ។ ការវាយតំលៃរបស់លោក Quinn គឺជាសញ្ញាប្រាប់ពីវាសនានៃប្រទេសកម្ពុជា។

បន្ទាប់ពីការពាក់ព័ន្ធអស់រយៈពេលជិត ១៥ ឆ្នាំ នៅឥណ្ឌូចិន ដោយនាំអោយមានការបាត់បង់ជីវិតជនជាតិអាមេរិកជាច្រើននោះ សហរដ្ឋអាមេរិកចង់បំភ្លេចវាចោលហើយដើរទៅមុខ។ វិបត្តិនៅមជ្ឈឹមបូព៌ា បានធ្វើអោយរដ្ឋការរបស់លោកប្រធានាធិបតី Jimmy Carter មានការខ្វល់ខ្វាយ។ ថ្វីបើសិទ្ធិមនុស្សនៅតែជាចំណុចសំខាន់ក្នុងរបៀបវារៈនយោបាយរបស់លោកក្តី តែស្ថានភាពនៅប្រទេសកម្ពុជាមិនមែនជាអាទិភាពទេ។ មានការដេញដោលគ្នាខ្លះស្តីពីការទទួលខុសត្រូវរបស់សហរដ្ឋអាមេរិកចំពោះប្រទេសកម្ពុជា ជាពិសេសលោកសមាជិកសភាតំណាងរាស្ត្រ Stephen Solarz ដែលជាសមាជិកសភាតំណាងរាស្ត្រមានការយល់ដឹងច្រើនជាងគេ ស្តីពីបញ្ហានេះ។ នៅឆ្នាំ ១៩៧៨ លោកប្រធានាធិបតី Carter បានចេញសេចក្តីថ្លែងការមួយ

Middle East would occupy the administration of President Jimmy Carter. Though human rights stood at the center of his political agenda, the situation in Cambodia was not a priority. There would be some debate about the U.S. responsibility to Cambodia—most notably on the part of Representative Stephen Solarz, who would become the most informed congressmen on the issue. In 1978, President Carter issued a statement condemning the actions of the Democratic Kampuchea government and, importantly, used the word ‘genocide’ in his statement. The same year, legislation was passed that allowed 15,000 Cambodian refugees to settle in the United States.

In response to increased Khmer Rouge incursions into Vietnamese territory, Vietnamese troops invaded Cambodia in December 1978. In January, 1979 the Khmer Rouge fled Phnom Penh and Pol Pot was forced to retreat to northwestern Cambodia. Given Vietnam’s recent alignment with the Soviet Union, the United States condemned the invasion, viewing it as an expansion of Soviet influence in Southeast Asia. Improving the relationship between the United States and Cambodia would have to wait.

ដោយថ្កោលទោសសកម្មភាពរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ហើយបានប្រើពាក្យថា "ប្រល័យពូជសាសន៍" នៅក្នុងសេចក្តីថ្លែងការនោះ។ នៅឆ្នាំដដែលនោះ មានការអនុម័តច្បាប់មួយ ដែលអនុញ្ញាតិអោយជនភៀសខ្លួនខ្មែរចំនួន១៥ 000នាក់ទៅតាំងទីលំនៅក្នុងសហរដ្ឋអាមេរិក។

ជាការឆ្លើយតបនឹងការលុកចូលរបស់ពួកខ្មែរក្រហមទៅក្នុងទឹកដីវៀតណាម ដែលចេះតែមានច្រើនឡើង កងទ័ពវៀតណាមបានលុកលុយចូលប្រទេសកម្ពុជា នៅខែធ្នូ ឆ្នាំ១៩៧៨។ នៅខែមករា ឆ្នាំ១៩៧៩ ពួកខ្មែរក្រហមបានគេចចេញពីទីក្រុងភ្នំពេញ ហើយត្រូវបានបង្ខំអោយដកថយទៅភាគពាយ័ព្យប្រទេសកម្ពុជា។ ដោយវៀតណាមបានទេរទៅខាងសហភាពសូវៀតក្នុងពេលថ្មីៗនោះ សហរដ្ឋអាមេរិកបានថ្កោលទោសការលុកចូលប្រទេសកម្ពុជារបស់វៀតណាម ដោយចាត់ទុកវាថា ជាការពង្រីកឥទ្ធិពលរបស់សូវៀតនៅ អាស៊ីអាគ្នេយ៍។ ការកែលំអទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងកម្ពុជាត្រូវរង់ចាំសិន។

1980s

- U.S. humanitarian aid alleviates suffering in refugee camps along the Thai border
- United States imposes sanctions on the Vietnamese-backed government in Phnom Penh
- 150,000 Cambodian refugees settle in the United States
- 1984: The Killing Fields wins three Academy Awards
- 1989: Vietnamese troops withdraw from Cambodia

- ជំនួយមនុស្សធម៌របស់សហរដ្ឋអាមេរិកបានជួយសំរាលទុក្ខវេទនានៅតាមជំរំជនភៀសខ្លួន តាមបណ្តាយព្រំដែនថៃ
- សហរដ្ឋអាមេរិកដាក់ទណ្ឌកម្មលើរដ្ឋាភិបាលក្រុងភ្នំពេញដែលគាំទ្រដោយវៀតណាម
- ជនភៀសខ្លួនខ្មែរចំនួន ១៥0 000 នាក់បានទៅតាំងទីលំនៅក្នុងសហរដ្ឋអាមេរិក
- ឆ្នាំ ១៩៨៤: ភាពយន្តរឿង វ៉ាលពិឃាត បានទទួលរង្វាន់ Academy ចំនួន ៣
- ឆ្នាំ ១៩៨៩: កងទ័ពវៀតណាមបានដកចេញពីប្រទេសកម្ពុជា

Cambodia began the 1980s devastated and exhausted from nearly four years of Khmer Rouge rule. The country was divided, with a Vietnamese-backed government in charge of Phnom Penh and much of the of the countryside, and a coalition of anti-government groups – including remnants of the Khmer Rouge – dug in near the border with Thailand. U.S.-Cambodian relations during the decade were colored by continuing Cold War realities, the Sino-Soviet split, and improving U.S. relations with China and ASEAN.

At the start of the 1980s, very little of Cambodia's infrastructure remained intact. Few roads, schools or hospitals had survived Khmer Rouge rule, and most civil servants and educated people had either died or fled the country.

Famine was rife. Food stocks were dwindling due to disruptions in the harvest cycle caused by the invasion of Vietnamese troops, 150,000 of whom would remain in Cambodia for most of the decade. Some 300,000 Cambodian refugees lived in UN-administered camps along the Thai border, but only 10% were given refugee status, meaning the vast majority would spend the decade in limbo.

International development groups, responding to the misery of the camps, poured into the border area to begin administering aid. The United States contributed $15 million per year in humanitarian assistance through organizations such as UNICEF and the International Committee for the Red Cross. As early as 1981, this aid began to have an impact on conditions in the camps, with the malnutrition rate among children falling from 50% to 2.5% in less than a year.

U.S. policy throughout the decade was to end Vietnamese military involvement in Cambodia and replace the Vietnamese-backed People's Republic of Kampuchea (PRK) government with one that represented the will of the people. To that end, the United States, under the Reagan and Bush administrations, supported political and popular resistance to the PRK government, which was headed by Khmer Rouge defectors.

នៅដើមទសវត្សទី ១៩៨0 ប្រទេសកម្ពុជារងការបំផ្លិច បំផ្លាញ ហើយប្រជាជនមានការបាក់កំលាំងបន្ទាប់ពីរយៈកាលជិត ៤ ឆ្នាំក្រោមរបបខ្មែរក្រហម។ ប្រទេសមានការបែងចែកដោយរដ្ឋាភិបាលក្រុងភ្នំពេញ ដែលគាំទ្រដោយវៀតណាម កាន់កាប់ទីក្រុងភ្នំពេញ និងភាគច្រើននៃតំបន់ជនបទ ហើយនិងក្រុមចងសម្ព័ន្ធគ្នាប្រឆាំងរដ្ឋាភិបាលរួមទាំងពួកខ្មែរក្រហមដែលនៅសេសសល់ មានទីតាំងរឹងមាំនៅជិតព្រំដែនថៃ។ ទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងកម្ពុជាដើរតាមស្ថានភាពជាក់ស្តែងនៃសង្គ្រាមត្រជាក់ដែលកំពុងមានជាបន្តការបែកបាក់គ្នារវាងចិន និងសូវៀត និងទំនាក់ទំនងបានល្អប្រសើរឡើងរបស់សហរដ្ឋអាមេរិកជាមួយប្រទេសចិន និងសមាគមអាស៊ាន។

នៅដើមទសវត្សទី ១៩៨0 ហេដ្ឋារចនាសម្ព័ន្ធតិចតួចណាស់នៅកម្ពុជាដែលមិនរងការប៉ះពាល់។ មានផ្លូវថ្នល់ សាលារៀន ឬមន្ទីរពេទ្យតិចតួចនៅសល់ពីរបបខ្មែរក្រហម ហើយមន្ត្រីរដ្ឋការនិងអ្នកចេះដឹងភាគច្រើនបានស្លាប់ ឬបានគេចចេញពីប្រទេស។

គ្រោះទុរ្ភិក្សមានជាទូទៅ។ ស្បៀងអាហារនៅសល់មានការថយចុះយ៉ាងខ្លាំងដោយសារការអាក់ខានក្នុងរដូវធ្វើស្រែ បណ្តាលមកពីការលុកលុយរបស់កងទ័ពវៀតណាម ដែលមានចំនួន ១៥0 000 នាក់ ស្ទើតែពេញមួយទសវត្សនោះ។ ជនភៀសខ្លួនខ្មែរចំនួនប្រហែល ៣00 000 នាក់រស់នៅតាមជំរំ ដែលគ្រប់គ្រងដោយអង្គការសហប្រជាជាតិ តាមបណ្តាយព្រំដែនខ្មែរថៃ តែមានតែ ១0% ប៉ុណ្ណោះដែលទទួលបានឋានៈជាជនភៀសខ្លួន មានន័យថាភាគច្រើនត្រូវចំណាយពេលក្នុងទសវត្សនោះដោយមិនដឹងជាត្រូវទៅណា។

ក្រុមអង្គការអភិវឌ្ឍន៍អន្តរជាតិបានឆ្លើយតបនឹងទុក្ខវេទនានៅក្នុងជំរំ បាននាំគ្នាចូលមកក្នុងតំបន់ព្រំដែន ដើម្បីចាប់ផ្តើមផ្តល់ជំនួយ។ សហរដ្ឋអាមេរិកបានផ្តល់ជំនួយមនុស្សធម៌ចំនួន ១៥ លានដុល្លាអាមេរិក ក្នុងមួយឆ្នាំ តាមរយៈអង្គការអន្តរជាតិនានា ដូចជាអង្គការ UNICEF និងអង្គការកាកបាទក្រហមអន្តរជាតិជាដើម ។ មកដល់ឆ្នាំ ១៩៨១ ជំនួយបានជួយសំរួលដល់ស្ថានភាពនៅក្នុងជំរុំ ដោយអត្រាកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារបានធ្លាក់ចុះពី ៥0% មកត្រឹម ២,៥% តែក្នុងរយៈពេលមិនដល់មួយឆ្នាំផង។

គោលនយោបាយរបស់សហរដ្ឋអាមេរិកនៅក្នុងទសវត្សនោះមានបំណងបញ្ឍប់ការពាក់ព័ន្ធផ្នែកយោធារបស់វៀតណាមនិងផ្លាស់ជំនួសរបបសាធារណរដ្ឋ

As the PRK attempted to rebuild the state institutions lost under Khmer Rouge rule, aid streamed into Cambodia along Cold War lines. The Soviet Union, Vietnam and other communist countries supported the PRK government with an estimated $100 million in aid per year, while the United States and much of the West imposed economic sanctions on the PRK government, choosing instead to focus aid on the border camps.

The anti-government resistance along the border was composed of three groups, which officially joined together in 1982 to create the Coalition Government of Democratic Kampuchea (CGDK). The largest of these was the Khmer Rouge, which received military aid from China through Thailand. Although critics charged that U.S. humanitarian aid was unintentionally reaching the Khmer Rouge, the United States denied this.

"It bears repeating – one can't say it often enough – that we give no support of any kind to the Khmer Rouge," Assistant Secretary of State for East Asian and Pacific Affairs Paul D. Wolfowitz said at the time.

The United States did directly support the two other groups, dubbed collectively the non-communist resistance, with non-lethal aid. Prince Norodom Sihanouk headed the pro-royalist National United Front for an Independent, Neutral, Peaceful and Cooperative Cambodia (FUNCINPEC), while Son Sann, a Prime Minister in the 1960s, headed the Khmer People's National Liberation Front (KPNLF).

Beginning in 1979, and continuing throughout the 1980s, the United States – along with China, ASEAN and others – voted to allow the anti-government coalition to hold Cambodia's seat at the United Nations. The United States argued that the PRK government was illegitimate since it was imposed by a foreign invasion, and it was consistent with international law to seat the predecessor government.

Despite continued U.S. government involvement in Cambodia, Americans knew little about what had happened there after 1975, when

ប្រជាមានិតកម្ពុជា ដែលគាំទ្រដោយវៀតណាម ដោយរបបមួយ ដែលតំណាងអោយឆន្ទៈរបស់ប្រជាជន។ ដើម្បីសំរេចបំណងនេះ សហរដ្ឋអាមេរិកក្រោមរដ្ឋបាលរបស់លោកប្រធានាធិបតី Reagan និងលោក Bush បានគាំទ្រការតស៊ូផ្នែកនយោបាយប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលដឹកនាំដោយក្រុមផ្តាច់ខ្លួនខ្មែរក្រហម។

ក្នុងពេលដែលសាធារណរដ្ឋប្រជាមានិតកម្ពុជាកសាងឡើងវិញនូវស្ថាប័នដែលបាត់បង់នៅក្រោមរបបខ្មែរក្រហមជិនួយបានហូរចូលមកប្រទេសកម្ពុជាពីសម្ព័ន្ធមិត្តក្នុងសង្គ្រាមត្រជាក់។ សហភាពសូវៀត វៀតណាមនិងប្រទេសកុំម្មុយនិស្តដទៃទៀត បានគាំទ្ររដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាជាមួយនឹងជិនួយដែលមានតំលៃប្រហែល ១00 លានដុល្លាអាមេរិកក្នុងមួយឆ្នាំ។ ចំណែកសហរដ្ឋអាមេរិក និងប្រទេសលោកខាងលិចភាគច្រើនបានដាក់ទណ្ឌកម្មសេដ្ឋកិច្ចទៅលើរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយផ្តោតជិនួយតែលើជំរំតាមព្រំដែនវិញ។

ពួកចលនាតស៊ូប្រឆាំងរដ្ឋាភិបាលនៅតាមព្រំដែនមានបីក្រុម ដែលបានចូលរួមគ្នាជាផ្លូវការនៅឆ្នាំ ១៩៨២ ដើម្បីបង្កើតរដ្ឋាភិបាលចំរុះកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះក្រុមខ្មែរក្រហមជាក្រុមធំជាងគេ ដែលបានទទួលជិនួយយោធាពីប្រទេសចិន តាមរយៈប្រទេសថៃ។ ថ្មីបើអ្នកវិះគន់បានចោទប្រកាន់ថាជិនួយមនុស្សធម៌របស់អាមេរិកបែរជាធ្លាក់ខុសគោលដៅទៅក្នុងដៃរបស់ពួកខ្មែរក្រហមក្តី តែសហរដ្ឋអាមេរិកបានបដិសេធចំពោះរឿងនេះ។

លោក Paul D. Wolfowitz ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកទទួលបន្ទុកកិច្ចការអាស៊ីខាងកើត និងប៉ាស៊ីហ្វិកបានមានប្រសាសន៍នៅពេលនោះថា "គេត្រូវថាម្តងហើយម្តងទៀត ហើយមិនដឹងជាប៉ុន្មានដងទើបគ្រប់ទេថា យើងមិនផ្តល់ការគាំទ្រណាមួយដល់ពួកខ្មែរក្រហមទេ"។

សហរដ្ឋអាមេរិកពិតជាបានផ្តល់ជិនួយមិនមែនអាវុធ ដោយផ្ទាល់ដល់ក្រុមពីរទៀត ដែលមានឈ្មោះថា ក្រុមតស៊ូមិនមែនកុំម្មុយនិស្ត ។ សម្តេចព្រះនរោត្តមសីហនុ បានដឹកនាំក្រុមរណសិរ្សរួបរួមជាតិរាជានិយមដើម្បីប្រទេសកម្ពុជាមានការសហប្រតិបត្តិការគ្នា សន្តិភាព អព្យាក្រិត្យភាព និងឯករាជ្យ ឬ ហ្ស៊ីនស៊ីនប៊ីច ចំណែកលោក សឺន សាន ដែលជាអតីតនាយករដ្ឋមន្ត្រីនៅសម័យទសវត្សឆ្នាំ ១៩៦0 បានដឹកនាំក្រុមរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ។

ពីឆ្នាំ ១៩៧៩ រហូតដល់ទសវត្សទី ១៩៨0 ទាំងមូល សហរដ្ឋអាមេរិករួម

the last of the U.S. presence left the country. A movie released in 1984 changed all of that and catapulted images of Pol Pot's Cambodia – the labor camps, the child soldiers, the executions – into the American consciousness.

The Killing Fields depicted the true story of the relationship between New York Times reporter Sydney Schanberg and his Cambodian stringer, Dith Pran, as they covered the war between Lon Nol and Khmer Rouge forces in the mid-1970s. In the film as in real life, Schanberg manages to escape Cambodia after the Khmer Rouge took Phnom Penh, but Pran is captured and is sent to successive labor camps in the countryside, an ordeal he manages to survive. The film won three Academy Awards. As a result of its popularity and emotional power, American charities raised millions of dollars in support of victims of the Khmer Rouge.

Americans also began to encounter survivors of the Khmer Rouge in their cities and neighborhoods. Throughout the 1980s, the U.S. government settled 150,000 Cambodian refugees in cities across the country. Large Cambodian-American communities took root in places such as Long Beach, California and Lowell, Massachusetts. As countless immigrants to the United States had done before them, Cambodian-Americans adapted to the way of life in their new home while retaining their distinct cultural identity.

Meanwhile, back in Cambodia the stalemate between the PRK and the anti-government resistance groups showed no sign of resolution. Fighting between the two sides reached a sort of equilibrium, with the insurgency advancing east from the border region during the wet season, and PRK and Vietnamese troops reclaiming lost ground during the dry season. Despite the continued fighting, the Cambodian economy was gradually recovering, due largely to the reemergence of small-scale trading. In addition, Cambodians were reviving traditional family and Buddhist practices lost during the Khmer Rouge.

The United States remained committed to supporting the non-

ជាមួយនឹងប្រទេសចិន សមាគមអាស៊ាន និងប្រទេសដទៃទៀត បានបោះឆ្នោតអោយ ក្រុមចំរុះដែលប្រឆាំងនឹងរដ្ឋាភិបាលក្រុងភ្នំពេញ អោយកាន់កាប់អាសនៈនៅអង្គការ សហប្រជាជាតិ។ សហរដ្ឋអាមេរិកបានលើកហេតុផលថា រដ្ឋាភិបាល សាធារណរដ្ឋ ប្រជាមានិតកម្ពុជាមានភាពខុសច្បាប់ ដោយសារនេះជារដ្ឋាភិបាលដែលត្រូវបានបន្ទុប ឡើងដោយការលុកលុយ របស់បរទេស ហើយថាវាត្រឹមត្រូវទៅនឹងច្បាប់អន្តរជាតិ ដែលត្រូវផ្តល់កៅអីទៅអោយរដ្ឋាភិបាលមុន។

ទោះបីរដ្ឋាភិបាលសហរដ្ឋអាមេរិកមានការពាក់ព័ន្ធជាបន្តក្នុងរឿងប្រទេស កម្ពុជាក្តី តែជនជាតិអាមេរិកបានដឹងមិនច្រើនទេ នូវអ្វីដែលបានកើតឡើងក្រោយឆ្នាំ ១៩៧៥ ជាឆ្នាំដែលសហរដ្ឋអាមេរិកមានវត្តមានជាចុងក្រោយនៅប្រទេសកម្ពុជា។ ភាពយន្តដែលបានចេញនៅឆ្នាំ ១៩៨៤ បានផ្លាស់ប្តូរការមិនដឹងមិនលឺទាំងនេះ ហើយ បានធ្វើអោយពួកគេមើលឃើញរូបភាពនៃប្រទេសកម្ពុជាក្រោមរបប ប៉ុលពត ដែល មានដូចជាជំរំធ្វើពលកម្ម ទាហានកុមារ និងការកាប់សំលាប់មនុស្សជាដើម។

ខ្សែភាពយន្តដែលមានចំណងជើងថា វាលពិឃាតរៀបរាប់រឿងពិតនៃ ទំនាក់ទំនងរវាងលោក Sydney Schanberg ដែលជាអ្នកយកព័ត៌មានអោយកាសែត New York Times និងអ្នកយកព័ត៌មានរបស់គាត់ គឺលោក ឌីត ប្រាន ក្នុងពេលពួកគេ យកព័ត៌មានស្តីពីសង្គ្រាមរវាងកងទ័ពលន់ ណុល និងកងទ័ពខ្មែរក្រហមនៅពាក់ កណ្តាលទសវត្សទី ១៩៧0 ។ នៅក្នុងខ្សែភាពយន្តក៏ដូចជាក្នុងជីវិតពិតដែរ លោក Schanberg បានគេចចេញពីប្រទេសកម្ពុជា បន្ទាប់ពីពួកខ្មែរក្រហមបានចូលកាន់កាប់ ក្រុងភ្នំពេញ តែលោក ប្រាន ត្រូវបានចាប់ខ្លួនហើយត្រូវបានបញ្ជូនទៅជំរំធ្វើពលកម្ម ពីមួយទៅមួយ នៅតាមជនបទ ។ លោកបានរួចជីវិតពីស្ថានភាពដ៏លំបាកនោះ។ ខ្សែ ភាពយន្តនេះឈ្នះរង្វាន់ភាពយន្ត Academy ចំនួន ៣ ។ ដោយសារការចូលចិត្ត និង មនោសញ្ចេតនាខ្លាំងក្លាចំពោះភាពយន្តនេះ អង្គការមនុស្សធម៌របស់អាមេរិកបានរៃ អង្គាសប្រាក់បានរាប់លានដុល្លាសំរាប់ជួយជនរងគ្រោះដោយពួកខ្មែរក្រហម។

ជនជាតិអាមេរិកក៏បានចាប់ផ្តើមជួបអ្នករងគ្រោះដោយរបបខ្មែរក្រហម នៅ តាមទីក្រុងនិងសង្កាត់រស់នៅរបស់គេ។ ក្នុងទសវត្សទី ១៩៨0 ទាំងមូល រដ្ឋាភិបាល សហរដ្ឋអាមេរិកបានទទួលយកជនភៀសខ្លួនខ្មែរចំនួន ១៥0 000 នាក់អោយទៅតាំង ទីលំនៅនៅតាមទីក្រុងនានាទូទាំងប្រទេសអាមេរិក។ សហគមន៍ខ្មែរធំៗបានចាក់ឫស នៅតាមកន្លែងនានា ដូចជានៅ Long Beach California Lowell និងនៅ Massachusetts ជាដើម។ ដូចជនអន្តោប្រវេសន៍ជាច្រើន ដែលបានទៅតាំងទីលំនៅ

communist resistance groups. In February and March of 1985, U.S. Representative Stephen Solarz, a Democrat from New York with a keen interest in developments in Cambodia, attempted to change the nature of U.S. support for these groups. Solarz proposed a $5 million package of overt, non-lethal aid; direct U.S. support for the groups up to that point had been covert and non-lethal, at $12 million per year.

On May 15, the Senate approved a version of Solarz' proposal. The House of Representatives then voted to pass the legislation in July, and President Reagan signed the bill on August 8, 1985. For the first time, U.S. non-lethal aid to the non-communist resistance would be overt, reaching a total of $15 million over the next three years.

As U.S. aid to the non-communist resistance increased in size and visibility, the Vietnamese government began to realize that it could no longer afford its costly occupation of Cambodia. Convinced that the PRK could resist a Khmer Rouge takeover without outside help, Vietnam announced in 1988 that it was planning to withdraw its forces from the country.

In February 1989, negotiations were held in Indonesia. Following the meeting, the PRK announced that Vietnam would withdraw by the end of September 1989, even if a political agreement was not reached. Negotiations continued at a conference in Paris in June 1989; although hopes remained high, the participants still did not reach a settlement.

On September 21, 1989, Vietnam began its final withdrawal of troops from Cambodia. However, Cambodia remained divided, and the United States joined the international community in a final push to end the conflict. In October 1989, Representative Solarz conferred with Australian Foreign Minister Gareth Evans about administering the country and holding elections. The following month, Evans presented his plan, which included significant input from Solarz and Prince Sihanouk.

Evans' proposal called for the UN to provide interim authority until na-

ក្នុងសហរដ្ឋអាមេរិក នៅមុនពួកគេដែរ ជនជាតិអាមេរិកមានដើមកំណើតខ្មែរមានការសំរបខ្លួនទៅនឹងជីវិតរស់នៅថ្មីរបស់គេ តែនៅរក្សាអត្តសញ្ញាណវប្បធម៌ដោយឡែករបស់គេដដែល។

ទន្ទឹមនឹងនោះ នៅប្រទេសកម្ពុជា ភាពគ្មានច្រកចេញរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងក្រុមតស៊ូប្រឆាំងនឹងរដ្ឋាភិបាលមិនមានសញ្ញាណាមួយថយចុះទេ។ ការប្រយុទ្ធគ្នារវាងភាគីទាំងសងខាងបានឈានដល់ចំណុចមានតុល្យភាពគ្នា ដោយពួកតស៊ូឡើងមកភាគខាងកើត ចេញពីតំបន់ព្រំដែននៅរដូវវស្សា ហើយកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាម បានដណ្តើមទឹកដីដែលបានបាត់បង់យកមកវិញនៅរដូវប្រាំង។ ទោះបីការប្រយុទ្ធគ្នានៅតែមានជាបន្តក្តី តែសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានបន្តងើបឡើងវិញ ភាគច្រើនបណ្តាលមកពីការចាប់មានឡើងវិញនូវការជួញដូរតូចតាច។ លើសពីនេះទៀត ប្រជាជនខ្មែរបានធ្វើអោយរស់ឡើងវិញនូវទំលាប់តាមព្រះពុទ្ធសាសនា និងតាមប្រពៃណី ដែលត្រូវបានបាត់បង់ក្នុងសម័យខ្មែរក្រហម។

សហរដ្ឋអាមេរិកនៅតែមានការប្តជ្ញាចិត្តក្នុងការជួយដល់ក្រុមតស៊ូមិនមែនកុំម្មុយនិស្តដដែល។ នៅខែកុម្ភៈនិងខែមិនា ឆ្នាំ១៩៨៥ លោកសមាជិកសភាគណបក្សប្រជាធិបតេយ Stephen Solarz មកពីរដ្ឋញ្ជីយ៉ក មានការចាប់អារម្មណ៍យ៉ាងខ្លាំងលើការវិវត្តន៍នៅក្នុងប្រទេសកម្ពុជា និងមានបំណងប្តូរលក្ខណៈនៃជំនួយ របស់សហរដ្ឋអាមេរិកចំពោះក្រុមទាំងនេះ។ លោកបានស្នើសុំកញ្ចប់ជំនួយចំនួន ៥ លានដុល្លា ដែលជាជំនួយមិនមែនអាវុធនិង ដោយចំហ ។ ជំនួយដោយផ្ទាល់របស់សហរដ្ឋអាមេរិកចំពោះក្រុមតស៊ូទាំងនោះ នៅមុនពេលពេលនោះត្រូវបានលាក់កំបាំង ហើយជាជំនួយមិនមែនអាវុធ ដែលមានតំលៃជាទឹកប្រាក់ចំនួន ១២ លានដុល្លាក្នុងមួយឆ្នាំ។

នៅថ្ងៃទី ១៥ ខែឧសភា ព្រឹទ្ធសភាអាមេរិកបានអនុម័តលើសំណើរបស់លោក Solarz ។ សភាតំណាងរាស្ត្របានបោះឆ្នោតអនុម័តលើច្បាប់នោះនៅខែកក្កដា ហើយលោកប្រធានាធិបតី Reagan បានចុះហត្ថលេខាលើច្បាប់នោះនៅថ្ងៃទី៨ ខែសីហា ឆ្នាំ ១៩៨៥។ ជាលើកដំបូង ជំនួយមិនមែនអាវុធរបស់សហរដ្ឋអាមេរិកដល់ក្រុមតស៊ូមិនមែនកុំម្មុយនិស្តមានភាពបើកចំហ ហើយបានឡើងដល់ចំនួនសរុប ១៥ លានដុល្លាក្នុងរយៈពេល ៣ ឆ្នាំក្រោយមក។

នៅពេលដែលជំនួយរបស់សហរដ្ឋអាមេរិកចំពោះក្រុមតស៊ូមិនមែនកុំម្មុយនិស្តមានទំហំកាន់តែធំ ហើយបើកចំហកាន់តែខ្លាំង រដ្ឋាភិបាលវៀតណាម

tional elections could be held. The stage was set for the United Nations Transitional Authority in Cambodia – the most expensive peacekeeping effort undertaken by the UN – and Cambodia's first democratic elections.

ចាប់ផ្តើមដឹងថា ខ្លួនមិនមានថវិកាសំរាប់បន្តការកាន់កាប់ដែលត្រូវការចំណាយច្រើន នៅប្រទេសកម្ពុជាបានទៀតនោះទេ។ ដោយដឹងច្បាស់ថា របបសាធារណរដ្ឋប្រជាមានិតកម្ពុជាអាចទប់មិនអោយពួកខ្មែរក្រហមវិលត្រឡប់មកវិញបាន ដោយមិនបាច់មានជំនួយពីខាងក្រៅ វៀតណាមបានប្រកាសនៅឆ្នាំ ១៩៨៨ ថា ខ្លួនមានផែនការដកកងកំលាំងរបស់ខ្លួនចេញពីប្រទេសកម្ពុជា។

នៅខែកុម្ភៈ ឆ្នាំ ១៩៨៩ ការចរចាត្រូវបានធ្វើនៅប្រទេសឥណ្ឌូនេស៊ី។ បន្ទាប់ពីកិច្ចប្រជុំនោះ សាធារណរដ្ឋប្រជាមានិតកម្ពុជាបានប្រកាសថា វៀតណាមនឹងដកកងទ័ពចេញនៅត្រឹមដំណាច់ខែកញ្ញា ឆ្នាំ ១៩៨៩ បើទោះបីជាមិនមានការព្រមព្រៀងផ្នែកនយោបាយក្តី។ ការចរចាបានបន្តនៅក្នុងសន្និសីទក្រុងប៉ារីស នៅខែមិថុនា ឆ្នាំ ១៩៨៩ ។ បើទោះបីជាមានការសង្ឃឹមច្រើនក្តី ក៏ភាគីចូលរួមនៅតែមិនបានឈានដល់កិច្ចព្រមព្រៀងដដែល។

នៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ១៩៨៩ វៀតណាមបានដកកងទ័ពចុងក្រោយរបស់ខ្លួនចេញពីប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក្តី ក៏ប្រទេសកម្ពុជានៅតែមានការមិនត្រូវគ្នាដដែល ហើយសហរដ្ឋអាមេរិកបានរួមជាមួយសហគមន៍អន្តរជាតិក្នុងការប្រឹងប្រែងចុងក្រោយ ដើម្បីបញ្ចប់ជំលោះ។ នៅខែតុលា ឆ្នាំ ១៩៨៩ លោកតំណាងរាស្ត្រ Solarz បានពិភាក្សាគ្នាជាមួយលោករដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី Gareth Evans អំពីការគ្រប់គ្រងប្រទេសនិងការចាត់ចែងការបោះឆ្នោត។ នៅខែបន្ទាប់ លោក Evans បានបង្ហាញផែនការរបស់លោក ដោយមានការណែនាំច្រើនពីលោក Solarz និងសម្តេចសីហនុ។

សំណើរបស់លោក Evans អំពាវនាវអោយអង្គការសហប្រជាជាតិផ្តល់អាជ្ញាធរបណ្តោះអាសន្ន រហូតដល់មានការបោះឆ្នោតជាតិរួច។ ការរៀបចំត្រូវបានកំណត់ឡើងសំរាប់អោយមានអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ដែលនោះគឺជាការងារថែរក្សាសន្តិភាពដែលត្រូវធ្វើការចំណាយច្រើនបំផុតរបស់អង្គការសហប្រជាជាតិ ហើយក៏ជាការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យលើកដំបូងនៅកម្ពុជាផងដែរ ។

The American flag is raised at the newly opened embassy after diplomatic ties between the United States and Cambodia are restored.

ទង់ជាតិអាមេរិកត្រូវបានបង្ហូតឡើង នៅស្ថានទូត ដែលទើបតែបើកថ្មី បន្ទាប់ពីទំនាក់ទំនងការទូតរវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជា ត្រូវបានស្តារឡើងវិញ។

1990s

- 1991: Prince Norodom Sihanouk returns to Cambodia after 13 years of exile
- 1991: The United States restores diplomatic relations with Cambodia, ends economic sanctions, and resumes development assistance
- 1992: UNTAC takes over administration of Cambodia
- 1993: Cambodia holds its first democratic election
- 1998: Pol Pot dies, marking the end of the Khmer Rouge

- ឆ្នាំ ១៩៩០: សម្តេច នរោត្តម សីហនុបានត្រលប់មកប្រទេសកម្ពុជាវិញបន្ទាប់ពីនៅនិរទេសអស់រយៈពេល ១៣ ឆ្នាំ
- ឆ្នាំ ១៩៩១: សហរដ្ឋអាមេរិកបានស្តារទំនាក់ទំនងការទូតជាមួយកម្ពុជាឡើងវិញ បញ្ចប់ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ហើយបន្តផ្តល់ជំនួយអភិវឌ្ឍន៍ឡើងវិញ
- ឆ្នាំ ១៩៩២: អ៊ុនតាក់បានចូលគ្រប់គ្រងប្រទេសកម្ពុជា
- ឆ្នាំ ១៩៩៣: ប្រទេសកម្ពុជាធ្វើការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យជាលើកដំបូង
- ១៩៩៨: ប៉ុលពតបានស្លាប់ ដែលជាការកត់សំគាល់ការរលំរលាយនៃពួកខ្មែរក្រហម

When the 1990s began, Cambodia was still a country divided by civil war, yet by the end of the decade it would finally see an end to nearly 30 years of armed conflict. The country would reach several milestones during the period: it would hold its first democratic elections, it would witness the demise of the Khmer Rouge as a military and political force, and it would welcome the return of Prince Norodom Sihanouk to Phnom Penh after 13 years in exile.

U.S. relations with Cambodia improved steadily over the course of the 1990s, culminating in the reestablishment of diplomatic relations and the re-instatement of U.S. development assistance. These changes came about largely because of major shifts in the geopolitical landscape and persistent negotiations by all of the parties with a stake in Cambodia's future.

In late 1989, the Berlin Wall fell, effectively ending the Cold War and creating space for a breakthrough in Cambodia. On January 2, 1990, U.S. Secretary of State James Baker asked the five permanent members of the UN SecurityCouncil – the United States, Great Britain, France, China and the Soviet Union – to convene on the Cambodia issue. A series of meetings followed in New York and Paris. The U.S. position in these talks was that the UN should have authority over Cambodia during a transition period that would precede national elections and the formation of a new government.

The first meeting took place on January 15 in Paris. John Bolton, U.S. Assistant Secretary of State for International Organizations, and Richard Solomon, U.S. Assistant Secretary of State for East Asian and Pacific Affairs, presented a chronology for transferring authority to the UN and preparing for elections.

All five countries involved in the talks agreed to a plan that would see Prime Minister Hun Sen's government retain control of its technical agencies but transfer administration of its ministries to the UN. At a second meeting in New York in February, the five permanent members discussed disarming the various warring factions, but a peace deal

ជាមួយនឹងការចាប់ផ្តើមនៃទសវត្សទី ១៩៩0 ប្រទេសកម្ពុជានៅតែមានការបែកបាក់គ្នា ដោយមានសង្គ្រាមស៊ីវិលតែនៅដំណាច់ទសវត្សនោះ ដំលោះប្រដាប់អាវុធដែលមានចំណាស់ជិត ៣0 ឆ្នាំនោះបានចប់។ ក្នុងអំឡុងពេលនោះប្រទេសកម្ពុជាមានព្រឹត្តិការណ៍សំខាន់ៗជាប្រវត្តិសាស្ត្រមួយចំនួន គឺការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យជាលើកដំបូង ការរលំរលាយទៅនៃពួកខ្មែរក្រហម ទាំងកំលាំងយោធាទាំងកំលាំងនយោបាយ និងការស្វាគមន៍ត្រឡប់មកវិញរបស់សម្តេច ព្រះនរោត្តម សីហនុ មកភ្នំពេញវិញបន្ទាប់ពីការនិរទេសអស់រយៈពេល ១៣ ឆ្នាំមក។

ទំនាក់ទំនងរវាងសហរដ្ឋអាមេរិកនិងកម្ពុជាមានភាពល្អឡើងជាលំដាប់ នៅក្នុងអំឡុងទសវត្សទី ១៩៩0 ដោយមានការបង្កើតអោយមានឡើងវិញនូវទំនាក់ទំនងការទូត និងការធ្វើអោយមានឡើងវិញនូវជំនួយអភិវឌ្ឍន៍របស់សហរដ្ឋអាមេរិក។ បុព្វហេតុសំខាន់នៃការប្រែប្រួលទាំងនេះគឺការប្រែប្រួលធំៗនៃទិដ្ឋភាពផ្នែកភូមិសាស្ត្រនយោបាយក្នុងគោលនយោបាយការបរទេស និងការចរចាដែលមានជាបន្តរបស់ភាគីទាំងអស់ដែលមានការពាក់ព័ន្ធនឹងអនាគតនៃប្រទេសកម្ពុជា។

នៅចុងឆ្នាំ ១៩៨៩ របងទីក្រុងប៊ែរឡាំងត្រូវបានរំលំដែលនាំអោយចប់សង្គ្រាមត្រជាក់ ហើយផ្តល់ឱកាសសំរាប់ធ្វើការទំលាយភាពទាល់ច្រកនៅកម្ពុជា។ នៅថ្ងៃទី ២ ខែមករា ឆ្នាំ ១៩៩0 លោករដ្ឋមន្ត្រីការបរទេសអាមេរិក James Baker បានសុំអោយសមាជិកអចិន្ត្រៃយ៍ទាំង ៥ នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលមានសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស ប្រាំង ចិន និងសហភាពសូវៀត ធ្វើការកោះប្រជុំស្តីពីបញ្ហាប្រទេសកម្ពុជា។ បន្ទាប់មក មានការប្រជុំជាបន្តបន្ទាប់នៅទីក្រុងញ្យ៉ក និងប៉ារីស។ គោលជំហររបស់សហរដ្ឋអាមេរិកក្នុងកិច្ចពិភាក្សាទាំងនេះគឺថា អង្គការសហប្រជាជាតិគួរមានអំណាចលើប្រទេសកម្ពុជា នៅក្នុងអំឡុងពេលអន្តរកាលនៅមុនពេលបោះឆ្នោតជាតិ និងការបង្កើតរដ្ឋាភិបាលថ្មី។

ការប្រជុំលើកដំបូងត្រូវបានធ្វើឡើងនៅថ្ងៃទី ១៥ ខែមករា ។ លោក John Bolton ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកទទួលបន្ទុកផ្នែកអង្គការអន្តរជាតិ និងលោក Richard Solomon ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកទទួលបន្ទុកកិច្ចការអាស៊ីខាងកើត និងប៉ាស៊ីហ្វិក បានធ្វើការរៀបរាប់ហូរហែរនូវដំណាក់កាលសំរាប់ការផ្ទេរអំណាចទៅអោយអង្គការសហប្រជាជាតិ និងសំរាប់ការរៀបចំការបោះឆ្នោត។

ប្រទេសទាំង ៥ ដែលបានចូលរួមក្នុងការពិភាក្សាបានយល់ព្រមលើផែនការអោយរដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុនសែន រក្សាការគ្រប់គ្រងលើស្ថាប័ន

remained elusive.

In March 1990, the UN unveiled the United Nations Transitional Authority in Cambodia (UNTAC). It would be the largest and most ambitious UN peacekeeping operation up to that point, with an estimated price tag of $1.5 billion. The plan laid out general outlines for an election, and it included the stipulation that refugees must be present in Cambodia to vote.

Meanwhile, a major debate was taking place in the U.S. Congress about President George H.W. Bush's policy toward Cambodia. Representative Chester Atkins, a Democrat from Massachusetts, and Senate Majority Leader George Mitchell, a Democrat from Maine, criticized the Bush policy of supporting the non-communist resistance. The Congressmen contended that supporting the resistance groups was immoral because they were part of a coalition that included the Khmer Rouge.

Atkins took his argument to a national audience on a special ABC News report by Peter Jennings on April 26, 1990. During the program, Atkins made the case that the United States was tolerating the Khmer Rouge and that this policy could result in the communist rebels returning to power. "We're still fighting the Vietnam War, and this is the last battle of that war, and if we have to use the Khmer Rouge as a pawn in that we'll use them," he said. "We don't appreciate that we're being used by the Khmer Rouge rather than the other way around."

The report created a storm in political circles and the American public, with both The New York Times and The Washington Post running editorials condemning the Bush policy. Seizing the momentum, in June Atkins proposed an amendment to cut all aid to the anti-government resistance and instead provide $10 million in support of peace talks.

Representative Stephen Solarz, a Democrat from New York long engaged in the Cambodia issue, argued against the amendment, contending that no U.S. support had reached the Khmer Rouge. A large majority of members of the U.S. House of Representatives agreed and

បច្ចេកទេសរបស់ខ្លួន តែផ្ទេរការគ្រប់គ្រងរដ្ឋបាលនៃក្រសួងរបស់ខ្លួនទៅអោយអង្គការសហប្រជាជាតិ។ ក្នុងការប្រជុំលើកទី ២ នៅទីក្រុងញូយ៉ក នៅខែកុម្ភៈ សមាជិកអចិន្ត្រៃយ៍ទាំង ៥ បានពិភាក្សាគ្នាពីការដកអាវុធពីបណ្តាក្រុមដំណោះតែកិច្ចព្រមព្រៀងសន្តិភាព នៅតែមិនទាន់បានឈានដល់ទេ។

នៅខែមិនា ឆ្នាំ ១៩៩0 អង្គការសហប្រជាជាតិបានបង្ហាញអាជ្ញាធរជាតិបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់)។ វាគឺជាប្រតិបត្តិការថែរក្សាសន្តិភាពធំជាងគេបំផុតរបស់អង្គការសហប្រជាជាតិ ដោយគិតមកត្រឹមពេលនោះ មានការចំណាយប្រហែល ១,៥ ពាន់លានដុល្លាអាមេរិក។ ផែនការនោះបានគូសបញ្ជាក់ពីទំនង់ទូទៅសំរាប់ការបោះឆ្នោត តែមានខចែងថា ជនភៀសខ្លួនត្រូវតែមានវត្តមាននៅក្នុងប្រទេស ដើម្បីបោះឆ្នោត។

ទន្ទឹមនឹងនោះ មានការពិភាក្សាធំមួយនៅក្នុងសភាអាមេរិក ស្តីពីគោលនយោបាយរបស់រដ្ឋការ លោកប្រធានាធិបតី George H.W. Bush ចំពោះប្រទេសកម្ពុជា។ សមាជិកសភាតំណាងរាស្ត្រ Chester Atkins ខាងគណបក្សប្រជាធិបតេយ្យមកពីរដ្ឋ Massachusetts និងមេដឹកនាំសំលេងភាគច្រើនក្នុងព្រឹទ្ធសភាគឺលោក George Mitchell ខាងគណបក្សប្រជាធិបតេយ្យមកពីរដ្ឋ Maine បានរិះគន់គោលនយោបាយរបស់លោកប្រធានាធិបតី Bush ក្នុងការជួយក្រុមអ្នកតស៊ូមិនមែនកុំម្មុយនិស្ត។ សមាជិកសភាទាំងនោះបានអះអាងថា ការជួយគាំទ្រដល់ក្រុមអ្នកតស៊ូមិនមានភាពត្រឹមត្រូវតាមផ្លូវសីលធម៌ទេ ពីព្រោះពួកគេគឺជាផ្នែកមួយនៃក្រុមចំរុះដែលមានពួកខ្មែរក្រហមក្នុងនោះផងដែរ។

នៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៩0 លោក Atkins បានលាតត្រដាងហេតុផលរបស់លោកអោយទស្សនិកជនទូទាំងប្រទេសបានដឹង តាមរយៈរបាយការណ៍ពិសេសមួយនៅក្នុងកម្មវិធីទូរទស្សន៍ ABC News របស់លោក Peter Jennings នៅក្នុងកម្មវិធីនោះ លោក Atkins បានលើកឡើងថា សហរដ្ឋអាមេរិកកំពុងតែអត់ឱនអោយពួកខ្មែរក្រហម និងថាគោលនយោបាយនេះអាចនាំអោយពួកឧទ្ទាមកុំម្មុយនិស្តត្រឡប់មកកាន់អំណាចវិញ។ លោកបានមានប្រសាសន៍ថា "យើងកំពុងតែប្រយុទ្ធនៅក្នុងសង្គ្រាមវៀតណាមនៅឡើយទេ ហើយនេះគឺជាការប្រយុទ្ធចុងក្រោយនៃសង្គ្រាមនោះ ហើយបើយើងត្រូវប្រើពួកខ្មែរក្រហមធ្វើជាកូនអុកក្នុងនោះ យើងនឹងប្រើពួកគេ។ តែយើងមិនសាទរនឹងការអោយពួកគេប្រើយើងធ្វើជាកូនអុកវិញនោះទេ"។

របាយការណ៍នោះបានធ្វើអោយមានការភ្ញាក់ផ្អើលក្នុងមជ្ឈដ្ឋានអ្នក

voted down the amendment.

Regardless, the U.S. Senate entered the debate. Senator Mitchell and Senator John Danforth, a Republican from Missouri, demanded that the anti-government resistance be removed from Cambodia's UN seat, and that the United States start providing humanitarian aid to Cambodia, open talks with the Phnom Penh government, and state publicly that the Khmer Rouge should have no role in Cambodia's future. A petition that the senators created containing these demands collected more than 60 signatures in Congress.

As a result of this public pressure, the administration reexamined and, ultimately, changed its position. On July 18, 1990, Secretary Baker announced at a news conference that the United States would do everything it could to ensure that the Khmer Rouge never returned to power in Cambodia. In addition, Secretary Baker said that the United States would begin providing aid to Cambodia outside of the border refugee camps, open dialogue with Hun Sen and Vietnam, and reverse its policy of supporting the anti-government resistance occupying Cambodia's UN seat.

This shift in U.S. policy set the stage for a final settlement in August 1990. On August 27 and 28, the five permanent members of the UN Security Council drafted a framework document that called for all parties to endorse a Cambodian Supreme National Council (SNC) that would have Prince Sihanouk as its head and would represent the various factions. It also called for a ceasefire and laid out guidelines for an election. The anti-government resistance and Hun Sen accepted the framework at a meeting in Jakarta in September. However, a cease fire did not occur in practice.

In February 1991, China announced that it would resume military aid to the Khmer Rouge. The United States, in an effort to assure the international community that it would not tolerate the return of Pol Pot to power, suspended all aid to the non-communist resistance because of its cooperation with the Khmer Rouge.

នយោបាយ និងសាធារណមតិអាមេរិក ដោយមានទាំងកាសែត The New York Times និង The Washington Post ចុះបទវិចារណកថាថ្កោលទោសនយោបាយ របស់លោកប្រធានាធិបតី Bush ។ បន្ទាប់ពីនេះទៅ នៅខែមិថុនា លោក Atkins បានស្នើអោយមានការធ្វើវិសោធនកម្ម ដើម្បីកាត់ជំនួយទាំងអស់ដល់ក្រុមអ្នកតស៊ូមិនមែនកុំម្មុយនិស្ត ហើយផ្តល់ថវិកាចំនួន ១០លានដុល្លាអាមេរិកសំរាប់គាំទ្រដល់ការចរចាសន្តិភាពវិញ។

លោកសភាតំណាងរាស្ត្រ Stephen Solarz ដែលមកពីខាងគណបក្ស ប្រជាធិបតេយ្យ ហើយបានធ្វើការជាយូរមកហើយលើបញ្ហាប្រទេសកម្ពុជា បានប្រឆាំងនឹងការធ្វើវិសោធនកម្មច្បាប់នោះ ដោយលោកបានអះអាងថា មិនមានជំនួយណាមួយ របស់សហរដ្ឋអាមេរិកបានធ្លាក់ដល់ដៃរបស់ពួកខ្មែរក្រហមឡើយ។ សមាជិកភាគច្រើន របស់សភាតំណាងរាស្ត្រសហរដ្ឋអាមេរិកបានយល់ស្របហើយបានបោះឆ្នោតប្រឆាំងនឹងវិសោធនកម្មនោះ។

ទោះជាយ៉ាងនេះក្តី ព្រឹទ្ធសភាសហរដ្ឋអាមេរិកចាប់ផ្តើមមានការដេញដោលពីបញ្ហាដូចគ្នានេះ។ លោកព្រឹទ្ធសមាជិក Mitchell និង John Danforth របស់គណបក្សសាធារណរដ្ឋនិយមមកពីរដ្ឋ Missouri បានសុំអោយគេដកក្រុមតស៊ូប្រឆាំងនឹងរដ្ឋាភិបាលចេញពីកៅអីរបស់ប្រទេសកម្ពុជា នៅអង្គការសហប្រជាជាតិ ហើយបានសុំអោយសហរដ្ឋអាមេរិកចាប់ផ្តើមផ្តល់ជំនួយមនុស្សធម៌ដល់ប្រទេសកម្ពុជា បើកការពិភាក្សាជាមួយរដ្ឋាភិបាលក្រុងភ្នំពេញ ហើយបានប្រកាសជាសាធារណៈថា ខ្មែរក្រហមមិនគួរមានតួនាទីអ្វីទាំងអស់ក្នុងអនាគតនៃប្រទេសកម្ពុជា។ ញត្តិស្តីពីការទាមទារនេះ ដែលសមាជិកព្រឹទ្ធសភាទាំងនោះបានរៀបចំឡើងដោយ ប្រមូលបានហត្ថលេខាគាំទ្រចំនួន ៦0 នៅក្នុងសភាអាមេរិក។

ដោយសារមានការគាបសង្កត់បែបនេះជាសាធារណៈ រដ្ឋការរបស់លោកប្រធានាធិបតីបានពិនិត្យមើលឡើងវិញ ហើយនៅទីបំផុតផ្លាស់ប្តូរគោលជំហររបស់ខ្លួន។ នៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ១៩៩0 លោករដ្ឋមន្ត្រីការបរទេស Baker បានប្រកាស ក្នុងសន្និសីទកាសែតមួយថា សហរដ្ឋអាមេរិកនឹងធ្វើអ្វីៗដែលខ្លួនអាចធ្វើបានដើម្បីកុំអោយពួកខ្មែរក្រហមអាចវិលត្រឡប់មកកាន់អំណាចវិញបាន។ លើសពីនេះទៀត លោកបានមានប្រសាសន៍ថា សហរដ្ឋអាមេរិកនឹងចាប់ផ្តើមផ្តល់ជំនួយមកអោយប្រទេសកម្ពុជា នៅក្រៅជុំវិញជនភៀសខ្លួនតាមព្រំដែន បើកការចរចាជាមួយលោកហ៊ុន សែន និងវៀតណាម ប្រែត្រឡប់គោលនយោបាយរបស់ខ្លួនក្នុងការគាំទ្រចលនាតស៊ូ

In June 1991, the SNC and the five permanent members of the Security Council met again but still could not convince the Khmer Rouge – who continued to initiate military offensives against government troops from their strongholds along the Thai border – to accept a peace settlement. The next month, the SNC met in Beijing and agreed to stop receiving arms from foreign sources and to allow the UN to monitor a tentative ceasefire.

The long-awaited diplomatic breakthrough finally occurred in October 1991. At what was dubbed the Paris Conference, all parties signed an historic peace accord. Under the agreement, UNTAC would take charge of the resettlement of 350,000 Cambodian refugees along the Thai border; disarmament of the various factions; preparations for a democratic election; and re-establishment of government institutions.

With the agreement in place, the following month proved to be a momentous one for Cambodia. Sihanouk returned to the country on November 14 after 13 years in exile. He rode from the airport into Phnom Penh in a 1963 Chevrolet Impala convertible with Hun Sen as a large crowd lining the road cheered and waved flags. That month, the city celebrated its first water festival – one of the biggest celebrations on the Khmer calendar – since 1969.

On November 11, the United States opened a liaison office in Phnom Penh and appointed Charles H. Twining as U.S. Representative. The United States also announced that it would end economic sanctions and begin providing aid to Cambodia for the first time in 15 years. By 1992, the U.S. Agency for International Development (USAID) would re-open its permanent mission to Cambodia, and the agency's total budget for the decade would reach $264 million.

With the establishment of a full-scale mission, USAID focused on rebuilding roads destroyed during 30 years of fighting and meeting the basic humanitarian needs of the Cambodian people. Improved health and education services emerged as additional key concerns. U.S.

ប្រឆាំងនឹងរដ្ឋាភិបាល ដែលកំពុងតែកាន់កាប់អាសនៈ របស់ប្រទេសកម្ពុជា នៅអង្គការសហប្រជាជាតិ។

ការផ្លាស់ប្តូរក្នុងគោលនយោបាយរបស់សហរដ្ឋអាមេរិកនេះគឺជាការរៀបចំសំរាប់ដំណោះស្រាយជាស្ថាពរ នៅខែសីហា ឆ្នាំ ១៩៩០។ នៅថ្ងៃទី ២៧ និង ២៨ ខែសីហា សមាជិកអចិន្ត្រៃយ៍ទាំង ៥ របស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ បានព្រៀងឯកសារ ក្របខ័ណ្ឌ ដែលអំពាវនាវអោយគ្រប់ភាគីទាំងអស់យល់ព្រមលើការបង្កើតឧត្តមក្រុមប្រឹក្សាជាតិកម្ពុជា (SNC) ដែលមានសម្តេចសីហនុ ធ្វើជាប្រធាន ហើយតំណាងអោយភាគីផ្សេងៗ។ ឯកសារ ក្របខ័ណ្ឌនោះក៏បានអំពាវនាវផងដែរ អោយមានការឈប់បាញ់គ្នា និងបានដាក់ចេញនូវគោលការណ៍ណែនាំសំរាប់ការ ប្រោះ ឆ្នោត។ ខាងចលនាតស៊ូប្រឆាំងរដ្ឋាភិបាល និងរដ្ឋាភិបាលលោក ហ៊ុន សែន បានទទួលយកក្របខ័ណ្ឌនោះ នៅពេលប្រជុំនៅទីក្រុងហ្សាកាតា នៅខែកញ្ញា។ តែតាមការជាក់ស្តែង មិនមានការឈប់បាញ់គ្នាទេ។

នៅខែកុម្ភៈ ឆ្នាំ ១៩៩១ ប្រទេសចិនបានប្រកាសថា ខ្លួននឹងបន្តជំនួយយោធាឡើងវិញទៅអោយពួកខ្មែរ ក្រហម។ ក្នុងការខំប្រឹងអះអាងចំពោះសហគមន៍អន្តរជាតិ ថា ខ្លួនមិនអត់ឱនចំពោះការ វិលត្រឡប់មកកាន់អំណាចវិញ របស់ប៉ុលពត សហរដ្ឋអាមេរិកបានពន្យាជំនួយទាំងអស់ទៅអោយ ក្រុមអ្នកតស៊ូមិនមែនកុំម្មុយនិស្ត ដោយសារ តែក្រុមនេះ ធ្វើសហប្រតិបត្តិការ ជាមួយ ក្រុមខ្មែរ ក្រហម។

នៅខែមិថុនា ឆ្នាំ ១៩៩១ SNC និងសមាជិកអចិន្ត្រៃយ៍ទាំង ៥ នៃ ក្រុមប្រឹក្សាសន្តិសុខ ( ) ( ) ( )

assistance also paid for 30% of UNTAC's budget and supported UNTAC's mandate of establishing a freely elected government.

By 1992, the full UNTAC presence was in place. Leading the mission was Yasushi Akashi, a senior UN diplomat who was in charge of 16,000 soldiers and 5,000 civilians. Two of these civilian advisors, supervised the opening of Cambodia's first free press since 1972, with newspapers appearing in both Khmer and English. They also created Radio UNTAC, a popular source of unbiased information in Khmer.

The chief goal of UNTAC was to prepare for the upcoming election. The two main contenders were the royalist FUNCINPEC and the CPP.

As the country's first national election approached, the Khmer Rouge sensed that it would not fare well, and so it boycotted the vote and threatened Cambodians who went to the polls with violence. They also began abducting UN personnel involved in election preparations.

Despite the violence, in May 1993, Cambodians turned out in large numbers to seize their first chance at participatory democracy. A remarkable 90% of the population voted, surpassing even the most hopeful of predictions.

FUNCINPEC received 45% of the vote, while the CPP received 38%. Prince Sihanouk announced that he was forming an interim government with Hun Sen and his son Prince Norodom Ranariddh as Deputy Prime Ministers. Although Ranariddh and the United States objected to the plan, two weeks later a government structure emerged in which the CPP and FUNCINPEC shared power, with two minor parties also participating.

In September, the newly formed Constituent Assembly approved a constitution, and Sihanouk was named King. He appointed Ranariddh as First Prime Minister and Hun Sen as Second Prime Minister. UNTAC had accomplished its mission of administering democratic elections and, thus, its mandate ended.

ពីភាគីនានា និងការរៀបចំសំរាប់ការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ ហើយនិងការបង្កើតឡើងវិញនូវស្ថាប័នរដ្ឋាភិបាល។

ដោយមានកិច្ចព្រមព្រៀងហើយ ក្នុងខែបន្ទាប់មក មានព្រឹត្តិការណ៍ដ៏ធំមួយសំរាប់ប្រទេសកម្ពុជា។ សម្តេចព្រះនរោត្តមសីហនុបានយាងត្រឡប់ចូលប្រទេសវិញនៅថ្ងៃទី ១៤ ខែវិច្ឆិកា បន្ទាប់ពីបាននៅនិរទេសអស់រយៈពេល ១៣ ឆ្នាំ។ ព្រះអង្គបានធ្វើដំណើរដោយរថយន្តអត់ដំបូល ម៉ាក Chevrolet Impala ផលិតនៅឆ្នាំ ១៩៦៣ ពីព្រលានយន្តហោះចូលមកក្រុងភ្នំពេញដោយមានហ្វូងមនុស្សជាច្រើនឈរអមសងខាងផ្លូវថ្នល់ ដើម្បីអបអរ និងគ្រវីទង់ជាតិ។ នៅខែនោះក្រុងភ្នំពេញបានអបអរទិវាបុណ្យអ៊ុំទូកជាលើកដំបូង។ បុណ្យនេះស្ថិតក្នុងចំណោមបុណ្យធំជាងគេតាមប្រក្រតីទិនខ្មែរ។

នៅថ្ងៃទី ១១ ខែវិច្ឆិកា ការិយាល័យទំនាក់ទំនងរបស់សហរដ្ឋអាមេរិកបានបើកនៅទីក្រុងភ្នំពេញហើយលោក Charles H. Twining ត្រូវបានតែងតាំងជាតំណាងរបស់សហរដ្ឋអាមេរិក។ សហរដ្ឋអាមេរិកបានក្រាសចាំខ្លួននឹងបញ្ចប់ទណ្ឌកម្មសេដ្ឋកិច្ច ហើយបានចាប់ផ្តើមផ្តល់ជំនួយអោយកម្ពុជាជាលើកដំបូង ក្នុងរយៈពេល ១៥ ឆ្នាំ។ នៅឆ្នាំ ១៩៩២ ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID)បានបើកបេសកកម្មអចិន្ត្រៃយរបស់ខ្លួននៅប្រទេសកម្ពុជាឡើងវិញ ហើយថវិការបស់ USAID សំរាប់ទសវត្សនោះ ជាសរុបឡើងដល់ ២៦៤ លានដុល្លាអាមេរិក។

ជាមួយនឹងការបង្កើតអោយមានឡើងនូវស្ថានបេសកកម្មពេញលេញ USAID បានផ្តោតលើការកសាងឡើងវិញនូវផ្លូវថ្នល់ ដែលត្រូវបានបំផ្លាញក្នុងអំឡុងសង្គ្រាម ៣0 ឆ្នាំកន្លងទៅ និងលើការបំពេញសេចក្តីត្រូវការផ្នែកមនុស្សធម៌ជា មូលដ្ឋានរបស់ប្រជាជនកម្ពុជា។ ការអភិវឌ្ឍន៍ខាងសេវាអប់រំ និងសេវាសុខភាព ក៏ជាកត្តាបន្ថែមដែលត្រូវយកចិត្តទុកដាក់ផងដែរ។ ជំនួយរបស់សហរដ្ឋអាមេរិកថែមទាំងបានគាំទ្រដល់៣0% នៃថវិការបស់អ៊ុនតាក់ ហើយបានជួយដល់អាណត្តិរបស់អ៊ុនតាក់ ក្នុងការធ្វើអោយមានឡើងនូវរដ្ឋាភិបាលមួយតាមការបោះឆ្នោតដោយសេរី។

មកដល់ត្រឹមឆ្នាំ ១៩៩២ អ៊ុនតាក់មានវត្តមានពេញ បន្ទុកនៅប្រទេសកម្ពុជា។ លោក Yasushi Akashi ដែលជាអ្នកការទូតជាន់ខ្ពស់របស់អង្គការសហប្រជាជាតិ គឺជាប្រមុខបេសកកម្មនោះ ដោយទទួលបន្ទុកលើទាហាន ចំនួន ១៦ 000 នាក់ និងបុគ្គលិកស៊ីវិលចំនួន ៥ 000 នាក់។ ទីប្រឹក្សាផ្នែកស៊ីវិលពីរនាក់ បានគ្រប់គ្រងការបើកផ្នែកសារព័ត៌មានសេរីលើកដំបូងនៅប្រទេសកម្ពុជា បើគិតតាំងពីឆ្នាំ ១៩៧២ មក

On September 24, 1993, the United States and the Kingdom of Cambodia established full diplomatic relations. The U.S. Mission was upgraded in status to a full Embassy, and on May 17, 1994, U.S. Representative Charles H. Twining presented his credentials as U.S. Ambassador.

Although a new government was in place, fears again surfaced in 1994 that the Khmer Rouge would re-emerge as a force in Cambodia. In response, the United States sent advisors to assist the Cambodian military, and the United States also protested Thailand's continued support of the Khmer Rouge. That same year, the U.S. Congress passed the Cambodian Genocide Justice Act, which officially endorsed a trial to hold Khmer Rouge leaders accountable for their crimes.

Although the Khmer Rouge continued to worry the international community, U.S. assistance was a major factor in slowly weakening the rebels. According to many experts, the U.S. focus on building and refurbishing roads helped undermine the Khmer Rouge because it ended the isolation of populations living in areas the rebels controlled.

The highest-profile of these road projects was the reconstruction of National Road 4, which was originally built by the United States in the 1950s and ran from Phnom Penh to the country's only deep-water port, Sihanoukville. U.S. assistance also upgraded Highway 10 to Pailin, a Khmer Rouge stronghold, spurring trade in the area. In 1996, Khmer Rouge units rebelled against Pol Pot after he ordered people living in the area to stop trading with outsiders. There were signs that the movement was losing its resolve.

Although the Khmer Rouge continued to carry out military campaigns, its members were beginning to defect to the government. The highest-profile of these defections occurred in 1996, when Ieng Sary, former Foreign Minister under Pol Pot, defected and in return was granted control of Pailin as provincial leader. Another Khmer Rouge leader, Son Sen, also began negotiating with the government about a defection.

ដោយមានការសែតចេញជាភាសាខ្មែរ និងអង់គ្លេស។ លោកទាំងពីរនាក់ថែមទាំងបានបង្កើតវិទ្យុអ៊ីនតាក់ ដែលជាប្រភពមានគេចូលចិត្តច្រើន ក្នុងការផ្តល់ព័ត៌មានដោយមិនលំអៀងជាភាសាខ្មែរ។

គោលបំណងធំរបស់អ៊ីនតាក់គឺរៀបចំការបោះឆ្នោត។ គូប្រជែងសំខាន់ពីរគឺ គណបក្សរាជានិយមហ៊ុនសុិនបុិច និង គណបក្សប្រជាជនកម្ពុជា។

នៅពេលការបោះឆ្នោតជាតិលើកដំបូងកាន់តែខិតជិតមកដល់ក្រុមខ្មែរក្រហមដឹងថា គេមិនអាចឈ្នះបានទេ ហើយបានធ្វើពហិការការបោះឆ្នោត ហើយគំរាមប្រើហឹង្សាលើអ្នកទៅបោះឆ្នោត។ ពួកគេថែមទាំងបានចាប់ជីវិតបុគ្គលិករបស់អង្គការសហប្រជាជាតិ ដែលធ្វើការរៀបចំការបោះឆ្នោត។

ទោះបីជាមានអំពើហឹង្សាក្តី ក៏នៅ ខែឧសភា ឆ្នាំ ១៩៩៣ ប្រជាជនកម្ពុជាក្នុងចំនួនច្រើនបាននាំគ្នាចេញទៅឆក់យកឱកាសដំបូងរបស់គេ ក្នុងការចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ។ ប្រជាជនចំនួន ៩0% បានទៅបោះឆ្នោត ដែលជាការមានលើសពីការព្យាករណ៍ប្រកបដោយសុទិដ្ឋិនិយមបំផុត។

គណបក្សហ៊ុនសុិនបុិចបានទទួលសំលេងឆ្នោតចំនួន ៤៥% ចំណែកគណបក្សប្រជាជនបានទទួលសំលេងឆ្នោតចំនួន៣៨%។ សម្តេចព្រះនរោត្តមសីហនុបានប្រកាសថា ព្រះអង្គនឹងបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ ដោយមានលោក ហ៊ុនសែន និងព្រះអង្គម្ចាស់ នរោត្តមរណឫទ្ធិ ដែលជាបុត្ររបស់ព្រះអង្គ ធ្វើជាឧបនាយករដ្ឋមន្ត្រី។ ទោះបីជាព្រះអង្គម្ចាស់ នរោត្តមរណឫទ្ធិ និងសហរដ្ឋអាមេរិកបានជំទាស់ទៅនឹងផែនការនោះក្តី ក៏រយៈពេល ២ សប្តាហ៍ក្រោយមក រចនាសម្ព័ន្ធរដ្ឋាភិបាលមួយបានកើតឡើង ដោយគណបក្សប្រជាជន និង គណបក្សហ៊ុនសុិនបុិចចែកអំណាចគ្នា ដោយមានគណបក្សតូចពីរទៀតបានចូលរួមផងដែរ។

នៅខែកញ្ញា សភាធម្មនុញ្ញដែលទើបតែត្រូវបាន បង្កើត ថ្មី បានអនុម័តលើរដ្ឋធម្មនុញ្ញ ហើយសម្តេចព្រះនរោត្តមសីហនុ បានឡើងគ្រងរាជ្យសម្បត្តិជាព្រះមហាក្សត្រ។ ព្រះអង្គបានតែងតាំងព្រះអង្គម្ចាស់ នរោត្តមរណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី ១ ហើយលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទី ២។ អ៊ីនតាក់បានបំពេញភារកិច្ចរបស់ខ្លួនក្នុងការចាត់ចែងការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ ហើយបន្ទាប់ពីនេះ អាណត្តិរបស់ខ្លួនក៏បានចប់។

នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ សហរដ្ឋអាមេរិកនិងព្រះរាជាណាចក្រកម្ពុជាបានបង្កើតទំនាក់ទំនងការទូតពេញលេញជាមួយគ្នា។ បេសកកម្មរបស់សហរដ្ឋ

Unfortunately for him, Pol Pot got wind of his plan and ordered him and his family executed.

On March 28, 1996, Kenneth M. Quinn presented his credentials as U.S. Ambassador. Quinn had been a Foreign Service Officer in Indochina during the war, and in the mid-1970s he was one of the first outside observers to document the existence and brutal nature of the Khmer Rouge.

In 1997, the situation in Cambodia – and U.S.-Cambodian relations – took a turn for the worse. On March 30, several grenades exploded at a rally for opposition politician Sam Rainsy, killing 16 and wounding more than 100. One of the wounded was an American, Ron Abney. As a result of the injuries to the American, the FBI launched an investigation into the attack but was unable to identify the perpetrators.

Ambassador Kenneth Quinn presenting his credentials to His Majesty King Sihanouk in a ceremony at the Royal Palace on March 28, 1996.

លោកឯកអគ្គរដ្ឋទូត Kenneth Quinn ថ្វាយសារតាំងជូនព្រះមហាក្សត្រ ព្រះករុណាព្រះបាទ នរោត្តមសីហនុ ក្នុងពិធីមួយនៅព្រះបរមរាជវាំង ក្នុងឆ្នាំ ១៩៩៦។

អាមេរិកត្រូវបាន លើកឋានៈអោយទៅជាស្ថានទូតពេញលេញ ហើយនៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ១៩៩៤ តំណាងរបស់សហរដ្ឋអាមេរិក គឺលោក Charles H. Twining បានថ្វាយសារតាំងជាឯកអគ្គរដ្ឋទូតអាមេរិក។

ថ្មីបើមានរដ្ឋាភិបាលថ្មីហើយក៏ដោយ ក៏គេមានការភ័យខ្លាចម្តងទៀត នៅឆ្នាំ ១៩៩៤ ថា ខ្មែរក្រហមអាចនឹងងើបឡើងម្តងទៀត ជាកំលាំងមួយនៅកម្ពុជា។ ជាការឆ្លើយតប សហរដ្ឋអាមេរិកបានបញ្ជូនទីប្រឹក្សាមកជួយយោធាកម្ពុជា ហើយសហរដ្ឋអាមេរិកថែមទាំងបានតវ៉ាចំពោះការដែលថៃនៅតែបន្តការគាំទ្រដល់ពួកខ្មែរក្រហម។ នៅឆ្នាំដដែលនោះ សភាអាមេរិកបានអនុម័តច្បាប់ស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា (Cambodian Genocide Justice Act) ដែលគាំទ្រជាផ្លូវការដល់ការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលមានការទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់គេ។

ថ្មីបើក្រុមខ្មែរក្រហមបានបន្តធ្វើអោយសហគមន៍អន្តរជាតិមានកង្វល់ក្តី តែជំនួយរបស់សហរដ្ឋអាមេរិកគឺជាកត្តាចំបងក្នុងការធ្វើអោយពួកឧទ្ទាមនេះចុះខ្សោយបន្តិចម្តងៗ។ យោងតាមអ្នកជំនាញជាច្រើន ការដែលសហរដ្ឋអាមេរិកបានផ្តោតលើការកសាង និងជួសជុលផ្លូវថ្នល់បានជួយធ្វើអោយខ្មែរក្រហមអន្តរាយ ពីព្រោះវាបានបញ្ចប់ភាពនៅដាច់តែឯងរបស់ប្រជាជន ដែលរស់នៅក្រោមតំបន់គ្រប់គ្រងរបស់ពួកខ្មែរក្រហម។

គំរោងមួយដែលលេចធ្លោជាងគេក្នុងចំណោមគំរោងទាំងនេះគឺការជួលជុលផ្លូវជាតិលេខ ៤ ដែលត្រូវបានកសាង ឡើងពីដើមមកដោយសហរដ្ឋអាមេរិកក្នុងទសវត្ស ទី ១៩៥0 ពីភ្នំពេញទៅកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់របស់កម្ពុជាគឺ កំពង់ផែក្រុងព្រះសីហនុ។ ជំនួយរបស់អាមេរិកក៏បានកែលំអផងដែរដល់ផ្លូវជាតិលេខ ១0 ទៅក្រុងប៉ៃលិន ដែលជាតំបន់រឹងមាំរបស់ពួកខ្មែរក្រហម ដែលនាំអោយមានកំណើននៃសកម្មភាពជំនួញ ក្នុងតំបន់នោះ។ នៅឆ្នាំ ១៩៩៦ អង្គភាពខ្មែរក្រហមបានងើបបះបោរប្រឆាំងនឹងប៉ុល ពត បន្ទាប់ពីគាត់បានបញ្ជាអោយមនុស្សរស់នៅតំបន់នេះអោយឈប់ធ្វើជំនួញជាមួយអ្នកទៅពីក្រៅ។ មានសញ្ញាថា ចលនានេះកំពុងតែបាត់បង់ទំនុកចិត្ត ប្តេជ្ញារបស់វា។

ថ្មីបើពួកខ្មែរក្រហមបានបន្តយុទ្ធនាការយោធាក្តី តែសមាជិករបស់ខ្លួនកំពុងតែចាប់ផ្តើមចុះចូលមកខាងរដ្ឋាភិបាល។ ករណីចុះចូលធំជាងគេគឺនៅឆ្នាំ១៩៩៦ នៅពេលអ៊ៀង សារី ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសក្រោមរបបប៉ុល ពត បាន

In June, fighting broke out between troops loyal to Hun Sen and Prince Ranariddh. The reasons for the conflict were complex and it is not possible to say with certainty who fired the first shot. Prince Ranariddh had sent one of his generals to meet with Pol Pot in the hope of securing his defection, and Hun Sen had accused the Prince of colluding with the Khmer Rouge, which ratcheted up tensions between the two sides. U.S. officials at the time believed that neither side wanted an armed conflict, but the United States was compelled to evacuate its staff and temporarily suspend aid.

With the 1998 national election on the horizon, the United States helped Cambodia prepare by supporting election monitoring organizations that fielded over 22,000 monitors nationwide. Cambodians went to the polls on July 26, 1998, with more than 93% of all registered voters participating. The CPP won the majority of votes, although it failed to win the two-thirds majority necessary to form a new government.

Tensions remained high and political violence occurred sporadically throughout a four-month deadlock. Then, on November 30, the CPP and FUNCINPEC party formed a coalition government, with Hun Sen as the sole Prime Minister. The National Assembly and a newly formed Senate began operating.

That same year, government forces began their final assault on what was left of the Khmer Rouge.

On April 15, 1998, Pol Pot died of natural causes; his movement, which had inflicted so much misery on Cambodia and its people, perished with him.

As the decade came to a close, the United States restored bilateral development aid. Kent M. Wiedemann presented his credentials as U.S. Ambassador on August 31, 1999. Thirty years of civil war had finally ended, and Cambodians entered the new millennium hopeful for the future and ready to rebuild their country.

ចុះចូល ហើយត្រូវបានផ្តល់អោយនូវការកាន់កាប់តំបន់ខេត្តប៉ៃលិន។ មេដឹកនាំខ្មែរក្រហមម្នាក់ទៀតគឺ សុន សេន ក៏បានចាប់ផ្តើមចរចាជាមួយរដ្ឋាភិបាល ផងដែរ ស្តីពីការចុះចូល។ តែជាអកុសលសំរាប់គាត់ ប៉ុល ពតបានដឹងពីផែនការនេះ ហើយបានបញ្ជាអោយគេសំលាប់គាត់ និងគ្រួសាររបស់គាត់។

នៅថ្ងៃទី ២៨ ខែមិនា ឆ្នាំ ១៩៩៦ លោក Kenneth M. Quinn បានថ្វាយសារតាំងជាឯកអគ្គរដ្ឋទូតអាមេរិក។ លោក Quinn បានធ្វើជាមន្ត្រីផ្នែកសេវាកិច្ចការបរទេស នៅឥណ្ឌូចិនក្នុងសម័យសង្គ្រាម ហើយនៅពាក់កណ្តាលទសវត្សទី ១៩៧0 លោកស្ថិតក្នុងចំណោមអ្នកសង្កេតការណ៍ដំបូងៗទៅពីខាងក្រៅ ដែលបានចងក្រងឯកសារស្តីពីការមាន និងសភាពយោរយៅនៃពួកខ្មែរក្រហម។

នៅឆ្នាំ ១៩៩៧ ស្ថានភាពនៅប្រទេសកម្ពុជា និងទំនាក់ទំនងរវាងសហរដ្ឋអាមេរិកនិងកម្ពុជា មានការធ្លាក់ចុះ។ នៅថ្ងៃទី ៣0 ខែមិនា គ្រាប់បែកដៃមួយចំនួនបានផ្ទុះនៅក្នុងកន្លែងប្រមូលផ្តុំមួយរបស់មេដឹកនាំគណបក្សប្រឆាំង សមរង្ស៊ី ដោយសំលាប់មនុស្សអស់ ១៦ នាក់ ហើយធ្វើអោយរបួសមនុស្សចំនួនជាង ១00 នាក់ទៀត។ ក្នុងចំណោមអ្នករបួសនោះមានលោក Ron Abney ដែលជាជនជាតិអាមេរិក។ ដោយមានការរបួសដល់ជនជាតិអាមេរិក ភ្នាក់ងារស៊ើបអង្កេត FBI បានធ្វើការស៊ើបអង្កេតលើការវាយប្រហារនោះ តែមិនអាចរកឃើញអ្នកវាយប្រហារបានទេ។

នៅខែមិថុនា ការប្រយុទ្ធគ្នាបានផ្ទុះឡើងរវាងកងទ័ព ដែលស្មោះត្រង់នឹងលោក ហ៊ុន សែន និងព្រះអង្គម្ចាស់នរោត្តម រ៉ាណារិទ្ធ។ ហេតុផលនៃជំលោះនោះគឺមានលក្ខណៈស្មុកស្មាញ ហើយក៏គេមិនអាចដឹងច្បាស់ទេថា តើនរណាជាអ្នកបាញ់មុន។ ព្រះ អង្គម្ចាស់រ៉ាណារិទ្ធបានបញ្ជូនឧត្តមសេនីយម្នាក់របស់ព្រះអង្គអោយទៅជួប ប៉ុល ពត ដើម្បីអោយគាត់ចុះចូលមកខាងព្រះអង្គ ហើយលោក ហ៊ុន សែនបានចោទប្រកាន់ព្រះអង្គថាបានឃុបឃិតជាមួយពួកខ្មែរក្រហម ។ ការនេះនាំអោយមានភាពតានតឹងឡើងរវាងភាគីទាំងពីរ ។ ក្នុងពេលនោះមន្ត្រីសហរដ្ឋអាមេរិកជឿថា គ្មានភាគីណាមួយចង់អោយមានជំលោះប្រដាប់អាវុធទេ តែសហរដ្ឋអាមេរិកត្រូវបង្ខំចិត្តជន្លៀសបុគ្គលិករបស់ខ្លួនហើយផ្អាកជំនួយជាបណ្តោះអាសន្ន។

នៅពេលការបោះឆ្នោតឆ្នាំ ១៩៩៨ ជិតមកដល់សហរដ្ឋអាមេរិកបានជួយកម្ពុជាក្នុងការរៀបចំ ដោយជួយអង្គការតាមដានការបោះឆ្នោត ដែលបានបញ្ជូនអ្នកឃ្លាំមើលការបោះឆ្នោតចំនួន ២២ 000 នាក់ នៅទូទាំងប្រទេស។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៩៩៨ ប្រជាជនកម្ពុជាបានទៅបោះឆ្នោត ដោយ ៩៣% នៃអ្នកមានឈ្មោះ

Ambassador Kenneth Quinn visits a former Khmer Rouge stronghold in Phnom Vor, Kampot Province.

លោកឯកអគ្គរដ្ឋទូត គ្នេនតេហ ឈ្វិនន ទៅមើលអតីតទីតាំងរឹងមាំរបស់ខ្មែរក្រហម នៅភ្នំវ៉ែរ ខេត្តកំពត។

ក្នុងបញ្ជីបោះឆ្នោត បានបោះឆ្នោត។ គណបក្សប្រជាជនបានឈ្នះសំលេងភាគច្រើន តែមិនបានឈ្នះដាច់សំលេង ២ ភាគ ៣ សំរាប់បង្កើតរដ្ឋាភិបាលថ្មីបានទេ។

ភាពតានតឹងនៅតែមានច្រើននៅឡើយ ហើយហឹង្សានយោបាយមានកើតឡើងម្តងម្តាល ក្នុងរយៈពេលនៃការដាប់គាំង ៤ ខែនោះ។ បន្ទាប់មក នៅថ្ងៃទី ៣០ ខែវិច្ឆិកា គណបក្ស ប្រជាជន និងគណបក្សហ្ស៊ីនសុិនបុិចបានបង្កើតរដ្ឋាភិបាលចំរុះមួយ ដោយលោក ហ៊ុន សែនធ្វើជានាយករដ្ឋមន្ត្រីតែម្នាក់ឯង។ សភាជាតិ និងព្រឹទ្ធសភា ដែលទើបតែត្រូវបានបង្កើតថ្មី បានចាប់ផ្តើមដំណើរការ ។

នៅក្នុងឆ្នាំដដែលនោះ កំលាំងរដ្ឋាភិបាលបានចាប់ផ្តើម ការវាយប្រហារចុងក្រោយទៅលើអ្វីដែលជាក្រុមនៅសេសសល់ចុងក្រោយរបស់ពួកខ្មែរក្រហម។

នៅថ្ងៃទី ១៥ ខែមេសា ឆ្នាំ ១៩៩៨ ប៉ុល ពតបានស្លាប់ដោយជរាពាធ ។ ចលនារបស់គាត់ ដែលបានធ្វើអោយមានទុក្ខវេទនាយ៉ាងច្រើនទៅលើប្រទេសនិងប្រជាជនកម្ពុជា ក៏បានរលាយរលត់ទៅជាមួយគាត់ដែរ ។

នៅដំណាច់ទសវត្ស សហរដ្ឋអាមេរិកបានផ្តល់ជំនួយ អភិវឌ្ឍន៍ទ្វេភាគីឡើងវិញ។ លោក Kent M. Wiedemann បានថ្វាយសារតាំងជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ ១៩៩៩។ សង្គ្រាមស៊ីវិលដែលមានរយៈពេល ៣០ ឆ្នាំ នៅទីបំផុត ត្រូវបានបញ្ចប់ ហើយប្រជាជនកម្ពុជាបានឈានចូលសហសវត្សថ្មីប្រកបដោយក្តីសង្ឃឹមសំរាប់អនាគត ហើយត្រៀមនឹងកសាងប្រទេសរបស់គេឡើងវិញ។

Ambassador Mussomeli talks with Fulbright grantees, who pursue graduate degrees in the U.S., during a pre-departure orientation in June 2007.

ឯកអគ្គរដ្ឋទូត Mussomeli សំណេះសំណាលជាមួយ និស្សិតទទួលអាហារូបករណ៍ Fulbright ដែលត្រូវទៅសិក្សាថ្នាក់ក្រោយបរិញ្ញា នៅសហរដ្ឋអាមេរិក ក្នុងពេលសំណេះសំណាល និងណែនាំមុនចេញដំណើររបស់ពួកគេ នៅខែមិថុនា ឆ្នាំ២០០៧។

2000s

- The United States supports the development of Cambodia's garment industry
- The United States assists in the restoration of key Angkorean temples, like Phnom Bakheng
- 2003 and 2008: Elections in Cambodia
- 2003: Secretary of State Colin Powell visits Cambodia
- 2006: U.S. Embassy opens in new building
- 2006: Former President Bill Clinton visits Cambodia
- 2007: First Peace Corps volunteers in Cambodia sworn in
- 2009: The Khmer Rouge tribunal begins its first case; the United States provides $16.8 million in support

- សហរដ្ឋអាមេរិកជួយដល់ការអភិវឌ្ឍន៍វិស័យកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- សហរដ្ឋអាមេរិកជួយជួសជុលប្រាសាទសំខាន់ៗនៅអង្គរ ដូចជាប្រាសាទភ្នំបាក់ខែង
- ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៨: ការបោះឆ្នោតនៅកម្ពុជា
- ឆ្នាំ ២០០៣: លោករដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកធ្វើទស្សនកិច្ចនៅកម្ពុជា
- ឆ្នាំ ២០០៦: ស្ថានទូតសហរដ្ឋអាមេរិកបើកសម្ពោធអាគារថ្មី
- ឆ្នាំ ២០០៦: អតីតប្រធានាធិបតីសហរដ្ឋអាមេរិក Bill Clinton ធ្វើទស្សនកិច្ចនៅកម្ពុជា
- ឆ្នាំ ២០០៧: អ្នកស្ម័គ្រចិត្តរបស់ទីភ្នាក់ងារ Peace Corps ក្នុងក្រុមដំបូងបានស្បថសច្ចាប្រណិធានចូលបំពេញការងារ
- ឆ្នាំ ២០០៩: សាលាក្តីកាត់ទោសខ្មែរក្រហមចាប់ផ្តើមដំណើរការលើករណីដំបូង។ សហរដ្ឋអាមេរិកផ្តល់ជំនួយថវិកាចំនួន ១៦,៨ លានដុល្លាអាមេរិក

Ambassador Kent Wiedemann joins Prime Minister Hun Sen at the opening of a bridge in Pursat in 2001.

លោ[illegible]ត្តរដ្ឋទូត Kent Wiedemann ជាមួយ[illegible]ក[illegible]ការ[illegible]ដ្ឋមន្ត្រី ហ៊ុន សែន ក្នុងពេលសម្ពោធស្ពានមួយ នៅខេត្តពោធិ[illegible]ត់ នៅ ឆ្នាំ២០០១។

Cambodia began the new millennium united and at peace for the first time in 30 years. The Khmer Rouge was defeated, the country was stable, and the government could begin working in earnest to address some of the country's biggest challenges, including widespread poverty, poor health and education systems, and the emergence of HIV/AIDS.

At the end of the 1990s, Cambodian Prime Minister Hun Sen was upbeat about the state of U.S.-Cambodian ties. "I feel we have a good relationship compared with the last two decades, in which we seemed to be enemies," he told Time magazine in March 1999. The Prime Minister's words would ring true over the course of the next 10 years, as the two countries further strengthened ties and worked together to tackle issues of mutual concern.

One such issue was how to deal with the surviving leaders of the Khmer Rouge. Although Pol Pot was dead, senior cadres such as Khieu Samphan and Ieng Sary were still alive and residing freely in the

ចូលដល់ដើមសហសវត្សប្រទេសកម្ពុជាមានការ ឯកភាពគ្នា និងមានសន្តិភាពជាលើកដំបូង ក្នុងរយៈពេល ៣០ ឆ្នាំមកនេះ។ ខ្មែរក្រហមបានបរាជ័យ ប្រទេសមានស្ថេរភាព ហើយរដ្ឋាភិបាលបានចាប់ផ្តើមយ៉ាងមុតមាំក្នុងការដោះស្រាយបញ្ហាប្រឈមធំៗខ្លះ ដូចជាភាពក្រីក្រ ស្ថានភាពសុខភាព និងប្រព័ន្ធអប់រំទន់ខ្សោយ ហើយនិងការកើតមានឡើងនូវជំងឺអេដស៍។

នៅចុងទសវត្សទី ១៩៩០ លោកនាយករដ្ឋមន្ត្រី ហ៊ុនសែន មានសុទិដ្ឋិនិយមលើទំនាក់ទំនងរវាងប្រទេសកម្ពុជា និងសហដ្ឋអាមេរិក។ លោកបានថ្លែងទៅកាន់ទស្សនាវដ្ដី Time នៅខែមិនា ឆ្នាំ ១៩៩៩ ថា "ខ្ញុំមានអារម្មណ៍ថា យើងមានទំនាក់ទំនងល្អ បើប្រៀបធៀបនឹងរយៈពេល ២ ទសវត្សមុន ដែលនៅពេលនោះយើងហាក់ដូចជាសត្រូវនឹងគ្នា"។ ប្រសាសន៍របស់លោកនាយករដ្ឋមន្ត្រីហាក់ដូចជាត្រូវ ក្នុងពេល ១០ ឆ្នាំបន្ទាប់មកដោយប្រទេសទាំងពីរបានពង្រឹងទំនាក់ទំនងថែមទៀត ហើយបានធ្វើការជាមួយគ្នា ដើម្បីដោះស្រាយបញ្ហាដែលជាកង្វល់រួម។

បញ្ហាមួយក្នុងចំណោមបញ្ហាទាំងនេះគឺថាតើត្រូវធ្វើយ៉ាងដូចម្តេចចំពោះមេដឹកនាំខ្មែរក្រហមដែលនៅរស់។ ថ្វីបើ ប ុ ល ពត បានស្លាប់ហើយក្តី តែកម្មាភិបាលចាស់ៗ ដូចជាខៀវសំផន និងអៀង សារី នៅមានជីវិតនៅឡើយ ហើយកំពុងរស់នៅដោយមានសេរីភាពនៅក្នុងប្រទេស ដោយទទួលបានការលើកលែងទោសដោយរដ្ឋាភិបាល ជាការប្តូរនឹងការចុះចូលរបស់ពួកគេ។ នៅឆ្នាំ ១៩៩៧ ប្រទេសកម្ពុជាបានបង្កើតក្រុមការងារពិសេស ដើម្បីបង្កើតរចនាសម្ព័ន្ធតុលាការសំរាប់កាត់ ទោសមេដឹកនាំទាំងនេះ ចំពោះអំពើឧក្រិដ្ឋរបស់គេ តែរដ្ឋាភិបាលត្រូវការជំនួយអន្តរជាតិ ដើម្បីដំណើរការកាត់ក្តី។

តាមរយៈការចរចាជាបន្តបន្ទាប់ ដោយមានការចូលរួមរបស់អង្គការសហប្រជាជាតិផង ដោយក្នុងនោះ សហរដ្ឋអាមេរិកដើរតួនាទីនាំមុខគេ រចនាសម្ព័ន្ធសំរាប់ធ្វើការកាត់ក្តីក៏ត្រូវបានបង្កើតឡើង ដែលក្នុងនោះចៅក្រមខ្មែរ និងចៅក្រមអន្តរជាតិនឹងធ្វើការកាត់ក្តីរួមគ្នាលើមេដឹកនាំជាន់ខ្ពស់ ដែល ទទួល ខុសត្រូវច្រើនជាងគេចំពោះការរំលោភច្បាប់ជាតិនិង ច្បាប់អន្តរជាតិ។ នៅឆ្នាំ ២០០៣ មានការព្រមព្រៀងគ្នាលើក្របខ័ណ្ឌស្តីពីការបង្កើតតុលាការ ដែលគេអោយឈ្មោះថា អង្គជំនំជំរះវិសា មញ្ញក្នុងតុលាការកម្ពុជា។

នៅខែមិនា ឆ្នាំ ២០០៦ លោក Kofi Annan អគ្គលេខាធិការអង្គការសហប្រជាជាតិ បានតែងតាំងចៅក្រមអន្តរជាតិចំនួន ៣ រូបសំរាប់តុលាការនេះ ហើយ

country, having been granted amnesty by the government in exchange for defecting. In 1997, Cambodia had formed a task force to create a court structure to try these leaders for their crimes, but the government needed international support to get the trial off the ground.

Through a series of negotiations involving the UN in which the United States played a leading role a trial structure was created in which Cambodian and international judges would together try senior leaders most responsible for violations of domestic and international law. In 2003, a framework agreement was reached on creating the tribunal, which was dubbed the Extraordinary Chambers in the Courts of Cambodia.

In March 2006, UN Secretary General Kofi Annan nominated seven international judges to oversee the court, and in May of that year Cambodian Minister of Justice Ang Vong Vathana announced that the government endorsed 30 Cambodian and UN judges who would make up the court. These judges were sworn in in July 2006, but Cambodians would have to wait several years for the actual proceedings to begin.

Concerned that the court would be unable to uphold international standards, the United States did not begin funding the court until 2009. Still, U.S. assistance contributed to the tribunal's efforts in other important ways, including the establishment of a Cambodian-run NGO called the Documentation Center of Cambodia.

Founded by Youk Chhang, a Cambodian survivor of the Khmer Rouge and expert on the regime, the center is Cambodia's only independent, non-governmental institution devoted to documenting Khmer Rouge history. The center's staff collects evidence, conducts research and promotes accountability for crimes through public outreach. It has provided thousands of pages of evidence to the Khmer Rouge tribunal, including key documents from the regime's central leadership and the locations of mass graves.

As negotiations to form the trial continued, the United States appointed

Youk Chhang with U.S. Ambassador Joseph Mussomeli in 2007.

លោក ឆាំង យុ ទិដ្ឋភាពលោកឯកអគ្គរដ្ឋទូត Joseph Mussomeli ក្នុង ២០០៧។

នៅខែឧសភា ក្នុងឆ្នាំដដែលនោះ លោក អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួង យុត្តិធម៌កម្ពុជា បានប្រកាសថា រដ្ឋាភិបាលយល់ព្រមលើចៅក្រមរបស់កម្ពុជានិងរបស់អង្គការសហប្រជាជាតិចំនួន ៣០នាក់ សំរាប់តុលាការនេះ។ ចៅក្រមទាំងនេះបានស្បថសច្ចាប្រណិធានចូលបំពេញការងារនៅខែកក្កដា ឆ្នាំ ២០០៦ តែប្រជាជនកម្ពុជាត្រូវរង់ចាំជាច្រើនឆ្នាំទំរាំដំណើរការក្តីជាក់ស្តែងចាប់ផ្តើម។

ដោយមានកង្វល់ថា តុលាការនេះមិនអាចបំពេញបានតាមបទដ្ឋានអន្តរជាតិ សហរដ្ឋអាមេរិកមិនទាន់ចាប់ផ្តើមផ្តល់ជំនួយថវិកាដល់តុលាការនេះទេ រហូតដល់ឆ្នាំ ២០០៩ ។ យ៉ាងណាក្តីក៏ជំនួយរបស់សហរដ្ឋអាមេរិកបានរួមចំណែកសំខាន់ៗដល់ការខិតខំរបស់តុលាការនេះ ដូចជាការបង្កើតអង្គការមិនមែន រដ្ឋាភិបាលដែលដឹកនាំដោយជនជាតិខ្មែរ និងមានឈ្មោះថា មជ្ឈមណ្ឌលឯកសារកម្ពុជា។

ដោយត្រូវបានបង្កើតឡើងដោយ លោក ឆាំង យុ ដែលជាជនជាតិខ្មែរសល់ពីការស្លាប់នៅសម័យខ្មែរក្រហម និងជាអ្នកឯកទេសស្តីពីរបបនេះមជ្ឈមណ្ឌលនេះគឺជាស្ថាប័នមិនមែនរដ្ឋាភិបាលនិងឯករាជ្យតែមួយគត់របស់ប្រទេសកម្ពុជា ដែលផ្តោតការងារលើការចងក្រងឯកសារស្តីពីប្រវត្តិសាស្ត្រពួកខ្មែរក្រហម។ បុគ្គលិករបស់មជ្ឈមណ្ឌលនេះប្រមូលភស្តុតាង ធ្វើការស្រាវជ្រាវ និងជំរុញគណនេយ្យភាពចំពោះ

U.S. Secretary of State Colin Powell meets with Prince Ranariddh in 2003.

Colin Powell រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ជួបជាមួយ ព្រះអង្គម្ចាស់ នរោត្តមរណឫទ្ធិ នៅឆ្នាំ២០០៣។

Charles Aaron Ray as the new U.S. Ambassador to Cambodia. Ambassador Ray presented his credentials on January 4, 2003.

Ambassador Ray's first major concern was Cambodia's upcoming national election, which was scheduled to take place on July 27, 2003. During campaigning, sporadic violence occurred, although it was much less frequent than in previous elections. On June 18, U.S. Secretary of State Colin Powell visited Cambodia and met with leaders of the three leading political parties. Powell called for all parties to receive fair and equal coverage in the country's media.

On Election Day, Prime Minister Hun Sen once again emerged victorious, claiming 73 of the 123 National Assembly seats. Ambassador Ray praised the election, saying it was a sign of "impressive growth of the democratic process in Cambodia." However, the CPP lacked the two-thirds majority necessary to form a government, and a political deadlock ensued. The impasse was resolved nearly a year later, when the CPP formed an alliance with FUNCINPEC, allowing the country to move forward.

បទឧក្រិដ្ឋតាមរយៈការទំនាក់ទំនងជាមួយសាធារណៈ។ មជ្ឈមណ្ឌលនេះបានផ្តល់ភស្តុតាងរាប់ពាន់ទំព័រទៅអោយតុលាការកាត់ទោស ពួកខ្មែរក្រហម រួមទាំងឯកសារសំខាន់ៗស្តីពីជួរដឹកនាំមជ្ឈឹមរបស់របបនេះ និងទីតាំងនៃរណ្តៅសពរួម។

នៅពេលដែលការចរចាដើម្បីបង្កើតតុលាការនៅបន្ត ហារដ្ឋអាមេរិកបានតែងតាំងលោក Charles Aaron Ray អោយធ្វើជាឯកអគ្គរដ្ឋទូតថ្មីប្រចាំនៅប្រទេសកម្ពុជា។ លោកឯកអគ្គរដ្ឋទូត Ray បានថ្វាយសារតាំងនៅថ្ងៃទី ៤ មករា ឆ្នាំ ២០០៣។

បញ្ហាធំជាងគេទីមួយសំរាប់លោកឯកអគ្គរដ្ឋទូត Ray គឺការបោះឆ្នោតជាតិនៅពេលខាងមុខ ដែលកំណត់ត្រូវធ្វើនៅថ្ងៃទី ២៧ កក្កដា ឆ្នាំ ២០០៣។ ក្នុងអំឡុងយុទ្ធនាការ អំពើហឹង្សាម្តងម្កាលបានកើតមានឡើង តែមានតិចជាងកាលពីការបោះឆ្នោតលើកមុនច្រើន។ នៅថ្ងៃទី ១៨ ខែមិថុនា លោក Colin Powell រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក បានធ្វើទស្សនកិច្ចនៅកម្ពុជា ហើយបានជួបមេដឹកនាំនៃគណបក្សនយោបាយធំជាងគេទាំងបី។ លោករដ្ឋមន្ត្រី Powell បានអំពាវនាវអោយគ្រប់ភាគីទាំងអស់ទទួលបានការការផ្សាយស្មើភាពគ្នាតាមប្រព័ន្ធផ្សព្វផ្សាយ។

នៅថ្ងៃបោះឆ្នោតគណបក្សប្រជាជនរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឈ្នះម្តងទៀត ដោយទទួលបានកៅអីចំនួន ៧៣ ក្នុងចំណោមកៅអីចំនួន ១២៣ ក្នុងសភាជាតិ។ លោកឯកអគ្គរដ្ឋទូត Ray បានសរសើរការបោះឆ្នោតនោះដោយមានប្រសាសន៍ថា វាជាសញ្ញានៃ "ការរីកចំរើនគួរអោយចាប់អារម្មណ៍នៃដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា"។ ទោះជាយ៉ាងណាក្តី ក៏គណបក្សប្រជាជនមិនបានទទួលសំលេងភាគច្រើន ២ ភាគ ៣ ដែលចាំបាច់សំរាប់បង្កើតរដ្ឋាភិបាលឡើយ ហើយការជាប់គាំងនយោបាយក៏មានឡើង។ មួយឆ្នាំក្រោយមក ការជាប់គាំងនេះត្រូវបានដោះស្រាយ នៅពេលគណបក្សប្រជាជនបានចងសម្ព័ន្ធជាមួយគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលជាការធ្វើអោយប្រទេសអាចដើរទៅមុខបាន។

ដោយមានស្ថេរភាពនយោបាយ និងមានរដ្ឋាភិបាលថ្មី ជាថ្មីម្តងទៀត ប្រទេសកម្ពុជាអាចផ្តោតការយកចិត្តទុកដាក់លើបញ្ហាអភិវឌ្ឍន៍។ ដូចដែលខ្លួនបានធ្វើមកក្នុងទសវត្សទី ១៩៥០ ជាថ្មីម្តងទៀត សហរដ្ឋអាមេរិកត្រៀមជាស្រេចដើម្បីដើរតួនាទីលេចធ្លោមួយ។ ថវិការបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) មានទំហំកើនឡើង ៤ ដងក្នុងអំឡុងទសវត្សនោះ ដោយបានឡើងដល់ ៤៧០ លានដុល្លាអាមេរិក ក្នុងរយៈពេលពីឆ្នាំ ២000 ដល់ឆ្នាំ ២00៩ ដោយបានជួយកែលំអប្រព័ន្ធសុខាភិបាលនិងអប់រំ ជំរុញកំណើនសេដ្ឋកិច្ច និងលើកកំពស់សិទ្ធិមនុស្ស

With the political situation stable and a new government in place, the country could once again focus on development issues. Just as it had done in the 1950s, the United States was once again ready to play a prominent role. The U.S. Agency for International Development's budget quadrupled in size over the course of the decade, reaching a total expenditure of over $470 million between 2000 and 2009, helping to improve the health and education systems, stimulate economic growth, and promote human rights and civil liberties.

In an effort to stimulate economic growth, Cambodia had signed a bilateral trade agreement with the United States in 1999 that allowed it to export a quota of textiles to the U.S. market under favorable terms. In exchange, Cambodia committed to improving labor standards and allowing inspections of its factories.

As a result of this deal – and due to Cambodia's growing reputation as a labor-friendly country – the garment industry expanded rapidly throughout the 2000s. It eventually grew to employ 350,000 people,

Ambassador Charles Ray shakes the hand of a young man in Kampong Cham.

លោកឯកអគ្គរដ្ឋទូត Charles Ray ចាប់ដៃជាមួយកុមារាម្នាក់ នៅខេត្តកំពង់ចាម។

និងសេរីភាពពលរដ្ឋ។

ក្នុងការខិតខំដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី ជាមួយសហរដ្ឋអាមេរិកនៅឆ្នាំ ១៩៩៩ ដែលអនុញ្ញាតិអោយកម្ពុជាទទួលបានកូតាក្នុងការនាំសំលៀកបំពាក់ទៅកាន់ទីផ្សាសហរដ្ឋអាមេរិក ក្រោមលក្ខខ័ណ្ឌអនុគ្រោះ។ ជាការតបវិញប្រទេស កម្ពុជាបានសន្យាកែលំអបទដ្ឋានការងារ ហើយបើកអោយមានការធ្វើអធិការកិច្ចលើរោងចក្ររបស់ខ្លួន។

ដោយសារមានកិច្ចព្រមព្រៀងនេះ និងដោយសារប្រទេសកម្ពុជាមានកេរ្តិ៍ឈ្មោះកាន់តែល្អជាប្រទេសដែលមានបទដ្ឋានការងារល្អ ឧស្សាហកម្មកាត់ដេរបានរីកចំរើនយ៉ាងឆាប់រហ័ស នៅក្នុងទសវត្សទី ២000 ទាំងមូល។ ឧស្សាហកម្មនេះមានពលកម្មឡើងដល់ ៣៥0 000 នាក់ ដែលភាគច្រើនចេញមកពីសហគមន៍ក្រីក្រដែលប្រកបមុខរបរធ្វើស្រែចំការនៅតាមតំបន់ជនបទតាមខេត្ត។ ដោយវាជាឧស្សាហកម្មនាំចេញធំជាងគេបំផុតរបស់ប្រទេស វិស័យកាត់ដេរបានក្លាយជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ដោយក្នុងទសវត្សនោះ បានជួយបង្កើនទ្វេដងនូវប្រាក់ចំណូលគិតជាមធ្យមសំរាប់មនុស្សម្នាក់ៗ។

កំណើនសេដ្ឋកិច្ចបានធ្វើអោយប្រជាជនកម្ពុជាសំលឹង ទៅអនាគតប្រកបដោយសុទិដ្ឋិនិយម ជាលើកដំបូងក្នុងអំឡុង ពេលរាប់ឆ្នាំមកនោះ តែនេះក៏ធ្វើអោយប្រទេសអាចពិនិត្យទៅ លើអតីតកាលរបស់ខ្លួនផងដែរ ជាពិសេស ភាពអស្ចារ្យផ្នែកបូរាណវិទ្យាពីសម័យអង្គរ។

នៅឆ្នាំ ២00៣ លោកឯកអគ្គរដ្ឋទូត Ray បានចុះ ហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីដាក់កំហិតលើការនាំចូលវត្ថុបូរាណទៅក្នុងទីផ្សាសហរដ្ឋអាមេរិក ដើម្បីការពារកុំអោយមានការលួចប្លន់ប្រវត្តិសាស្ត្រវប្ធធម៌នៃប្រទេសកម្ពុជា។ ចំណុចដែលគេឃើញច្បាស់មួយចេញពីកិច្ចព្រមព្រៀងនេះគឺការបញ្ជូនត្រឡប់មកវិញ កាលពីឆ្នាំ២00៧ នូវរូបរបាំអប្សរាធ្វើពីថ្មភក់ នៅសតវត្សទី ១៣ ដែលត្រូវបានគេលួចយកចូលទៅក្នុងសហរដ្ឋអាមេរិក។ កិច្ចព្រមព្រៀងទ្វេភាគីនេះត្រូវបានបន្តឡើងវិញ នៅឆ្នាំ ២00៨ ។

សហរដ្ឋអាមេរិកថែមទាំងបានផ្តល់ជំនួយដើម្បីជួយជួសជុលប្រាសាទអង្គរដ៏ល្អឯករបស់ប្រទេសកម្ពុជា។ ដោយបានចាប់ផ្តើមនៅឆ្នាំ ២00១ និងបានបន្តរហូតមកក្នុងទសវត្សនោះ សហរដ្ឋអាមេរិកបានផ្តល់ថវិកាចំនួន ១,៨ លានដុល្លាអាមេរិក ជាថវិកាអភិរក្សជាប្រវត្តិសាស្ត្រ សំរាប់ប្រទេសកម្ពុជា។ សកម្មភាពរួមមានការធ្វើសំរង់

many of whom came from poor farming communities in rural provinces. As the country's largest export industry, the garment sector became an engine of economic growth, helping to double per-capita income over the course of the decade.

The growing economy allowed Cambodians to look to the future with optimism for the first time in years, but it also allowed the country to examine its past – in particular, the archeological wonders of the Angkorean era.

In 2003, Ambassador Ray signed an agreement with the Cambodian government to restrict imports of ancient artifacts into the U.S. market, in a bid to protect the looting of Cambodia's cultural history. A highlight of the deal was the repatriation in 2007 of a sandstone Apsara dancer from the 13th century that had been smuggled into the United States. The bilateral agreement was renewed and expanded in 2008.

The United States also provided assistance to help restore some of

Former U.S. President Bill Clinton meets with Prime Minister Hun Sen during his visit to Cambodia in 2006.

លោក Bill Clinton អតីតប្រធានាធិបតីអាមេរិក ជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុនសែន នៅពេលដែលលោកធ្វើទស្សនកិច្ច នៅប្រទេសកម្ពុជាក្នុងឆ្នាំ២០០៦។

សារពើពន្ធលើវត្ថុបូរាណធ្វើការស្រាវជ្រាវ និងជួសជុលទីតាំងប្រាសាទឡើងវិញ។ គំរោងធំបំផុតមួយគឺការជួសជុលប្រាសាទភ្នំបាក់ ខែងដោយត្រូវចំណាយថវិកាអស់ ១,៥ លានដុល្លាអាមេរិក។ ប្រាសាទនេះគឺជាប្រាសាទសំខាន់ជាងគេមួយ នៅក្នុងចំណោម ប្រាសាទនានានៅអង្គរ។

ជំនួយរបស់សហរដ្ឋអាមេរិកនៅក្នុងទសវត្សឆ្នាំ ២000 ថែមទាំងបានជួយផងដែរក្នុងផ្នែកជំងឺអេដស៍ ដែលបានចោទជាការគំរាមកំហែងដល់សុខភាព នៅក្នុងប្រទេសនិងក្នុងតំបន់។ ក្នុងនាមជាប្រទេសផ្តល់ជំនួយទ្វេភាគីធំជាងគេដល់ប្រទេសកម្ពុជា ក្នុងផ្នែកជំងឺអេដស៍ សហរដ្ឋអាមេរិកបានជួយកាត់បន្ថយអត្រាអ្នកផ្ទុកមេរោគអេដស៍អោយមានការថយចុះពីអត្រា ២% នៅចុងទសវត្សទី ១៩៩0 មកត្រឹមតិចជាង ១% នៅឆ្នាំ ២00៥ ដែលជាការធ្វើអោយប្រទេសកម្ពុជាមានជោគជ័យ ដែលគេកំរមាន ក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគនេះ នៅក្នុងពិភពលោក។

ជនជាតិអាមេរិកម្នាក់ដែលមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះបញ្ហាជំងឺអេដស៍គឺលោកប្រធានាធិបតី Bill Clinton ដែលអង្គការអភិវឌ្ឍនអន្តរជាតិរបស់លោក គឺមូលនិធិ Clinton ធ្វើការផ្នែកសុខភាពនៅទូទាំងសាកលលោក។ នៅខែធ្នូ ឆ្នាំ ២00៦ លោកអតីតប្រធានាធិបតីបានមកទីក្រុងភ្នំពេញហើយបានសន្យាថា មូលនិធិរបស់លោកនឹងជួយក្នុងការប្រយុទ្ធ ប្រឆាំងនឹងជំងឺនេះ នៅប្រទេសកម្ពុជា។ លោកបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុនសែន ដោយក្នុងនោះ មូលនិធិ Clinton នឹងផ្តល់ថ្នាំប្រឆាំងជំងឺអេដស៍ និងកែលំអមន្ទីរពិសោធន៍របស់ផ្នែកសុខាភិបាលជាតិ ហើយមានសកម្មភាពដទៃទៀត។

លោកប្រធានាធិបតី Clinton ត្រូវបានទទួលដោយលោកឯកអគ្គរដ្ឋទូត Joseph A. Mussomeli ដែលបានថ្វាយសារតាំងជាឯកអគ្គរដ្ឋទូតថ្មីរបស់សហរដ្ឋអាមេរិក នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២00៥។ ចំណុចគួរអោយចាប់អារម្មណ៍នៃទស្សនកិច្ចរបស់លោកអតីតប្រធានាធិបតីគឺការដើរមើលទីតាំងអាគារថ្មីរបស់ស្ថានទូតដែលបានបើកទ្វារនៅឆ្នាំ ២00៦។ អាគារថ្មីនេះ ដែលស្ថិតនៅជិតវត្តភ្នំដ៏មានឈ្មោះល្បី នៅភាគខាងជើងនៃរាជធានី មានផ្ទៃដីស្មើនឹងប្លុកទាំងមូលមួយក្នុងក្រុង ហើយមានបុគ្គលិកធ្វើការជាង ៥00 នាក់។ ក្នុងនាមជាកន្លែងដែលត្រូវបានសង់ឡើងតាមការកំណត់សំរាប់ស្ថានទូត ទីតាំងអាគារទាំងនេះគឺជាសញ្ញាមួយនៃទំនាក់ទំនងដែលមានកាន់តែច្រើនឡើងរបស់សហរដ្ឋអាមេរិក នៅប្រទេសកម្ពុជា។

សញ្ញាមួយទៀតនៃការទាក់ទងកាន់តែជ្រាលជ្រៅនេះគឺការមកដល់នៃទី

Cambodia's most precious Angkorean temples. Beginning in 2001, and continuing throughout the decade, the United States provided over $1.8 million in historical preservation funds to Cambodia. Activities included inventorying historical objects, conducting research, and restoring temple sites; the most ambitious of these was the $1.5 million restoration of Phnom Bakheng, a major temple located within the Angkor complex.

U.S. assistance in the 2000s also helped Cambodia address the spread of HIV/AIDS, which had emerged as a health threat in the country and the region. As the largest bilateral donor of HIV/AIDS funds in Cambodia, the United States helped cut the prevalence rate of the disease from 2% in the late 1990s to less than 1% in 2005, making Cambodia one of the few success stories in the global fight against the virus.

One American with a keen interest in the HIV/AIDS issue was former President Bill Clinton, whose international development organization, the Clinton Foundation, works to address health issues worldwide. In December 2006, the former President visited Phnom Penh and pledged the foundation's support in fighting the disease in Cambodia. He signed a memorandum of understanding with Prime Minister Hun Sen under which the Clinton Foundation would provide anti-retroviral medication and upgrade national health laboratories, among other activities.

President Clinton was received at the U.S. Embassy by Joseph A. Mussomeli, who had presented his credentials to become the new U.S. Ambassador on September 22, 2005. A highlight of the former President's visit was a tour of the new Embassy facility, which had opened its doors on January 17th, 2006. The new building, located next to the famed Wat Phnom temple on the capital's north side, occupies an entire city block and houses over 500 employees. As the first purpose-built U.S. Embassy in Cambodia, the new facility was a sign of growing U.S. engagement in the country.

Another sign of this deepening engagement was the arrival of the Peace Corps, which opened its first office in Phnom Penh in 2006 at the

The first group of U.S. Peace Corps Volunteers in Cambodia, consisting of 29 people, arrived on February 2, 2007 and was sworn in on April 4, 2007. Peace Corps was established by U.S. President John Kennedy in 1961 in order to promote international peace and friendship through the service of American Volunteers overseas.

អ្នកស្ម័គ្រចិត្តក្រុមទី១របស់ Peace Corps បានមកដល់កម្ពុជា នៅថ្ងៃទី២ ខែកម្ភៈ ឆ្នាំ២០០៧។ អង្គការ Peace Corps ត្រូវបានបង្កើតដោយ លោកប្រធានាធិបតី John Kennedy ក្នុងឆ្នាំ ១៩៦១ ដើម្បីជំរុញសន្តិភាព និងមិត្តភាពអន្តរជាតិ តាមរយៈការងាររបស់អ្នកស្ម័គ្រចិត្តអាមេរិក នៅបរទេស ។

ភ្នាក់ងារ Peace Corps ដែលបានបើកការិយាល័យដំបូងរបស់ខ្លួននៅទីក្រុងភ្នំពេញ នៅឆ្នាំ ២០០៦ តាមការអញ្ជើញរបស់រដ្ឋាភិបាលកម្ពុជា។ អ្នកស្ម័គ្រចិត្តរបស់ទីភ្នាក់ងារ Peace Corps ក្នុងក្រុមដំបូងបានធ្វើសច្ចារប្រណិធានចូលបំពេញការងារនៅប្រទេសកម្ពុជា នៅថ្ងៃទី ៤ ខែមេសា ឆ្នាំ ២០០៧។ អ្នកស្ម័គ្រចិត្តទាំង ២៩ នាក់នោះមានអាណត្តិបំពេញការងាររយៈពេល ២ ឆ្នាំ ដោយរស់នៅជាមួយគ្រួសារខ្មែរ តាមភូមិជនបទ នៅទូទាំងប្រទេស បង្រៀនភាសាអង់គ្លេសនៅតាមវិទ្យាល័យកំរិតទុតិយភូមិ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។ ក្រុមបន្តបន្ទាប់មកទៀតមានចំនួនសមាជិកកាន់តែច្រើន នៅក្នុងទសវត្សនេះ។

នៅឆ្នាំ ២០០៨ ប្រទេសកម្ពុជាប្រុងប្រៀបរៀបចំសំរាប់ការបោះឆ្នោតសភាជាតិលើកទី ៤ របស់ខ្លួន តាំងពីសម័យអ៊ុនតាក់មក។ នៅថ្ងៃទី ២៧ ខែកក្កដា ប្រជាជនកម្ពុជាបានទៅបោះឆ្នោត ហើយបានបោះឆ្នោតអោយគណបក្សប្រជាជនក្នុងចំនួនច្រើន ដោយគណបក្សនេះឈ្នះបានសំលេងជាង ២ ភាគ ៣ ដែលចាំបាច់សំរាប់បង្កើតរដ្ឋាភិបាល។ ទោះជាយ៉ាងណាក្តី ក៏គណបក្សប្រជាជនសំរេចរក្សាការចងសម្ព័ន្ធជាមួយគណបក្សហ្ស៊ីនសុិនបុិច ដែលមានការធ្លាក់ចុះយ៉ាងខ្លាំង ហើយលោក ហ៊ុន សែននៅតែជានាយករដ្ឋមន្ត្រី។

Ambassador Mussomeli turns over the Khmer sculpture to H.E. Him Chhem in a ceremony at National Museum of Cambodia in 2007.

លោកឯកអគ្គរដ្ឋទូត Mussomeli ប្រគល់ជូនរូបចំលាក់វិញ នៅពិធីមួយ កាលពី ឆ្នាំ២០០៧។

invitation of the Cambodian government. The Peace Corps swore in its first group of volunteers on April 4, 2007. These 29 volunteers served their two-year tours living with Cambodian families in rural villages throughout the country, teaching English at upper secondary schools and regional teacher training centers. Successive volunteer classes swelled in size as the decade continued.

In 2008, the country was poised for what would be its fourth parliamentary election since UNTAC. On July 27, Cambodians went to the polls and voted for the CPP in large numbers, allowing the party to secure the more than the two-thirds majority necessary to form a government. Regardless, the CPP decided to maintain its alliance with a severely diminished FUNCINPEC, and Hun Sen remained Prime Minister.

By funding candidate debates, elections observers, and town-hall style political forums, the United States contributed to what international observers called the freest election in Cambodia's history. The vast majority of Cambodia's registered voters were able to express their choice in a peaceful and orderly atmosphere. U.S. programs designed to engage women in the democratic process had a noticeable impact, with women filling 15% of National Assembly seats, reflecting a trend of steady increases over previous elections. In a sign of their growing political prominence, women candidates were selected for a newly created Deputy Prime Minister position and 24 deputy governor positions.

ដោយជួយថវិកាដល់ការជជែកដេញដោលរបស់បេក្ខជន អ្នកសង្កេតការបោះឆ្នោត និងវេទិការនយោបាយជារបៀបសំណេះសំណាល សហរដ្ឋអាមេរិកបានរួមចំណែកដល់អ្វីដែលអ្នកសង្កេតការបានហៅថា ការបោះឆ្នោតដែលមានភាពសេរីជាងគេ ក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ ភាគច្រើនលើសលុបនៃអ្នកបោះឆ្នោតដែលបានចុះបញ្ជី អាចសំដែងការជ្រើសរើសរបស់គេ ក្នុងបរិយាកាសសន្តិភាព និងមានរបៀបរៀបរយ។ កម្មវិធីរៀបចំដោយសហរដ្ឋអាមេរិក ដែលមានបំណងអោយស្ត្រីចូលរួមក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ បានទទួលផលគួរអោយកត់សំគាល់ ដោយមានស្ត្រីកាន់កាប់កៅអីក្នុងរដ្ឋសភាចំនួន ១៥% ដែលជាការឆ្លុះបញ្ចាំងនិន្នាការនៃការកើនឡើងជាលំដាប់ បើប្រៀបធៀបនឹងការបោះឆ្នោតមុនៗ។ ក្នុងសញ្ញាមួយនៃការលេចមុខឡើងកាន់តែច្រើនរបស់គេ បេក្ខជនជាស្ត្រីត្រូវបានជ្រើសរើសអោយកាន់តំណែងជាឧបនាយករដ្ឋមន្ត្រី ដែលទើបត្រូវបានបង្កើតឡើងថ្មី និងមុខតំណែងជាអភិបាលរងចំនួន ២៤។

នៅដើមឆ្នាំ ២០០៩ ឯកអគ្គរដ្ឋទូតថ្មីរបស់សហរដ្ឋអាមេរិកបានមកដល់។ លោកស្រី Carol A. Rodley បានថ្វាយសារតាំង នៅថ្ងៃទី ២០ ខែមករា ឆ្នាំ២០០៩។ លោកស្រីគឺជាស្ត្រីទី ១ ដែលបានកាន់តំណែងនេះ ។

នៅឆ្នាំដដែលនោះ ព្រឹត្តិការណ៍ធំមួយដែលមានខ្លឹមសារជានិមិត្តរូប តាមផ្លូវច្បាប់ និងតាមផ្លូវនយោបាយ បានកើតមានឡើងនៅក្នុងបន្ទប់សវនាការ នៅជាយក្រុងភ្នំពេញ។ ដោយមានប្រជាជនកម្ពុជា និងពិភពលោកកំពុងសំលឹងមើលតុលាការកាត់ទោសខ្មែរក្រហមបានចាប់ផ្តើមធ្វើការងារលើករណីទីមួយ នៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០៩។ ចុងចោទមានឈ្មោះថា គាំង ហ្គិចគៀវ ដែលមានឈ្មោះបដិវត្តន៍ថា ឌុច។ គាត់គឺជាមេគុកទួលស្លែងដ៏មានឈ្មោះអាសោច ឬគុក ស ២១។ បន្ទាប់ពីរយៈពេលរង់ចាំចំនួន ៣១ ឆ្នាំមកសាក្សីជាជនជាតិខ្មែរនៅទីបំផុត បានបង្ហាញមុខនៅក្នុងតុលាការដើម្បីរៀបរាប់ពីការភ័យរន្ធត់ដែលពួកគេបានជួបប្រទះនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។

ថ្មីបើគាត់បានសំដែងការសោកស្តាយ និងធ្វើសហប្រតិបត្តិការបានល្អ ក្នុងអំឡុងពេលស្នើរតែទាំងមូលនៃសវនាការ តែឌុច និងមេធាវីរបស់គាត់បានកែប្រែវិធីរបស់គេយ៉ាងខ្លាំង នៅពេលថ្លែងជាចុងក្រោយ។ ឌុចបាននិយាយថាពិតមែនតែគាត់មិនបដិសេធតួនាទីរបស់គាត់នៅក្នុងការសំលាប់អ្នកទោសនៅគុកទួលស្លែងប្រហែល ១២ 000 នាក់ក្តី តែការទទួលខុសត្រូវពិតប្រាកដចំពោះបទឧក្រិដ្ឋនេះស្ថិតនៅលើជួរមេ

At the start of 2009, a new U.S. Ambassador arrived in the country. Carol A. Rodley presented her credentials on January 20, 2009, becoming the first woman to occupy the post.

That same year, an event with major political, legal, and symbolic significance occurred in a courtroom on the outskirts of Phnom Penh. With Cambodians and the world watching, the Khmer Rouge tribunal began its first case on February 16, 2009. The defendant was Kaing Guek Eav, better known by his revolutionary name Duch, who was the warden of the notorious Khmer Rouge prison at Tuol Sleng, also known as S-21. After 30 years of waiting, Cambodian witnesses finally appeared in a court of law to describe the horrors they had endured under the Democratic Kampuchea regime.

While contrite and forthcoming for most of the trial, Duch and his defense team dramatically switched tactics during closing arguments. Duch argued that while he did not deny his role in the execution of some 12,000 prisoners at Tuol Sleng, the real responsibility for these crimes lay with the Khmer Rouge leadership. Duch asked to be released; a verdict is expected in the summer of 2010. The four remaining Khmer Rouge leaders in custody are likely to face trial in 2011. In 2010, the United States committed a further $5 million to support the proceedings, bringing the total contribution to date to $6.8 million.

As the decade wound to a close, Cambodians could feel optimistic about the direction of their country. While significant problems persisted, it had only been 10 years since the end of a protracted civil war, and the country was on the ascent. Despite the impact of the global economic crisis toward the end of the decade, the 2000s marked a period of progress, with the economy making major gains, successive elections becoming freer and fairer, and an internationally recognized court at last beginning to prosecute senior Khmer Rouge leaders.

In many ways, the U.S.-Cambodian relationship mirrored this progress.

Ambassador Rodley with the winners of Cambodian Client Council Competition which is part of USAID's Program on Rights and Justice.

ដឹកនាំខ្មែរក្រហម។ ឌុចបានសុំអោយគេដោះលែងខ្លួន ។ សាលក្រមត្រូវបានគេរំពឹងថានឹងចេញនៅរដូវក្តៅ ឆ្នាំ ២០១០។ នៅឆ្នាំ ២០១០ សហរដ្ឋអាមេរិកបានសន្យាផ្តល់ប្រាក់ចំនួន ៥ លានដុល្លា ដើម្បីជួយដល់ដំណើរការកាត់ទោសរបស់តុលាការដែលនាំអោយប្រាក់វិភាគទានសរុបរហូតមកដល់ពេលនេះ ឡើងដល់ ៦,៨ លានដុល្លា។

នៅចុងទសវត្ស ប្រជាជនកម្ពុជាមានសុទិដ្ឋិនិយមលើទិសដែលប្រទេសរបស់គេកំពុងដើរតាម។ ថ្មីបើនៅតែមានបញ្ហាធំៗនៅឡើយក្តី តែសង្គ្រាមស៊ីវិលរ៉ាំរ៉ៃទើបតែបានចប់ ទៅកាលពី ១០ ឆ្នាំមុនតែប៉ុណ្ណោះ ហើយប្រទេសកំពុងតែ ឈានឡើង។ ទោះបីជារងផលប៉ះពាល់ដោយវិបត្តិសេដ្ឋកិច្ច ពិភពលោកនៅដំណាច់ទសវត្សក្តី តែទសវត្ស ឆ្នាំ ២000 ត្រូវបានកត់សំគាល់ថាជារយៈកាលនៃការដើរទៅមុខ ដោយសេដ្ឋកិច្ចមានការចំរើនឡើងច្រើន ការបោះឆ្នោតជាបន្តបន្ទាប់ មានភាពកាន់តែសេរី និងយុត្តិធម៌ ហើយនិងមានតុលាការដែលទទួលស្គាល់ដោយអន្តរជាតិនៅទីបំផុតបានចាប់ផ្តើមដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់។

ក្នុងលក្ខណៈជាច្រើន ទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងកម្ពុជាបានឆ្លុះបញ្ចាំងពីការដើរទៅមុខនេះ។ ថ្មីបើនៅមានការយល់ច្នាខុសម្តងម្កាលក្តី តែសហរដ្ឋអាមេរិកបានដើរតួនាទីវិជ្ជមាន ហើយរៀបចំដើរតួនាទីនេះជាបន្តទៀត ក្នុងការ

While there were still occasional misunderstandings, the United States played – and is poised to continue to play – a positive role in Cambodia's ongoing development.

The United States and Cambodia continue to cooperate on other areas of mutual concern, such as combating the illegal trafficking of drugs and humans, preventing terrorism, and promoting Cambodia's role as a responsible partner in regional and international bodies such as ASEAN.

Sixty years after the establishment of diplomatic relations and the appointment of Donald R. Heath as U.S. Envoy Extraordinary and Minister Plenipotentiary in 1950, the U.S.-Cambodian relationship enters the next decade healthier and stronger than it has ever been.

អភិវឌ្ឍប្រទេសកម្ពុជាជាបន្តទៀត។

សហរដ្ឋអាមេរិក និងកម្ពុជាបន្តធ្វើសហប្រតិបត្តិការ ក្នុងវិស័យដទៃទៀតដែលជាកង្វល់រួម ដូចជាការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងគ្រឿងញៀនខុសច្បាប់ ការការពារភេរវកម្ម និងការជំរុញតួនាទីរបស់ប្រទេសកម្ពុជា ជាដៃគូមានការទទួលខុសត្រូវ ក្នុងអង្គការតំបន់និងអន្តរជាតិ ដូចជាសមាគមអាស៊ាន។

៦0 ឆ្នាំបន្ទាប់ពីការបង្កើតទំនាក់ទំនងការទូត និងការតែងតាំងលោក Donald R. Heath អោយធ្វើជាបេសកជនពិសេស និងពេញសមត្ថភាពរបស់សហរដ្ឋអាមេរិក នៅឆ្នាំ ១៩៥0 មក ទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងកម្ពុជាឈានចូលទសវត្សថ្មីប្រកបដោយភាពរឹងមាំល្អជាងពេលណាៗទាំងអស់។

Cambodian Ambassadors to the United States

June 5, 1951 Legation Opened

Name: *Nong Kimny*
Title: Envoy Extraordinary. and Minister Plenipotentiary
Appointment: June 5, 1951

July. 1, 1952 Legation Raised to Embassy

Name: *Nong Kimny*
Title: Ambassador Extraordinary and Plenipotentiary
Appointment: June 19, 1952

Name: *Sonn Voeunsai*
Title: Anbassador Extraordinatry and Plenipotentiary
Appointment: June 8, 1970

Name: *Um Sim*
Title: Ambassador Extraordinary and Plenipotentiary
Appointment: June 5, 1973

Name: *Var Houth*
Title: Ambassador Extraordinary and Plenipotnetiary
Appointment: May 28, 1995

Name: *Eng Roland*
Title: Ambassador Extraordinary and Plenipotentiary
Appoinment: September 14, 1999

Name: *Ek Sereywath*
Title: Ambassador Extraordinary and Plenipotentiary
Appointment: February 10, 2005

Name: *Hem Heng*
Title: Ambassador Extraordinary and Plenipotentiary
Appointment: January 29, 2009

U.S. Ambassadors to Cambodia

Name: *Donald R. Heath*
Foreign Service officer
Title: Envoy Extraordinary and Minister Plenipotentiary
Appointment: Jun 29, 1950
Presentation of Credentials: Jul 11, 1950
Termination of Mission: Promoted to Ambassador Extraordinary and Plenipotentiary
Note: Also accredited to Laos and Vietnam; resident at Saigon. During Heath's tenure as non-resident Minister, Legation Phnom Penh was opened to the public, Nov 14, 1950, with Don V. Catlett as Chargé d'Affaires ad interim.

Name: *Donald R. Heath*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: Jun 25, 1952
Presentation of Credentials: 12 Jul 1952
Termination of Mission: Superseded, Oct 2, 1954
Note: Also accredited to Laos and Vietnam; resident at Saigon. During Heath's tenure as non-resident Minister, Legation Phnom Penh was opened to the public, Nov 14, 1950, with Don V. Catlett as Chargé d'Affaires ad interim.

Note: Thomas J. Corcoran was serving as Chargé d'Affaires ad interim when Legation Phnom Penh was raised to Embassy status, Jun 25, 1952.

Name: *Robert McClintock*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: Aug 18, 1954
Presentation of Credentials: Oct 2, 1954
Termination of Mission: Left post, Oct 15, 1956

Name: *Carl W. Strom*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: Oct 11, 1956
Presentation of Credentials: Dec 7, 1956
Termination of Mission: Left post, Mar 8, 1959

Note: Commissioned during a recess of the Senate; recommissioned following confirmation on Jan 29, 1957.

Name: *William C. Trimble*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: Feb 16, 1959
Presentation of Credentials: Apr 23, 1959
Termination of Mission: Left post, Jun 8, 1962

Name: *Philip D. Sprouse*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: Jun 28, 1962
Presentation of Credentials: Aug 20, 1962
Termination of Mission: Left post, Mar 3, 1964

Name: *Randolph A. Kidder*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: Jul 9, 1964Note: Took oath of office and proceeded to post, but did not present credentials; left post, Sep 18, 1964.
Note: Alf E. Bergesen was serving as Chargé d'Affaires ad interim when Cambodia severed diplomatic relations with the U.S., May 3, 1965. Embassy Phnom Penh was reestablished Aug 16, 1969, with Lloyd M. Rives as Chargé d'Affaires ad interim.

Name: *Emory C. Swank*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: Sep 3, 1970
Presentation of Credentials: Sep 15, 1970
Termination of Mission: Left post, Sep 5, 1973
Note: Continued to serve, without accreditation, after the proclamation of the Khmer Republic.

Name: *John Gunther Dean*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: Mar 14, 1974
Presentation of Credentials: Apr 3, 1974
Termination of Mission: Left post Apr 12, 1975
Note: Commissioned to the Khmer Republic.

Note: Embassy Phnom Penh was closed on Apr 12, 1975, following the evacuation of all U.S. personnel.

Note: The U.S. Mission to Cambodia was established Nov 11, 1991, with Charles H. Twining as U.S. Representative.

Name: *Charles H. Twining*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: May 13, 1994
Presentation of Credentials: May 17, 1994
Termination of Mission: Left post, Nov 20, 1995

Name: *Kenneth M. Quinn*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: Dec 12, 1995
Presentation of Credentials: Mar 28, 1996
Termination of Mission: Left post July 25, 1999

Name: *Ken M. Wiedemann*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: June 7, 1999
Presentation of Credentials: August 31, 1999
Termination of Mission: Left post May 16, 2002

Name: *Charles A. Ray*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: November 15, 2002
Presentation of Credentials: January 4, 2003
Termination of Mission: Left post July 11, 2005

Name: *Joseph A. Mussomeli*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: June 27, 2005
Presentation of Credentials: September 22, 2005
Termination of Mission: Left post August, 2008

Name: *Carol A. Rodley*
Foreign Service officer
Title: Ambassador Extraordinary and Plenipotentiary
Appointment: October 24, 2008
Presentation of Credentials: January 20, 2009
Termination of Mission: Current

Photos:

- National Archives of Cambodia, Phnom Penh
- National Library of Cambodia, Phnom Penh
- National Archives & Records Administration, Washington
- Al Rockoff, War Photographer
- U.S. Embassy, Phnom Penh

Public Affairs Section
U.S. Embassy, Phnom Penh

http://cambodia.usembassy.gov
http://khmer.cambodia.usembassy.gov